ស.ប.ស.ខ

សមាគមបុគ្គលិកសិក្សាខ្មែរ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

* ចំណងមិត្តភាពនិងការឧបត្ថម្ភគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សម្ភារៈ

៤៨

# ទស្សនាវដ្តី គ្រូបង្រៀន




**សាលាបឋមសិក្សា បរគូង ស្រុកពេជ្រាដា មណ្ឌលគីរី**

**ត្រីមាសទី២ ឆ្នាំ ២០១៦**

ផ្សាយចេញរាល់ត្រីមាសពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

១២៨ឌ មហាវិថីព្រះនរោត្តម (ភ្នំពេញ)

ទូរស័ព្ទ : ០២៣ ២១៦ ១៨៤_០១២ ៦៣៨ ៨៨៩

អ៊ីម៉ែល : kta.amcek@gmail.com

# មាតិកា


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| | **វប្បធម៌ទូទៅ** | |
| ២ | ប្រទេសកម្ពុជាក្នុងសមាហរណកម្មសហគមន៍អាស៊ាន ឆ្នាំ២០១៥ | ៣ |
| ៣ | ប្រភពនៃការអប់រំក្នុងពិភពលោក (ត) | ៦ |
| | **ចិត្តវិទ្យាអប់រំ** | |
| ៤ | ការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈជំទង់ | ៩ |
| ៥ | មាតាបិតាពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុកតែជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា (ត) | ១២ |
| | **ការអប់រំ និង គរុកោសល្យ** | |
| ៦ | របៀប វិធីផ្ទាល់របស់គ្រូក្នុងការបង្រៀន (តចប់) | ១៤ |
| ៧ | កត្តាជាច្រើនធ្វើឱ្យអ្នកសិក្សាសម្រេចគោលដៅ | ១៦ |
| ៨ | សាលាធនធានជួយបង្កើនគុណភាពអប់រំនៅកម្ពុជា(តចប់) | ១៨ |
| ៩ | ពិសោធប្រើប្រដាប់លេងនិងសម្ភារឧបទេសសម្រាប់អប់រំបុត្រធីតានិងសិស្ស | ២០ |
| ១០ | តាក់តែងប្រធានចំណោទដោយផ្តើមចេញពី ប្រមាណវិធីមួយ | ២២ |
| | **វិទ្យាសាស្ត្រព័ត៌មាន-បច្ចេកវិទ្យា** | |
| ១១ | ការចុះឈ្មោះជាមួយគេហទំព័រគ្រូ | ២៥ |
| | **កំណាព្យ និង កម្សាន្ត** | |
| ១២ | ចំណងបីប្រការ (បទភុជង្គលីលា) | ២៨ |
| ១៣ | កុំសេពសុរា (បទព្រហ្មគីតិ) | ៣០ |
| | **វេទិកាសេរីន** | |
| ១៤ | ពុទ្ធសាសនានៅប្រទេសកម្ពុជា (ត) | ៣១ |
| ១៥ | សាលារៀនគឺជាគ្រឹះស្ថានសង្គមមួយ (តចប់) | ៣៤ |
| | **ព័ត៌មាន** | |
| ១៦ | សុត្តន្តប្រីជាឥន្ទ (១៨៥៩-១៩២៤) | ៣៦ |
| ១៧ | ប្រវត្តិ «បឹងត្របែក» | ៣៧ |
| ១៨ | ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១២ (ត) | ៣៩ |
| ១៩ | ស្ថិតិសពខែធ្នូ ឆ្នាំ២០១៤ ដល់ខែ ឆ្នាំ២០១៥ | ៤១ |



## គណៈកម្មការរៀបរៀង និង និពន្ធ

- លោក ជ័យ សយ្យនា
- លោក ថោង ម៉ូរ៉ាន់
- លោកស្រី គុយ ផល្លា
- លោក ជន ឈាងលី
- លោក ស្វាយ ទិត្យ
- លោកស្រី អ៊ឹម ប៊ុណ្ណារី
- លោក ព្រុំ សាមិត
- លោកស្រី ម៉ក់ ណាង
- លោក នៀ សុផន
- លោកស្រី ថាច់ ធីសារ៉ែន
- លោក អ៊ុម ជា
- សមាជិកសមាជិកា ស. ប. ស.ខ

## គណៈកម្មការត្រួតពិនិត្យ

- លោក យស់ អ៊ាង
- លោកស្រី ទន់ សាអ៊ឹម
- លោកស្រី ប្រាក់ សូលីដា
- លោក រ័ត្ន ហួត
- លោក សួង សារុណា
- លោក ស៊ុង វ៉ាន់ថន
- លោក ស៊ិន ស៊ឹម

## ការីកុំព្យូទ័រ

អ្នកស្រី ម៉ៃ សូនី


## ក្របខាងក្រៅ

- **ពីមុខ** : *សាលាបឋមសិក្សា បរគូង (ខេត្តមណ្ឌលគិរី)*
- **ពីក្រោយ** : *ដងស្ទឹងសង្កែ*


**ទូរស័ព្ទផ្ទះគ្រូបង្រៀន**

| | | |
|---|---|---|
| **ភ្នំពេញ** | : | ០៨៩ ៦៨៤ ០៨១ |
| **ព្រះសីហនុ** | : | ០១២ ៦៥៩ ៥៦០ |
| **សៀមរាប** | : | ០១២ ៦៧៥ ៦៤០ |
| **កំពង់ចាម** | : | ០១១ ៧៤២ ២២៤ |
| **ស្វាយរៀង** | : | ០៩៧ ២៦៥៥ ៩៨៧ |
| **ព្រៃវែង** | : | ០១២ ៦៧១ ៦៤០ |
| **កំពត** | : | ០១២ ៨៥៦ ៧២២ |
| **កែប** | : | ០៩៧ ៨ ៧២១៨៨០ |
| **តាកែវ** | : | ០៩៧ ៩៧៦១ ៥៨៨ |
| **រតនគិរី** | : | ០៩៧ ៩០៤២ ៥៨៤ |
| **ព្រះវិហារ** | : | ០១២ ២១៨២៨១ |
| **បាត់ដំបង** | : | ០១២ ៦៧៣ ៦៦២ |
| **ស្ទឹងត្រែង** | : | ០១២ ៩៦៤ ៤៩៦ |

# វិចារណកថា

ថ្វីបើសន្តិភាពជាបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់មនុស្សនៃភពផែនដីក៏ដោយប៉ុន្តែជម្លោះផ្ទៃក្នុង និងអន្តរជាតិនៅតែកើតមានកន្លែងនេះកន្លែងនោះដដែល។

ក្នុងន័យនេះ UNESCO ដែលមានមុខងារជាទីពិសោធន៍ផ្នែកគំនិត និងជាចលករជំរុញរាល់កិច្ចសហប្រតិបត្តិអន្តរជាតិបានបង្ហាញផ្លូវដើម្បីអនុវត្ត **"វប្បធម៌សន្តិភាព"** ជាក្របខ័ណ្ឌនៃទំនាក់ទំនង សកម្មភាពដូចខាងក្រោម៖

## ១.ការកសាងវប្បធម៌ សន្តិភាព និងអហិង្សា

- អាស្រ័យដោយការរៀបចំចាត់ចែងក្នុងរូបភាពជាការផ្សព្វផ្សាយជាសមោសរថ្នាក់ខ្ពស់ ការសន្ទនា សន្និសីទ សិក្ខាសាលា និងការជ្រើសយកយុវជនជាដៃគូ UNESCO បានទទួលជោគជ័យគួរឲ្យលើកទឹកចិត្តក្នុងការកសាងវប្បធម៌ សន្តិភាព និងអហិង្សា។

- ដើម្បីអបអរសាទរ ទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា UNESCO បានរៀបចំការសន្ទនាថ្នាក់ខ្ពស់អំពីវប្បធម៌ សន្តិភាព និងអហិង្សា នៅស្នាក់ការកណ្តាលនៃ អ.ស.ប. ដោយសង្កត់ធ្ងន់លើ "សន្តិភាពស្ថិតស្ថេរ និងអនាគតស្ថិតស្ថេរ"។ វាគ្មិនល្បីៗបានអំពាវនាវ សូមឲ្យទាំងអស់គ្នាចូលរួមធ្វើសកម្មភាពច្បាស់លាស់ ដើម្បីសន្តិភាព សិទ្ធិមនុស្ស ការសន្តោស ការគោរព និងការយល់គ្នាទៅវិញទៅមក។

- ក្រុមអ្នកគិតគូរ និងអ្នកនយោបាយធំៗដែលមានឥទ្ធិពលបានជួបជុំផ្លាស់ប្តូរមតិយោបល់ និងដាក់ចេញសេចក្តីអំពាវនាវអំពីការខិតចូលជិតគ្នា ដើម្បីធ្វើឲ្យប្រសើរឡើងវិញនូវសន្តិភាពក្នុងពិភពលោកដោយផ្តោតជាសំខាន់លើតួនាទីរបស់UNESCOពិសេសទាក់ទងនឹងការប្រមូលផ្តុំយុវជនសំដៅកសាងសន្តិភាព និងសង្គមស្ថិតស្ថេរ។

- ជំរុញលើកទឹកចិត្តចំពោះវប្បធម៌សន្តិភាពដោយសិក្សាស្រាវជ្រាវរកឲ្យឃើញអត្តសញ្ញាណនៃលំនាំសកម្មភាពឆ្ពោះទៅកសាងសន្តិភាពដូចជា តួនាទីនៃតួអង្គជាប្រពៃណីក្នុងយន្តការផ្ទៃក្នុងដើម្បីបង្ការនិងដោះស្រាយជម្លោះជាអាទិ៍ តួនាទីនៃសេដ្ឋកិច្ច តួនាទីនៃសង្គមស៊ីវិល និងបងប្អូនរួមឈាមដែលស្ថិតនៅក្រៅមាតុភូមិ...។

## ២.ដៃគូដើម្បីសន្តិភាព

ដៃគូធំៗ និងសំខាន់ៗចំនួន ៣ ដែលបានខិតខំប្រឹងប្រែងធ្វើសកម្មភាព ដើម្បីកសាងវប្បធម៌សន្តិភាពគឺ៖

- **វិទ្យាស្ថានអន្តរជាតិដើម្បីសន្តិភាព៖**បានសហការជាមួយសហគមន៍ទីក្រុងប្រជុំជននៃតំបន់ជាច្រើនក្នុងពិភពលោក សំដៅជំរុញប្រតិបត្តិការសន្តិភាពក្នុងចំណោមអ្នកអប់រំ អ្នកដឹកនាំសាសនា និងសហគមន៍ សហគ្រិន ប៉ូលីសមូលដ្ឋាន និងយុវជនដែលរងគ្រោះដោយអំពើហិង្សា។

ជាក់ស្ដែងកម្មវិធីអប់រំយុវជនដែលស្រឡាញ់សន្តិភាព បានណែនាំឲ្យយល់ដឹងពីរបៀបដោះស្រាយជម្លោះ ភាពជាអ្នកដឹកនាំ ការអភិវឌ្ឍសហគមន៍ បច្ចេកវិទ្យា ព័ត៌មានវិទ្យា...។

- **វិទ្យាស្ថានអប់រំ Mahatma Gandhi ដើម្បីសន្តិភាព និងការអភិវឌ្ឍស្ថិតស្ថេរ** មានគោលបំណងអភិវឌ្ឍ និងជំរុញអនុវត្តនូវវិធីសាស្ត្រគរុកោសល្យថ្មី ដែលអនុញ្ញាតឲ្យសិស្សម្ចាស់ការសិក្សារៀនសូត្រដើម្បីប្រែក្លាយជីវិតរបស់គេនិងកសាងពិភពលោកឲ្យកាន់តែប្រសើរនិងសុខក្សេមក្សាន្តស្ថិតស្ថេរ។

- យុទ្ធនាការនៃទង្វើអ្វីម្យ៉ាងដើម្បីភាពផ្សេងៗគ្នានិងភាពនៃវត្ថុមួយនៅក្នុងវត្ថុមួយទៀតដោយសហការជាមួយUNESCOបានអំពាវនាវឲ្យមនុស្សគ្រប់រូបក្នុងពិភពលោកធ្វើសកម្មភាពដើម្បីគាំទ្រដល់ភាពផ្សេងៗគ្នានៃវប្បធម៌ តាមរយៈការផ្លាស់ប្ដូរវប្បធម៌ទៅវិញទៅមក។

### ៣.ការគាំទ្រលទ្ធិប្រជាធិបតេយ្យ

ក្នុងលំនាំប្រជាធិបតេយ្យ ការបោះឆ្នោតទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ដើម្បីជ្រើសរើសតំណាងប្រជាជនឆ្ពោះទៅដឹកនាំស្ថាប័ននីតិបញ្ញត្តិនិងស្ថាប័ននីតិប្រតិបត្តិត្រូវតែអនុវត្តឲ្យបានទៀងទាត់ ត្រឹមត្រូវ និងមានតម្លាភាព។ ទន្ទឹមនឹងនេះការចូលរួមរបស់យុវជន យុវនារីដែលជាវេនបន្ត គឺជាគោលការណ៍មូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ។ ក៏ប៉ុន្តែវេនបន្តត្រូវរឹងមាំលើលក្ខណៈសម្បត្តិ ៣ យ៉ាងគឺសមត្ថភាព គំនិតច្នៃប្រឌិតថ្មី និងភាពប៉ិនប្រសប់។ "ច្រវាក់រឹងមាំក៏អាស្រ័យដោយកងច្រវាក់រឹងមាំដែរ"។

### ៤.ការពង្រឹងសិទ្ធិមនុស្ស

UNESCO ពង្រឹងសិទ្ធិមនុស្សតាមរយៈទង្វើជាក់ស្ដែងនៃរាល់គំនិតផ្ដួចផ្ដើមថ្មីសម្រាប់វិសាលភាពតំបន់ និងអន្តរជាតិគឺការបណ្ដុះបណ្ដាល។ ក្នុងន័យនេះ គេអាចប្រមូលចងក្រងជាទិន្នន័យនៃស្ថានភាពនិងជំនាន់សិទ្ធិមនុស្សក្នុងពិភពលោកដោយសាកល្បងលើកកម្ពស់និងពង្រឹងសមត្ថភាពនៃអ្នកចូលរួមលើផ្នែកការវិនិច្ឆ័យ ការវិភាគ ការធ្វើផែនការ និងការវាយតម្លៃគោលនយោបាយសាធារណៈ ទាក់ទងនឹងសិទ្ធិមនុស្ស។

យ៉ាងណាមិញ សន្តិភាពនៅកម្ពុជាដែលកើតមានឡើងតាមរយៈគោលនយោបាយឈ្នះ-ឈ្នះ ក្រោមគំនិតផ្ដើមរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គឺជាដំណោះស្រាយផ្ទៃក្នុងរវាងភាគីកម្ពុជា និងភាគីកម្ពុជា ក្នុងស្មារតីរួមរស់ជាមួយគ្នា ជាបងប្អូនរួមឈាមដើម្បីឧត្តមប្រយោជន៍ជាតិនិងប្រជាជនកម្ពុជា៕

**គណៈកម្មាធិការស.ប.ស.ខ.**




# ប្រទេសកម្ពុជាក្នុងសមាហរណកម្មសហគមន៍អាស៊ានឆ្នាំ២០១៥

## I-បុព្វហេតុនៃការកសាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)៖ ផែនទីនៃបណ្ដាប្រទេសសមាជិកជាសមាគមអាស៊ាន

បណ្ដាប្រទេសអាស៊ីអាគ្នេយ៍មួយចំនួនដែលជារដ្ឋទើបឯករាជ្យថ្មីថ្មោងដូចជា ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបុរីនិងប្រទេសថៃដែលមិនបានឋិតនៅក្រោមការគ្រប់គ្រងរបស់អាណានិគមបស្ចិមប្រទេសណាមួយនោះ គឺសុទ្ធតែកំពុងប្រឈមមុខនឹងការគំរាមកំហែងពីក្រៅ និងបញ្ហាផ្ទៃក្នុងប្រទេស។ ប្រទេសទាំងអស់នោះ ភាគច្រើនសុទ្ធតែត្រូវប្រឈមមុខនឹងការងើបបះបោរទាមទារឯករាជ្យពីសំណាក់ក្រុមជនជាតិភាគតិច។ មិនត្រឹមតែប៉ុណ្ណោះ បណ្ដាប្រទេសអាស៊ីអាគ្នេយ៍ដែលជាកោះនោះមានទំនាស់ទឹកដីនឹងគ្នាថែមទៀតដូចជា ម៉ាឡេស៊ីមានទំនាស់មួយឥណ្ឌូណេស៊ី ហើយតំបន់នេះទាំងមូលជាសមរភូមិនៃសង្គ្រាមត្រជាក់និងក៏ជាតំបន់ក្ដៅគគុកជាងគេបង្អស់នៃជម្លោះមនោគមវិជ្ជារវាងអាមេរិក សូវៀតនិងចិន។ ជម្លោះមនោគមវិជ្ជានេះស្ដែងឡើងតាមរយៈសង្គ្រាមវៀតណាមដែលផ្ដើមរីករាលដាលហូរចូលដល់កម្ពុជានិងឡាវហើយបានជះឥទ្ធិពលដល់បណ្ដាប្រទេសដែលមានព្រំដែនជាប់គ្នានិងរាលដាលចូលមកពាសពេញឥណ្ឌូចិនតែម្ដង។ ឥទ្ធិពលសង្គ្រាមត្រជាក់កាលសម័យនោះក៏បានចូលជ្រួតជ្រាបទៅដល់បណ្ដាប្រទេសអាស៊ីអាគ្នេយ៍ដទៃទៀតដែរដូចជា ភូមា ហ្វីលីពីន ថៃ និងឥណ្ឌូណេស៊ីជាដើម។ភាគច្រើននៃប្រទេសដែលទប់ទល់នឹងឥទ្ធិពលមនោគមវិជ្ជាកុម្មុយនិស្ដ គឺជាប្រទេសសម្ព័ន្ធមិត្តទាំង ៥ របស់អាមេរិកគឺថៃ ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូណេស៊ី និងហ្វីលីពីនដែលបានសម្រេចចិត្តបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថាអាស៊ាន នៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧។ គោលបំណងនៃការបង្កើតសមាគមអាស៊ាននេះ គឺសហប្រតិបត្តិការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌រវាងបណ្ដាប្រទេសសមាជិកនិងជាពិសេសគឺការបង្កើតតំបន់សន្តិភាពមួយដែលមានមូលដ្ឋាននៅលើសេរីភាពនិងអព្យាក្រឹតភាព។ ក្រៅពីនេះក៏ត្រូវដោះស្រាយបញ្ហាធំៗពីរ៖ ទីមួយគឺត្រូវទប់កុំឱ្យសង្គ្រាមកើតឡើងរវាងពួកគេ និងទីពីរ គឺត្រូវពឹងពាក់អាមេរិក ដើម្បីខ្ទប់កុំឱ្យមនោគមវិជ្ជានិងសកម្មភាពទ័ពព្រៃកុម្មុយនិស្ដរីកធំធាត់រាលដាលនៅក្នុងប្រទេសរបស់ពួកគេបាន។មូលហេតុធំជាងគេមួយទៀតនៃការបង្កើតអាស៊ាននៅឆ្នាំ១៩៦៧ ជាការប្រយុទ្ធទប់ទល់នឹងគ្រោះថ្នាក់កុម្មុយនិស្ដដូចដែលសារព័ត៌មានផ្លូវការរបស់ចិនសម័យនោះ

បានសរសេរថា អាស៊ានគឺជាសម្ព័ន្ធភាពប្រឆាំងបដិវត្តន៍កុម្មុយនិស្តដែលត្រូវបានបង្កើតឡើងដើម្បីប្រយុទ្ធនឹងចិនប្រយុទ្ធនឹងកុម្មុយនិស្ត។



កិច្ចប្រជុំលើកទី១នៃអាស៊ាន ខែសីហាឆ្នាំ១៩៦៧នៅបាងកកប្រទេសថៃ

ចាប់ពីដើមទស្សវត្សរ៍ទី៨០ រហូតដល់ដើមទសវត្សរ៍ទី៩០ទើបឃើញបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ចំនួន៥ទៀតបានចាកចេញជាបណ្តើរៗពីភាពប្រេះឆាដើម្បីឆ្ពោះទៅរកទីដៅនៃការឯកភាពក្រោម ដំបូលតែមួយនៃអង្គការតំបន់អាស៊ាន ព្រោះតែសង្គ្រាមត្រជាក់ត្រូវបានបញ្ចប់ដោយសហភាពសូវៀតបានរលំរលាយនៅថ្ងៃទី២៦ខែធ្នូឆ្នាំ១៩៩១។ ប្រទេសប្រ៊ុយណេបានក្លាយជាសមាជិកទី៦ របស់អាស៊ានឆ្នាំ១៩៨៤។ សាធារណរដ្ឋសង្គមនិយមវៀតណាមបានក្លាយជាសមា-ជិកទី៧ របស់ អាស៊ានឆ្នាំ១៩៩៥។ សាធារណរដ្ឋប្រជាតិបតេយ្យប្រជាមានិតឡាវ និងសហភាពមីយ៉ាន់ម៉ាបាន ក្លាយជាសមាជិកទី៨-ទី៩នៅឆ្នាំ១៩៩៧។ ហើយតាមការគ្រោងទុកអាស៊ានត្រូវមានសមាជិកទាំង ១០ប្រទេសនៅឆ្នាំ១៩៩៧។ ប៉ុន្តែដោយសារប្រទេសកម្ពុជាមានព្រឹត្តិការណ៍ថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ ហេតុនេះក៏ត្រូវបានពន្យាពេលរហូតថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ ទើបក្លាយជាសមាជិក ទី១០ របស់អាស៊ាន។ បន្ទាប់ពីប្រទេសកម្ពុជាបានធ្វើសមាហរណកម្មផ្ទៃក្នុងនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៩៨ គឺបានបញ្ចប់អង្គការចាត់តាំងខ្មែរក្រហមទាំងស្រុងដែលជាប្រការមួយជំរុញឲ្យបណ្តា ប្រទេសជាសមាជិកទាំងចាស់ទាំងថ្មីត្រូវធ្វើដំណើររួមគ្នាដើម្បីសមាហរណកម្មឆ្ពោះទៅរកជោគជ័យវាសនាតែមួយ។

**II- ចក្ខុវិស័យដើម្បីឆ្ពោះទៅការបង្កើតសហគមន៍អាស៊ានមុនឆ្នាំ២០២០៖**

គោលដៅនិងទិសដៅរបស់សមាគមអាស៊ាន ដែលបានកំណត់ក្នុងសេចក្តីថ្លែងការណ៍ទីក្រុងបាងកកនៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការណ៍តំបន់ (Regional Cooperation) អាស៊ីអាគ្នេយ៍ក្នុងស្មារតីសមភាព និងភាពជាដៃគូដើម្បីរួមចំណែកកសាងសន្តិភាព វឌ្ឍនភាព វិបុលភាព នៅក្នុងតំបន់។ ការបង្កើតសហគមន៍នៃប្រជាជាតិអាស៊ីអាគ្នេយ៍ប្រកបដោយ

សន្តិភាពរវាងគ្នានិងគ្នាជាមួយពិភពលោកដើម្បីសម្រេចបានឆាប់រហ័សនូវវិបុលភាពសម្រាប់ប្រជាជាតិនិងលើកស្ទួយជីវភាពប្រជាជនស្មើមុខស្មើមាត់ក្នុងតំបន់មុនឆ្នាំ២០២០។ នៅឆ្នាំ២០០៣ ប្រមុខដឹកនាំអាស៊ានបានប្រកាសថា យើងនឹងបង្កើតនូវសហគមន៍សេដ្ឋកិច្ចអាស៊ានមួយនៅឆ្នាំ២០១៥ដោយសារកំណើនសេដ្ឋកិច្ចរបស់ចិននិងឥណ្ឌាដែលជាដៃគូដ៏រឹងមាំនៃសេដ្ឋកិច្ចរបស់បណ្ដាប្រទេសសមាជិកសមាគមអាស៊ាន។កិច្ចប្រជុំកំពូលអាស៊ានលើកទី២៥នៅប្រទេសមីយ៉ាន់-ម៉ា លោក Li Keqiang នាយករដ្ឋមន្ត្រីប្រទេសចិនបានធ្វើការសន្យា និងជំរុញនូវកិច្ចសហប្រតិបត្តិការរវាងទីក្រុងប៉េកាំង និងបណ្ដាប្រទេសសមាជិកអាស៊ាន ដើម្បីពង្រីកទំហំពាណិជ្ជកម្មចិន និងអាស៊ានឱ្យកាន់តែមានសន្ទុះ។ លោក Li Keqiang បានផ្ដល់ទឹកប្រាក់ 30 Million Yuan ជាប្រាក់ជំនួយ ដើម្បីគាំទ្រដល់កិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចនិងបច្ចេកវិទ្យា។ កាលពីឆ្នាំ២០១៣ ទំហំពាណិជ្ជកម្មចិន និងអាស៊ានមានទឹកប្រាក់រហូតដល់ USD444 Billion។ ប្រទេសចិនក៏ធ្លាប់គាំទ្រផ្នែកហិរញ្ញវត្ថុចំពោះប្រទេសទាំង១០ នៃសមាគមអាស៊ាននូវទឹកប្រាក់កម្ចី USD20 Billion និងប្រាក់ 3 Billion Yuan (HKS3.8 Billion) ដើម្បីកាត់បន្ថយភាពក្រីក្រ និងកសាងហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ដូច្នេះប្រទេសចិនមានតួនាទីសំខាន់ណាស់សម្រាប់សមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន។ការបង្កើតនូវសហគមន៍អាស៊ានក្នុងគោលដៅចាប់ដៃគ្នាកសាងសន្តិភាពពង្រឹងសហប្រតិបត្តិការនិងលំហូរសេដ្ឋកិច្ចនៅក្នុងតំបន់ដែលជាគោលដៅចម្បងមួយស្របតាមគោលការណ៍ដែលបានកំណត់កាលពីឆ្នាំ១៩៩៧។

(*លោក* Li Keqiang *ក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី២៥ នៅប្រទេសភូមា*)

ផែនការនៃចក្ខុវិស័យអាស៊ាន២០២០ ត្រូវបានអនុម័តដោយមេដឹកនាំកំពូលអាស៊ានក្នុងកិច្ចប្រជុំកំពូលរំលឹកខួប៣០ឆ្នាំរបស់អាស៊ាននៅក្រុងកូឡាឡាំពួរ នៅថ្ងៃទី១៤-១៦ ខែធ្នូ ឆ្នាំ១៩៩៧។

## ដំណើរការរៀបចំចក្ខុវស័យអាស៊ាន

| ការអនុម័តផែនការនៃចក្ខុវិស័យ | ការរៀបចំចក្ខុវិស័យដោយក្រុមឥស្សរជនឆ្នើមអាស៊ាន | របាយការណ៍និងអនុសាសន៍ជូនមេដឹកនាំអាស៊ាន |
|---|---|---|
| ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ មេដឹកនាំអាស៊ានអនុម័តផែនការនៃចក្ខុវិស័យអាស៊ានឆ្នាំ២០២០ | **ឆ្នាំ១៩៩៩-២០០០ ក្រុមឥស្សរជនឆ្នើមអាស៊ានខាងចក្ខុវិស័យឆ្នាំ២០២០** រៀបចំចក្ខុវិស័យជារបាយការណ៍ និងអនុសាសន៍ជូនថ្នាក់ដឹកនាំ | **ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០០ ក្រុមឥស្សរជនឆ្នើមអាស៊ានខាងចក្ខុវិស័យ២០២០** ដាក់ជារបាយការណ៍ និងអនុសាសន៍ជូនថ្នាក់ដឹកនាំអាស៊ាន |

(*នៅមានត*)

*ដោយលោក* **គួយ សុគាន**

# ប្រភពនៃការអប់រំក្នុងពិភពលោក (ត)

## គ- ការអប់រំជាការបណ្ដុះសនិទានភាព

**អារីស្តូត ស្ដីពីការអប់រំ:** ក្នុងផ្នែកនយោបាយរបស់គាត់ អារីស្តូត អះអាងថា សហគមន៍ល្អស្ថិតនៅលើសនិទានភាព(១)របស់សមាជិក។ ប្រសិនបើការអប់រំដែលជាអ្នកបណ្ដុះសនិទានភាពនោះត្រូវបានធ្វេសប្រហែស ដូច្នេះសហគមន៍នឹងទទួលរងគ្រោះថ្នាក់។ ប្លាតុង អារីស្តូត បានបែងចែកភាពខុសគ្នារវាងការអប់រំសេរី និងការបណ្ដុះបណ្ដាលបច្ចេកទេស។ អារីស្តូត បានមើលឃើញសិល្បៈសេរី ថាជាការពង្រីកនភាបាទ(២)របស់មនុស្សញាណ និងការជ្រើសរើស។ លោកបានមើលឃើញការបណ្ដុះបណ្ដាលវិជ្ជាជីវៈថាជារឿងមានតម្លៃតាមដែនកំណត់របស់វាតែម្យ៉ាង។ការពិភាក្សានាសម័យទំនើបរវាងអ្នកអប់រំសេរី និងមុខរបរជាញឹកញាប់ឆ្លុះបញ្ចាំងបញ្ហាតែមួយ ដែលអារីស្តូត និងអ្នកទ្រឹស្តីដទៃទៀតបានពិនិត្យមើល ហើយក្នុងនាមជាគ្រូម្នាក់ អ្នកអាចនឹងជួបប្រទះកំណែប្រែថ្មីនៃការពិភាក្សាតែមួយនៅពេលដែលសិស្សសួរអ្នក ពីមូលហេតុដែលគេគួរសិក្សាអ្វីមួយដែលគេជឿជាក់ថា វានឹងមិនត្រូវបានប្រើប្រាស់។ អ្វីជាសនិទានកម្មរបស់អ្នក ដើម្បីបង្រៀនបំណិនពិតប្រាកដ និងមុខវិជ្ជាទាំងឡាយ តែមិនមែនមុខវិជ្ជាផ្សេងទៀតឡើយ។

## ឃ- កម្មវិធីសិក្សារបស់អារីស្តូត

អារីស្តូតបានផ្ដល់ឱ្យមានការអប់រំជាកាតព្វកិច្ច។ ការអប់រំកុមារតូចគឺត្រូវមានការលេងសកម្មភាពខាងរាងកាយ និងរឿងនិទានដែលសមរម្យ។

កុមារពីអាយុ៧ឆ្នាំដល់១៤ឆ្នាំ ត្រូវរៀនលេខ រៀនអាន សរសេរ និងទម្លាប់សីលធម៌សមរម្យ ដើម្បីត្រៀមរៀបចំពួកគេឱ្យសិក្សានាពេលអនាគត ខាងសិល្បៈសេរី។ កម្មវិធីសិក្សារបស់គេ ក៏បានរាប់បញ្ចូលការអប់រំកាយ និងតន្ត្រីផងដែរ ដើម្បីបណ្ដុះផ្នែកអធ្យាស្រ័យចិត្តរំភើបសមរម្យ។

ពីអាយុ១៥ឆ្នាំរហូតដល់២១ឆ្នាំ យុវជនត្រូវសិក្សាគណិតវិទ្យា ធរណីមាត្រ តារាសាស្ត្រ វេយ្យាករណ៍ វោហាសាស្ត្រ សីលវិទ្យា និងនយោបាយ។

នៅអាយុ២១ឆ្នាំសិស្សត្រូវបន្តរៀនមុខវិជ្ជាខាងទ្រឹស្តីថែមទៀតដូចជារូបវិទ្យាលោកធាតុវិទ្យា ជីវវិទ្យា ចិត្តវិទ្យា តក្កវិទ្យា និងបរមត្ថវិទ្យា។

## ង-តួនាទីតាមដែនកំណត់របស់ស្ត្រី

ដោយជឿជាក់ថា ស្ត្រីមានប្រាជ្ញាអន់ជាងបុរស អារីស្តូត បានយកចិត្តទុកដាក់លើការអប់រំបុរសតែប៉ុណ្ណោះ។ ក្មេងស្រីត្រូវបានគេអប់រំសម្រាប់តែឱ្យធ្វើការងារផ្ទះ និងតួនាទីចិញ្ចឹមកូនដែលចាំបាច់សម្រាប់ពេលអនាគត ជាប្រពន្ធនិងជាមាតា។

---

(១)ភាពត្រឹមត្រូវ(២)ជើងមេឃ ព្រំដែន

ច-ចំណេះដឹងជាបញ្ញត្តិដែលផ្អែកលើវត្ថុ

**ទ្រឹស្តីរបស់អារីស្តូតនៃចំណេះដឹង:** អារីស្តូត ជាជនតថនិយម ខុសប្លែកពីប្លាតុង ជាជនមនោនិយមនៅក្នុងបញ្ញត្តិរបស់គាត់ស្តីពីចំណេះដឹងកើតឡើងពីវត្ថុជាជាងពីគំនិតដែលកើតឡើងមុននៅក្នុងចិត្ត។ ការអប់រំផ្តោតទៅលើការចាត់ថ្នាក់របស់វត្ថុទៅជាបញ្ហាប្រធានបទឬមុខវិជ្ជា។

ឧទាហរណ៍ប្រសិនបើអ្នកកំពុងតែបង្រៀនភូគសាស្រ្តដោយប្រើប្រាស់វិធីអារីស្តូតនោះ អ្នកអាចបង្រៀនអំពីដើមឈើទាំងឡាយជាថ្នាក់មួយដែលជាប្រភេទទូទៅមួយក្នុងតថភាពភូគសាស្រ្ត និងអំពីដើមឈើ ជាពិសេសដែលជាសមាជិកមួយៗនៃថ្នាក់នោះ។

ឆ-ឥទ្ធិពលដែលស្ថិតនៅរបស់អារីស្តូត

គោលដៅបឋមរបស់សាលារៀនអារីស្តូត គឺត្រូវបណ្តុះសនិទានភាព។ ក្នុងនាមជាស្ថាប័នសិក្សា សាលារៀនគួរតែផ្តល់កម្មវិធីសិក្សាទៅតាមបញ្ហាប្រធានបទដែលបានកំណត់ដោយផ្អែកលើមុខវិជ្ជាវិទ្យាសាស្រ្តនិងមានខ្លឹមសារ។ គ្រូត្រូវតែមានចំណេះដឹងជំនាញទៅលើមុខវិជ្ជារបស់ខ្លួន និងមានជំនាញក្នុងការជំរុញទឹកចិត្តសិស្ស និងផ្ទេរចំណេះដឹងទៅឱ្យសិស្ស។ ទស្សនវិជ្ជារបស់អារីស្តូតមានខ្លឹមសារដ៏សំខាន់ទៅលើការអប់រំលោកខាងលិច។ ក្នុងចំណោមលទ្ធិរបស់សាសនាគ្រិស្ត វាក្លាយជាមូលដ្ឋានគ្រឹះនៃការអប់រំសិក្សានៅមជ្ឈិមសម័យ (ខ្លឹមសារលំអិតនឹងបកស្រាយនៅពេលក្រោយ)។

## ៥.៥ អ៊ីសូក្រាត: សិល្បៈនៃការថ្លែងសុន្ទរកថា និងវោហារសាស្ត្រ

អ្នកវោហារសាស្រ្តជនជាតិក្រិចឈ្មោះ Isocrates(436-388B.C.) គឺជាមនុស្សដ៏សំខាន់សម្រាប់ទ្រឹស្តីអប់រំដែលមានរចនាសម្ព័ន្ធត្រឹមត្រូវលើសគេឯងដែលសង្កត់ធ្ងន់ទៅលើចំណេះដឹងនិងបំណិនវោហារសាស្រ្ត[១]។ ទ្រឹស្តីរបស់គាត់ប្រកាន់តាមផ្លូវកណ្តាល រវាងទំនាស់នៃពួកសូហ្វីសនិងប្លាតុង។ អភិប្រាយរបស់អ៊ីសូក្រាត ប្រឆាំងនឹងពួកសូហ្វីសបានពន្យល់នូវវិធីដែលបានប្រើប្រាស់ក្នុងសាលារៀននេះ។

*ក-ការសង្កត់ធ្ងន់ទៅលើវោហារសាស្ត្រ*

អ៊ីសូក្រាតចាត់ទុកគោលដៅបឋមនៃការអប់រំថាត្រូវតែត្រៀមរៀបចំរដ្ឋបុរសឱ្យមានការគិតច្បាស់លាស់ប្រកបដោយវិចារណញ្ញាណនិងសច្ចភាព។ គាត់ជឿជាក់ថា កំណែទម្រង់ស៊ីវិលទាមទារឱ្យមានការអប់រំអ្នកដឹកនាំដែលប្រកបដោយគុណធម៌ដែលអាចជាអ្នករដ្ឋបាលមានសិទ្ធភាព។ ក្នុងចំណោមការសិក្សាដោយសេរីIsocratesយល់ថាវោហារសាស្រ្តដែលបានកំណត់ន័យថាជាការបង្ហាញគំនិតប្រកបដោយវិចារណញ្ញាណនោះគឺជារឿងសំខាន់បំផុតក្នុងការបណ្តុះសីលធម៌និងភាពជាអ្នកដឹកនាំនយោបាយ។ ការអប់រំវោហារសាស្រ្ត គួរតែផ្សំបញ្ចូលគ្នាសិល្បៈ និងវិទ្យាសាស្រ្ត និងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។ អ្នកជំនាញខាងថ្លែងសុន្ទរកថាដ៏មានតម្លៃ គួរតែអះអាងសម្រាប់បុព្វបុរសកិត្តិយស ដែលជំរុញដល់កុសលសាធារណៈ។ តាមគោលវិធីខាងលើអ្នកមានជំនាញខាងថ្លែងសុន្ទរកថា នឹងបញ្ចុះបញ្ចូលមនុស្សឱ្យធ្វើតាមគោលនយោបាយដ៏ល្អ។ Isocrates

(1)Ekaterina V.haskins Logos and Power

ប្រឆាំងនឹងការបង្រៀនរបស់ពួកសូហ្វីសនៃវោហារសាស្ត្រដែលគ្រាន់តែជាផ្លូវបញ្ចុះបញ្ចូលដដែល ឬបច្ចេកទេសទំនាក់ទំនងសាធារណៈ។

សិស្សរបស់ Isocrates ដែលបានសិក្សានៅសាលារបស់គាត់រយៈពេល ៤ ឆ្នាំនោះ បានសិក្សាវោហារសាស្ត្រ នយោបាយ ប្រវត្តិសាស្ត្រ និងសីលវិទ្យា។ពួកគេបានវិភាគ និងគ្រាប់តាមសិល្បៈនៃការថ្លែងសុន្ទរកថានិងប្រតិបត្តិការនិយាយជាសាធារណៈ។ ក្នុងនាមជាគ្រូគំរូម្នាក់ Isocrates ជឿជាក់ថា គាត់ទទួលខុសត្រូវចំពោះការជះឥទ្ធិពលដល់សិស្ស តាមការបកស្រាយផ្ទាល់របស់គាត់នៃចំណេះដឹង បំណិន និងចរិយាខាងសីលវិទ្យា។

*ខ-ការធ្វើតុល្យភាពប្លាតុង និងពួកសូហ្វីស*

ប្រឆាំងនឹងកាលានុវត្តនិយមដ៏កម្រោលរបស់ពួកសូហ្វីសគាត់បានបដិសេធការអះអាងរបស់ប្លាតុងដែលថា ការអប់រំមានតែទ្រឹស្ដីសុទ្ធ និងអរូបី។ ចំពោះការអប់រំ Isocrates បានរួមចំណែកដល់សេវាកម្មសាធារណៈដែលត្រូវបានដឹកនាំដោយចំណេះដឹង។ Isocrates មានឥទ្ធិពលទៅលើប្រពៃណីខាងវោហារសាស្ត្រក្នុងការអប់រំជាពិសេសអ្នកទ្រឹស្ដីអប់រំរបស់រ៉ូម៉ាំងឈ្មោះ Quintilian។ ដោយទទួលស្គាល់វិសាលភាពវោហារសាស្ត្ររបស់មនុស្សជាតិ Isocrates ក៏បានរួមចំណែកដល់ឧត្តមគតិរបស់មនុស្សដែលមានការអប់រំដោយសេរី។

(*នៅមានត*)

*អនុបណ្ឌិត***សូ សុធីរ**

## ច្បាប់ល្បើកថ្មី

| | | |
|---|---|---|
| ឯអ្នកប្រមឹក | ប្រមូលកនធឹក | ធ្វើភឿននឹងក្មេង |
| ស្រដីច្រើនតឹង | ស្រវឹងវង្វេង | ជំហរអួតក្អេង |
| | មិនចេះក្រខ្សត់។ | |
| អួតទាំងបំពាន | ផឹកម៉ៃ្វលុយមាន | ផឹកម៉ៃ្វលុយអត់ |
| ឯងចេះតែកិន | ចិនចេះតែកត់ | ផឹកដល់កំណត់ |
| | យកស្រែបញ្ចាំ។ | |
| សល់ថ្នាលមួយពីរ | វាយគោស្ទោរស៊ី | មិនគិតខ្លាចកម្ម |
| ផឹកជ្រុលហួសល្បត់ | អត់បាយរាល់ឆ្នាំ | អស់ស្រែបញ្ចាំ |
| | បញ្ចាំកូនទៀត។ | |

ភិរម្យ ង៉ុយ



# ចិត្តវិទ្យាអប់រំ

## ការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈជំទង់

### ១-ការប្រែប្រួលបុគ្គលិកលក្ខណៈ

**ក.**ចំណុចដែលគួរឱ្យកត់សម្គាល់នៅវ័យនេះ គឺភាពគ្រប់ការ។ ភាពគ្រប់ការនេះជះឥទ្ធិពលយ៉ាងខ្លាំងលើការប្រែប្រួលបុគ្គលិកលក្ខណៈរបស់ជំទង់។ គ្រូ ឬអ្នកអប់រំត្រូវតែមានការយល់ដឹងឱ្យបានច្បាស់នូវលក្ខណៈរបស់ជំទង់។

**ខ.**នៅជំណាក់នេះ ជំទង់ដឹងថាខ្លួនគេចូលក្នុងជំណាក់ថ្មីមួយនៃជីវិត ហើយគេមានតម្រូវការថ្មី ចិត្តរំភើបថ្មីសញ្ចេតនាថ្មី អត្តចរិតថ្មី ការគិតថ្មី ចំណង់ចំណូលចិត្តថ្មី ចិត្តគំនិតថ្មី បំណងប្រាថ្នាថ្មី...។បើយើងប្រៀបធៀបសកម្មភាពជំទង់ទៅនឹងសកម្មភាពកុមារយើងឃើញថាសកម្មភាពសំខាន់ៗរបស់ជំទង់ផ្លាស់ប្តូរ។ ចំពោះជំទង់សកម្មភាពដ៏សំខាន់ជាងគេ គឺការសិក្សា បន្ទាប់មកគឺការធ្វើពលកម្ម និងល្បែង។ ជានិច្ចកាល ជំទង់បានជួបប្រទះលក្ខខណ្ឌសកម្មភាពបញ្ហាថ្មីៗក្នុងសង្គមដូចជាការសេពគប់មិត្តភក្តិ និងបញ្ហាថ្មីៗជាច្រើនតាមមុខវិជ្ជាសិក្សាដែលសម្បូរទៅដោយសញ្ញាណអរូបី។

**ឧទាហរណ៍៖** ការសិក្សាតម្រង់ទៅសញ្ញាណអរូបី មុខវិជ្ជាបង្រៀនចាប់ផ្តើមដាច់ចេញពីគ្នា។ កាលនៅបឋមសិក្សាកុមារសិក្សានូវមូលដ្ឋានភាសាជាតិជាចម្បងរួមទាំងគណិតវិទ្យានិងសញ្ញាណខ្លះៗនៃវិទ្យាសាស្ត្រ។ប៉ុន្តែនៅមធ្យមសិក្សាបឋមភូមិ គេត្រូវការសិក្សាមុខវិជ្ជាច្រើន។ ក្រៅពីអក្សរសាស្ត្រ និងគណិតវិទ្យា គេសិក្សាពីប្រវត្តិវិទ្យា ភូមិវិទ្យា ជីវវិទ្យា...។

ជំទង់ចាប់ផ្តើមសិក្សាជាមួយគ្រូច្រើននាក់តាមមុខវិជ្ជាផ្សេងៗគ្នា។ ពេលនេះជំទង់ចាប់ផ្តើមមានឧត្តមគតិហើយមនុស្សដែលជាគំរូរបស់គេនៅពេលនេះមិនមែនគ្រូរបស់គេតែមួយគត់

ទៀតនោះទេ។ កាលនៅមត្តេយ្យសិក្សា និងបឋមសិក្សា គ្រូជាជនគំរូរបស់កុមារ ជាមនុស្សដែលល្អជាងគេចំពោះពួកគេ។ តែមកដល់ពេលនេះ នៅមធ្យមសិក្សាជនគំរូសម្រាប់ជំទង់ គឺមនុស្សពិតៗដូចជាតួអង្គនៅក្នុងប្រលោមលោកក្នុងខ្សែភាពយន្ត អ្នកចម្រៀង ឬតួចម្រៀងកាយវិការ ឬកីឡាករជើងឯកដែលជាជនគំរូសម្រាប់ពួកគេឯណោះវិញទេ។ ពេលណាគេអានរឿងប្រលោមលោក ឬមើលខ្សែភាពយន្ត ឬវីដេអូ ហើយជួបនឹងវីរភាពតួអង្គណាមួយគេនឹងស្ងើចសរសើរដល់វីរជននោះហើយគេចង់ធ្វើខ្លួនឱ្យទៅជាវីរជន។ដូចនេះគ្រូត្រូវជួយជំទង់ឱ្យបណ្ដុះបណ្ដាលឧត្តមគតិនៃជីវិត។

វ័យជំទង់ជាវ័យដែលអនុគ្រោះបំផុតដល់ការសិក្សាព្រោះសមត្ថភាពបញ្ញារបស់គេនៅពេលនេះមានការរីកចម្រើនខ្លាំងក្លា ពិសេសគឺ «ការគិតអរូបី»។ គ្រូត្រូវបណ្ដុះឧត្តមគតិដល់ជំទង់ ដើម្បីឱ្យគេយល់តម្លៃក្នុងឆាកជីវិត ព្រោះថាវ័យនេះការស្រមើស្រមៃ និងឧត្តមគតិមិនទាន់មានស្ថិរភាពនៅឡើយទេ ហើយអាចមានការប្រែប្រួលយ៉ាងឆាប់រហ័សផង។ ពេលនេះជំទង់ចង់ឃើញ ចង់ដឹង ចង់ពិចារណា ចង់ពិភាក្សា ចង់វែកញែក ចង់យកឈ្នះ ទោះបីជាសកម្មភាពខ្លះជាការខុសឆ្គងក៏ដោយ។ កម្មវត្ថុនៃការសិក្សាមានភាពទូលំទូលាយ អាចឱ្យជំទង់ធ្វើការស្វែងយល់ និងមានការពិភាក្សាទៅលើបញ្ហាសង្គមទៀតផង។

**ឧទាហរណ៍៖** ជំទង់អាចពិភាក្សាទៅលើ “បុគ្គលនិយម” និង “សមូហភាព”។

ក្រៅពីចរិតលក្ខណៈខាងលើ ជំទង់មានលក្ខណៈគួរឱ្យកត់សម្គាល់ជាងគេ គឺអំណះអំណាងបុគ្គលិកលក្ខណៈដែលជាតម្រូវការចាំបាច់មួយរបស់ជំទង់។ តម្រូវការនោះសម្ដែងចេញក្នុងទំនាក់ទំនង សង្គម។

**២-ទំនាក់ទំនងជាមួយសង្គម**

### *ក.ទំនាក់ទំនងជាមួយមនុស្សពេញវ័យ*

- **ជាមួយគ្រួសារ៖** នៅក្នុងគ្រួសារ ឪពុកម្ដាយ ឬបងប្រុសស្រីមិនត្រូវចាត់ទុកជំទង់ជាក្មេងទៀតទេ។ គេត្រូវផ្ដល់សេរីភាព និងភាពឯករាជ្យដល់ជំទង់ខ្លះ និងប្រគល់កិច្ចការណាដែលធំដុំដល់គេផង។ ជំទង់ទាមទារសេរីភាព និងភាពម្ចាស់ការ និងភាពស្វ័យសម្រេចលើអ្វីៗដោយខ្លួនគេផ្ទាល់។ មាតាបិតា ឬបងប្រុសស្រីត្រូវប្រគល់ភារកិច្ចឱ្យគេទទួលខុសត្រូវនូវកិច្ចការណាថ្នូនល្មមដោយធ្វើការតាមដានសកម្មភាពជំទង់ឱ្យបានដិតដល់ផង។ ជំទង់ពេលនេះ ចេះធ្វើឱ្យឪពុកម្ដាយមានទំនុកចិត្តលើគេបានខ្លះហើយ។ ជំទង់មិនចង់ឱ្យអ្នកណាចាត់ទុកគេដូចក្មេងទៀតទេ។ ការថ្នាក់ថ្នម ការលួងលោមរបស់ឪពុកម្ដាយធ្វើឱ្យគេធុញទ្រាន់ក្នុងពេលខ្លះ តែគេចង់ឱ្យឪពុកម្ដាយគេគោរពសិទ្ធិគេវិញ ដូចជាការផ្ដល់សេរីភាពដល់ពួកគេ។ ក្នុងករណីដែលបុគ្គលិកលក្ខណៈរបស់គេមិនត្រូវបានគោរពនោះ ជំទង់នឹងបង្កជម្លោះជាមួយអ្នកនោះ ពិសេសជាមួយមនុស្សពេញវ័យ។
- **ជាមួយគ្រូ៖** ជាការពិតហើយថា ក្នុងដំណាក់នេះ ជំទង់តែងតែគិតថា គ្រូជាអ្នកផ្ដល់ចំណេះដឹងដល់ពួកគេ ហើយគ្រប់អាកប្បកិរិយារបស់គ្រូធ្វើឱ្យគេគោរព។ តែគ្រូមិនមែនជាជនគំរូ

ដូចកាលគេនៅបឋមសិក្សានោះទៀតទេ។ គេគោរពគ្រូក្នុងនាមជាអ្នកអប់រំ អ្នកបង្ហាត់បង្រៀន មុខវិជ្ជាសិក្សាប៉ុណ្ណោះ។ តែជាទូទៅជំទង់តែងតែមានចរិតគោរពស្រឡាញ់គ្រូ។

- **ជាមួយមតិសាធារណៈ៖** ជំទង់ចាប់អារម្មណ៍ណាស់ចំពោះការទិតៀន និងការវាយតម្លៃពីមតិសាធារណៈ។ ជំទង់ចង់បានការសរសើរពីអ្នកដទៃ តែគេខ្លាចការទិតៀនពីអ្នកដទៃ ផ្ទុយទៅវិញគេហ៊ានទិតៀនអ្នកដទៃយ៉ាងខ្លាំងក្លារហូតហ៊ានបង្កជម្លោះផង។ គេចូលចិត្តត្រាប់តាមមនុស្សធំ គេចង់ដឹងរឿងមនុស្សធំ ពិសេសទំនាក់ទំនងរវាងបុរស និងនារី តែជំទង់ហាក់ដូចជាមិនទាន់អើពើនៅឡើយ។

ជំទង់ប្រាថ្នាចង់ឱ្យបានដូចលក្ខខណ្ឌមនុស្សពេញវ័យ "គេចង់ក្លាយជាមនុស្សពេញវ័យ"។ ហេតុនេះហើយបានជាជំទង់ចូលចិត្តប្រណាំងប្រជែងជាមួយមនុស្សពេញវ័យ។ជំទង់ចង់យកឈ្នះអ្នកដទៃណាស់។ ពិសេសជំទង់ចង់បញ្ជាទៅកុមារក្នុងឋានៈគេជារៀមច្បង។ ជានិច្ចកាលជំទង់ចៀសវាងសកម្មភាពណាដែលឡូកឡំជាមួយកុមារ។

(នៅមានត)

*ដោយលោក* ***ជ័យ សយ្យនា***

*ដកស្រង់ពីឯកសារនាយកដ្ឋានបណ្ដុះបណ្ដាល*

**តើពាក្យ «រំលឹក, រម្លឹក, រំឭក» មួយណាត្រឹមត្រូវ?**

*ពាក្យសរសេរជាព្យាង្គរាយ រំលឹក, ជាព្យាង្គតម្រួត រម្លឹក, ឬសរសេរជាស្រៈពេញតួ រំឭក តាមវចនានុក្រមសម្ដេច* ***ជួន ណាត*** *បញ្ជាក់ថា ពាក្យនេះត្រឹមត្រូវទាំងបី អាចប្រើជំនួសគ្នាបាន មានន័យថា ធ្វើឲ្យរលឹកឃើញ ធ្វើឲ្យនឹកឃើញ ឲ្យភ្ញាក់ស្មារតី ឲ្យចាំឡើងវិញ។*

# មាតាបិតាពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុក តែជាអ្នកនាំផ្លូវថ្នល់សម្រាប់បុត្រធីតា (ត)

ប្រសិនបើអាចដើរនិយាយបែបនេះបាន ចុះហេតុម្ដេចបានជាមិននិយាយថា៖

-កូនមួយនេះខ្ញុំស្ដីថាមិនបាន ពិបាកណែនាំណាស់!

-សូមប្អូន បង អ៊ំ ពូ មីង តាយាយ ជួយស្ដី ជួយថា ឱ្យកូនខ្ញុំផង!

-បើឃើញកូនខ្ញុំមួយនេះធ្វើអ្វីមិនគប្បី សូមប្រាប់ខ្ញុំផង!

-តើឱ្យខ្ញុំធ្វើយ៉ាងណា? បើកូនហ្នឹងវាអ៊ីចឹង...។ល។

លូង់ខ្លៅត្រូវតែសួរ ពាក្យឱ្យគួរកុំឱ្យស៊ុន

យកពាក្យផ្អែមជាមុន ទន់លំទោនឱនប្រតិបត្តិ។

(ក្រមង៉ុយច្បាប់កេរកាលថ្មី)

សូមស្វែងយល់សុភាសិតបុរាណខ្មែរថា **សម្លច្រើនគ្រឿង ច្រើនពិសា កូនច្រើនបាច្រើនល្អ។** ស្ដាប់គេឱ្យបានច្រើន និងវិភាគឱ្យបានជាប្រចាំ។នៅមានពាក្យសមគួរជាច្រើនទៀតដូចជាអរគុណណាស់ដែលបានប្រាប់ខ្ញុំ ជួយខ្ញុំ ផ្ដល់គំនិតល្អៗ បើកុំតែបានអ្នក ឬពូ... ខ្ញុំពុំដឹងធ្វើយ៉ាងម៉េចទេ ។ល។ តើអ្នកមានខូចខាតអ្វីខ្លះដែរ?

សុភាសិតខ្មែរថា **«ដើយស្អុក ឱនដាក់គ្រាប់»** វាហាក់បីដូចជាអន់បន្តិចមែន តែទទួលបាននូវសម្ដីពិត គំនិតពិត ចិត្តស្មោះត្រង់ ពីមជ្ឈដ្ឋានជុំវិញខ្លួន។ ឯការខូចខាតគឺកើតមានចំពោះតែការប្រកាន់ចិត្តអស្មិមានះតាំងខ្លួនគ្រាន់បើ។ ពេលញាតិបានស្ដាប់ហើយ គេយល់ គេដឹង អំពីសេចក្ដីអគតិរបស់យើង គេមិនហ៊ានផ្ដល់គំនិត គេធ្វើពើជារាប់អានធម្មតាក្នុងប្រយោជន៍ណាមួយរបស់គេតែប៉ុណ្ណោះ ឬអាចថាបញ្ជោរបោកស៊ី ចំណែកអ្នកវិញគ្មានបានអ្វីពីគេ ក្រៅពីការលួចរិះគន់ ឬខ្លួនឯងបានត្រឹមតែពោលនៅក្នុងចិត្តថា ជាតិក្រោយសុំកុំជួបបែបនេះឱ្យសោះ។

អំពើវាយដំត្រូវសង្គមស៊ីវិល័យស្អប់ខ្ពើមនិងច្បាប់ហាមឃាត់។ សូមលោកអ្នកស្វែងយល់អំពីច្បាប់សង្គមផង តើមានទោសទណ្ឌកម្រិតណាខ្លះក្នុងការធ្វើទារុណកម្មកូន ឬអំពើហិង្សាក្នុងគ្រួសារ?

### ១.៤ អំពីពាក្យសម្ដីអហិង្សា

ថ្វីបើក្នុងលោកយើងនេះមិនអាចអត់បាននូវភាពហិង្សាក៏ពិតមែន ប៉ុន្តែជីវិតសុខសាន្តមានតម្រូវការច្រើននិងចាំបាច់បំផុតនោះគឺភាពអហិង្សាពិសេសសម្រាប់ក្នុងគ្រួសារនេះតែម្ដង។ គ្រួសារមួយមានទំនាក់ទំនងគ្នាជាប្រចាំថ្ងៃ ដោយពាក្យសម្ដីរួសរាយរាក់ទាក់គ្នា រវាងមាតាបិតា បុត្រធីតា ជីដូនជីតា ចៅ ឬចៅទួត ស្គាល់ទាប ស្គាល់ខ្ពស់ កុំអាងបុណ្យស័ក្តិ មាសប្រាក់លុយឡាន ប្អូនត្រូវគោរពបង បងត្រូវយល់អំពីប្អូន បានន័យថា គ្រួសារនេះកំពុងអនុវត្តមូលដ្ឋានគ្រឹះនៃទង្វើអហិង្សា។

គ្មានពាក្យសម្ដី**ហិង្សា** វាត្រូវតែលេចចេញនូវពាក្យសម្ដី**អហិង្សា**ជាវិជ្ជមាន។ គ្មានសម្ដី**គ្រោតគ្រាត** វាត្រូវតែលេចចេញនូវពាក្យសម្ដី**ផ្អែមល្ហែម។** កាលបើភាពស្និទ្ធស្នាលកើតឡើងហើយ វាត្រូវតែរលុបបាត់បញ្ហាប្រទូស្ដរ៉ាយនិងបានផុសចេញឡើងនូវកិត្តិយសមួយដែលគេគ្រប់គ្នាកោតសរសើររាប់អានថាជាគ្រួសារសុភមង្គល បានន័យថា ផ្លូវចិត្តក៏សុខ សេដ្ឋកិច្ចក៏ចម្រើនឡើងកិត្តិយសក៏ថ្កុំថ្កើង។

-អហិង្សា (ន.)(សំ.),(បា)(អៈហិង-សា ឬអៈហេ...)(អហឹសា ឬអហេសា) ការមិនបៀតបៀនគេ,ការមិនធ្វើទុក្ខគេឱ្យបានសេចក្ដីលំបាក, ការមិនធ្វើទុក្ខបុកម្នេញគេៈ*មនុស្សត្រូវប្រើសត្វពាហនៈដោយអហិង្សា, ប្រសិនបើសត្វលោកទាំងអស់មានអហេសាដូចគ្នា ក្នុងសកលលោកសមនឹងបរិបូណ៌ដោយសេចក្ដីសុខសម្រាន្តយ៉ាងក្រៃលែង។ វេវ.អវិហិង្សា, អវិហេសា។ ព.ផ្ទ.ហិង្សា, វិហិង្សា, វិហេសា។ ព.កា.ប្រាប់ផលអហិង្សាៈ អហិង្សាជាធម៌ដ៏សំខាន់ ប្រសិនបើកាន់បានគ្រប់គ្នា សមលោកទាំងមូលនឹងសះជា ការឈ្លោះទាស់គ្នាក៏នឹងគ្មាន។ ព្រោះអហិង្សាជាធម៌ស្ងប់ ឱ្យរាប់ឱ្យរកគ្នារាល់ប្រាណ អាចនាំឱ្យមានសុខក្សេមក្សាន្ត ធ្វើម្ដេចនឹងបានដូចថាអើយ។ ប្រសិនបើអាចប្រជុំគ្នាទូទាំងលោកាពុំកន្តើយ ជជែកប្រឹក្សារកកោះត្រើយ បើបានឃើញហើយព្រមកាន់តាម។ ឱ្យអហិង្សាមានរាល់ទ្វីប ភ្លឺដូចប្រទីបនៃលោកភ្លាម នោះលោកទាំងមូលនឹងមាននាម ថាបានរួចផុតចាកហិង្សា។(ល)*។ (ប្រទីបនៃលោកគឺព្រះអាទិត្យ)។ អហឹសា,អហេសា (វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត** បោះពុម្ពចម្លងឆ្នាំ១៩៨១ ដោយលោកស្រីយ៉ាម៉ាដាបូផាណា ទំព័រ១៧០៥)។

តើនឹងមានប្រយោជន៍អ្វីខ្លះ ដែលគួរប្រើជាចាំបាច់នូវពាក្យសម្ដីអហិង្សា? យើងប្រាកដជាក់ណាស់គឺដូចគ្នាទាំងអស់ រមែងចង់បានសុភមង្គលក្នុងជីវិតគ្រួសារផ្ទាល់។ មើលចុះ! អាចារ្យឱ្យពរជ័យសិរីមង្គលឯអ្នកម្ដាយ និងលោកឪពុក ថ្នាក់ថ្នមបមបីកូនកាលនៅតូច ក៏ពីព្រោះតែអ្វី?

(នៅមានត)

*ដោយលោក* **ផេង កែន**

*ប្រធានការិ.រដ្ឋបាលមន្ទីរអ.យ.ក.ខេត្តកំពង់ឆ្នាំង*

*កុំថ្កោលទោសគេពុំពិនិត្យ*
*កុំធ្វេសប្រហែសពាក្យសម្ដី*
*កុំគិតខ្លួនឯងថាប្រពៃ*
*នាំឲ្យមានភ័យដល់អាត្មា។*

*ព្រះសង្ឃរាជ* **ជួន ណាត**




## របៀបវិធីផ្ទាល់ខ្លួនរបស់គ្រូក្នុងការបង្រៀន (តចប់)

៨.ការអានម៉ោងជាភាសាអង់គ្លេស

ឧទាហរណ៍៖

-It is five to ten (5 to 10) →ម៉ោងដប់ខ្វះប្រាំនាទី - It is five past ten (5 past 10) →ម៉ោងដប់និងប្រាំនាទី





គេអាចរកពាក្យជូនជាភាសាខ្មែរដើម្បីឱ្យសិស្សងាយចាំ និងចូលចិត្តទន្ទេញសូត្រលេង គឺគេថា To ខ្វះ Past លើស ខ្វះជូននឹង Past។

**៩.ខែទាំង ១២ តាមសូរិយគតិនៃឆ្នាំ**ខែខ្លះមាន ២៨-២៩-៣០ និង៣១ថ្ងៃ។ បើគិតតាមលេខរៀងនៃខែឃើញថា ខែខ្លះលេខសេស ខែខ្លះលេខគូ។

| ***<u>ខែសេស</u>*** | ***<u>ខែគូ</u>*** |
|---|---|
| ខែ ១ = ៣១ ថ្ងៃ | ខែ ២ = ២៨ ឬ ២៩ថ្ងៃ |
| ខែ ៣ = ៣១ ថ្ងៃ | ខែ ៤ = ៣០ ថ្ងៃ |
| ខែ ៥ = ៣១ ថ្ងៃ | ខែ ៦ = ៣០ ថ្ងៃ |
| ខែ ៧ = ៣១ ថ្ងៃ | ខែ ៨ = ៣១ ថ្ងៃ |
| ខែ ៩ = ៣០ ថ្ងៃ | ខែ ១០ = ៣១ ថ្ងៃ |
| ខែ ១១ = ៣០ ថ្ងៃ | ខែ ១២ = ៣១ ថ្ងៃ |

តាមរយៈឯកសារសាស្ត្រាចារ្យ និងគ្រូបង្រៀនមុនបានប្រាប់ និងបង្រៀនថា គេអាចចាំបាន ខែណាមាន៣០ថ្ងៃ ឬ៣១ថ្ងៃ លើកលែងតែខែកុម្ភៈ ដែលមាន ២៨ ឬ២៩ថ្ងៃ តាមការរាប់គល់ម្រាម ខាងខ្នងដៃ តែការរាប់របៀបនេះហាក់ដូចជាយូរជាងការចាំនូវឃ្លាមួយដូចខាងក្រោមៈ

ខែសេស ៣១ ចូរអ្នកប្រឹងជួយមួយ (1) ដល់ប្រាំពីរ (7) ហើយខំសម្ដី ក្រោយខែប្រាំពីរ (7) គឺ ខែគូវិញ។

បានន័យថាខែសេសរាប់ពីខែ ១ ដល់ ខែ ៧ មានខែ១ ខែ៣ ខែ៥ និងខែ៧ មាន៣១ថ្ងៃ។ ក្រោយខែ៧ គឺខែគូវិញដែលមាន៣១ថ្ងៃដែរ គឺខែ៨ ខែ១០ និងខែ១២។

ឧទាហរណ៍ ដូចបានរៀបរាប់ជូនទាំង ៩ ចំណុចមកនេះគ្រាន់តែជាគំរូនៃរបៀប ឬវិធីផ្ទាល់ខ្លួនរបស់គ្រូ ដើម្បីធ្វើយ៉ាងណាមិនឱ្យសិស្សធុញទ្រាន់ គឺសិស្សចូលចិត្តត្រងត្រាប់ចាប់យកទុកក្នុងខួរក្បាលបានយូរអង្វែង។ លោកគ្រូ អ្នកគ្រូ អាចរកនឹកបង្កើតតាមរបៀប ឬវិធីផ្ទាល់ខ្លួនក្នុងការបង្រៀនមុខវិជ្ជាផ្សេងៗក្នុងអាជីពរបស់ខ្លួន។

លោកគ្រូ អ្នកគ្រូ ដែលប្រើរបៀប ឬវិធីដោយខ្លួនឯងដូចឧទាហរណ៍ខាងលើនេះ ត្រូវតែច្បាស់លាស់បំផុត មានការយកចិត្តទុកដាក់ខ្ពស់ គឺមុននឹងយកពាក្យ ឬឃ្លាអ្វីមកបង្ហាញ ដើម្បីភ្ញោចបម្រុងប្រយ័ត្នរបស់សិស្ស លោកគ្រូ អ្នកគ្រូត្រូវផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវនូវអក្ខរាវិរុទ្ធក្នុងវចនានុក្រមជៀសវាងការភ័ន្តច្រឡំ សរសេរខុស។ បើពុំនោះទេ វានឹងក្លាយទៅជាកាំបិតមុខពីរធ្វើឱ្យសិស្សចាំនូវពាក្យខុសនោះអស់មួយជីវិតក៏ថាបាន៕

*លោក* **គិម ប៊ុនសាន**

*អតីតអនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអ.យ.ក*

**<u>សំណួរល្បងប្រាជ្ញា</u>**

*១.ខ្ញុំមានលេខ ៨ ចំនួន៨។ តើខ្ញុំត្រូវតម្រៀបវាយ៉ាងណា «បូក សង គុណ ចែក» ដើម្បីអោយបានផលបូកស្មើនឹង១០០០។*

*២.ខ្ញុំមានលេខ ៥ ចំនួន ៥។ តើខ្ញុំត្រូវតម្រៀបវាយ៉ាងណា «បូក សង គុណ ចែក» ដើម្បីអោយបានផលបូកស្មើនឹង១០០០។*

*ដោយ* **រត្ន ហ្វូត**

*អតីតនាយករងវិទ្យាស្ថានជាតិអប់រំ*

(ចម្លើយមាននៅទំព័រទី១៧)

# កត្តាជាច្រើនធ្វើឱ្យអ្នកសិក្សាសម្រេចគោលដៅ

ជាការពិតណាស់ នៅលើលោកយើងនេះគ្រប់ជាតិសាសន៍ទាំងអស់រមែងទទួលការអប់រំតាំងពីកុមារភាពរហូតដល់ជាមនុស្សពេញវ័យដើម្បីមានគោលដៅក្នុងជីវិតរបស់គេម្នាក់ៗ។ ក្នុងការសិក្សាដែលជាប្រភពចំណីនៃប្រាជ្ញារបស់មនុស្សនោះ លុះត្រាតែមានកត្តាជាច្រើនដែលជំរុញអ្នកសិក្សាឱ្យឈានដល់គោលដៅរបស់គេ ដើម្បីអនាគត គេអាចជួយខ្លួនឯង គ្រួសារ និងសង្គមជាតិទាំងមូលផង។

តាមការពិនិត្យសង្កេតក្នុងអតីតកាលក៏ដូចបច្ចុប្បន្នកាលដែលអ្នកសិក្សាតែងតែមានកត្តាជាច្រើនជួយជំរុញដំណើរការសិក្សាឱ្យមានភាពរលូនទៅបានពោលគឺតាំងពីមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា។

**កត្តាគ្រួសារៈ** គឺជាគ្រឹះដំបូងដែលជាអ្នកផ្ទុងផ្ដើមឱ្យបុត្រធីតារបស់ផងខ្លួនបានចូលរៀនថ្នាក់មត្តេយ្យតាំងពីអាយុ៤ឬ៥ឆ្នាំម្ល៉េះ។ កត្តាគ្រួសារនេះហើយដែលឱ្យកុមារកក់ក្ដៅក្នុងចិត្តរបស់គេដែល មានឪពុកម្ដាយ ឬអាណាព្យាបាលបាននាំគេដំបូងទៅចុះឈ្មោះចូលរៀន បានស្គាល់សាលាគ្រូ មិត្តភក្ដិ។ល។ នេះជាអនុស្សាវរីយ៍លើកដំបូងនៃជីវិតកុមារ។ បើគ្រួសារបានផ្ដល់ឱកាសគ្រប់គ្រាន់ដល់កូនក្នុងការស្វ័យ សិក្សាបន្ថែមនៅផ្ទះ ឬជួយបង្រៀនបន្ថែម ក៏ដូចជាជួយជំរុញដាស់តឿនឱ្យខំរៀនដោយផ្ដល់កម្លាំងចិត្ត និងសម្ភារថវិកានោះជាការលើកទឹកចិត្តមួយកម្រិតទៀត ។ កត្តាគ្រួសារនេះបើគ្រួសារប្រកបដោយអ្នកចេះដឹង ច្រើនមានសីលធម៌រស់នៅល្អទៀតនោះ ក៏ជាគំរូមួយដ៏ល្អជួយដល់អារម្មណ៍របស់គេដែរ។

**កត្តាខ្លួនឯងៈ** គឺជាចំណែកមួយទៀតដែលអ្នកសិក្សាមិនអាចខ្វះបាននោះ គឺការព្យាយាមសង្វាតទាំងនៅសាលារៀនក្ដី នៅផ្ទះក្ដី ពោលគឺមានចិត្តស្រឡាញ់ការសិក្សា ចេះកំណត់គោលដៅរបស់ខ្លួន។ នៅសាលារៀនគឺកុមារទាំងថ្នាក់ទាបរហូតថ្នាក់ខ្ពស់ត្រូវចេះប្រើសុ.ចិ.បុ.លិ ទាំង៤នេះជាប្រចាំ។ ពួកគេមិនត្រូវចាំតែរៀនពីគ្រូប៉ុណ្ណោះទេ គេថែមទាំងរៀនពីមិត្តភក្ដិពូកែៗ ឬអានក្នុងបណ្ណាល័យ។ ចំណែកកិច្ចការផ្ទះដែលគ្រូដាក់ឱ្យ គឺត្រូវបំពេញឱ្យខាងតែបាន។ កត្តាខ្លួនឯងនេះបើអ្នកសិក្សាបានដល់ថ្នាក់មធ្យមសិក្សាទុតិយភូមិ គេរឹតតែមានគោលដៅជាក់លាក់តាមរយៈការសិក្សាមុខវិជ្ជាឯកទេសណាដែលខ្លាំងជាងគេ។ ការមិនឈប់ញឹកញាប់ឬគេចដើរលេងនោះ វាជាផ្នែកមួយនៃការសិក្សាឈានទៅរកគោលដៅរបស់គេដែរ។ កត្តាខ្លួនឯងនេះមតិខ្លះលើកពីតំណពូជផងដែរ កត្តាតំណពូជនេះបើពិនិត្យទៅឃើញថា ត្រឹមត្រូវខ្លះៗដែរ ប្រហែល៧០%។

**កត្តាសាលារៀន គ្រូ៖** គឺជាផ្នែកមួយមិនអាចខ្វះបាន គឺដើរតួនាទីសំខាន់ណាស់ សាលារៀនល្អ ឬជាសាលាកុមារមេត្រី ជាផ្នែកមួយដែលទាក់ទាញអារម្មណ៍សិស្សទូទៅឱ្យស្រលាញ់ចង់មករៀនមិនអវត្តមាន។ គួបផ្សំលោកគ្រូអ្នកគ្រូមានឆន្ទៈ បទពិសោធន៍ គរុកោសល្យ វិធីសាស្ត្រទំនើបទៀត ក៏រឹតតែញ៉ាំងឱ្យសិស្សស្រលាញ់ការសិក្សាថែមទៀត។ពិសេសគ្រូមានការអប់រំផ្នែកសីលធម៌ស្របតាមមុខវិជ្ជាដូចជាសិក្សាសង្គម។ល។ ហើយវិធីសាស្ត្រមិនចេះរីងស្ងួតនោះ គឺការប្រើល្បែងសិក្សាក្នុងថ្នាក់រៀនទាក់ទាញអារម្មណ៍សិស្សឱ្យសប្បាយផង។ ជាងនេះទៅទៀត បើគ្រូមានការត្រៀមលក្ខណៈដាក់កិច្ចការផ្ទះជាប្រចាំ ព្រមទាំងពិនិត្យកិច្ចការនោះវិញ រឹតតែធ្វើឱ្យកុមារឬសិស្សមានការរីកចម្រើនលើចំណេះដឹងធំទូលាយទៀត។

**កត្តាសង្គម៖** គឺជាកត្តាដែលជំរុញឱ្យកុមារឬសិស្សទទួលយកជាងកត្តារបស់សាលារៀន និងគ្រូទៅទៀត។ បើសង្គមពោរពេញដោយភាពឆើតឆាយ ស៊ីវិល័យ ទំនើប ទាំងសម្ភារៈនោះក៏ជាកត្តាជះឥទ្ធិពលដល់សិស្សដែរ។ បើសង្គមមានស្ថេរភាព សុវត្ថិភាព ពុំមានផលរមាស់អ្វីទេនោះ អារម្មណ៍កុមារ សិស្សទូទៅសប្បាយ និងទទួលយកការសិក្សាប្រកបដោយស្ថេរភាព។

យោងតាមកត្តាទាំងឡាយដូចខាងលើនេះ បើមានដំណើរព្រមគ្នាទំនាក់ទំនងបំពេញឱ្យគ្នាទៅវិញទៅមកនោះ គេសង្ឃឹមថា អ្នកសិក្សាទាំងឡាយរមែងឈានទៅរកគោលដៅពិតប្រាកដ នៅពេលគេពេញវ័យក្លាយជាពលរដ្ឋពេញលេញជួយខ្លួនឯង គ្រួសារ សង្គមជាតិមិនខានឡើយ៕

*លោក* **ធីវ ពេកជីវសុជម្ម**

*សាលាប.ប.សដំរីយកទឹក ស្រុកសំរោង ខេត្តតាកែវ*

**ចម្លើយពីទំព័រទី១៥**

| | |
|---|---|
| ១/. ៨៨៨ | ២/. ៩៩៩ + ៩/៩ = ១០០០ |
| ៨៨ | |
| + ៨ | |
| ៨ | (បើរកឃើញ១៖ ជោគជ័យ |
| ៨ | បើរកឃើញ២៖ អច្ឆរិយៈ) |
| ១០០០ | |

# សាលាធនធានជួយបង្កើនគុណភាពអប់រំនៅកម្ពុជា (តចប់)

- តម្រូវការមួយចំនួនរបស់គ្រូវិទ្យាសាស្ត្រនៅតាមសាលាធនធានក្នុងខេត្តកំពង់ចាម កំពង់ធំ បាត់ដំបង និងខេត្តព្រះវិហារ គឺតម្រូវការឱ្យមានសម្ភារឧបទេស និងសៀវភៅគោលសម្រាប់គ្រូ ដែលជាផ្នែកមួយជំនួយស្មារតី គឺសម្រាប់ការបង្រៀន និងការពិសោធឱ្យបានគ្រប់មេរៀន ហើយបន្ទប់ពិសោធន៍ក៏ខ្វះខាតវត្ថុធាតុដើមសម្រាប់ពិសោធ។ ការបណ្តុះបណ្តាល គឺត្រូវបណ្តុះបណ្តាលឱ្យចំគោលដៅ និងបំពាក់នូវកុំព្យូទ័របន្ថែមទៀត វានៅមិនទាន់គ្រប់គ្រាន់តាមតម្រូវការសិស្សហើយការខ្វះខាតគ្រូវិទ្យាសាស្ត្រឯកទេសទី១ ដែលមានជំនាញខាងពិសោធ គឺមានតែគ្រូ ២ ឬ៣នាក់ប៉ុណ្ណោះ នេះជាប្រការមួយដែលនាំឱ្យដំណើរការនៃការពិសោធមិនបានគ្រប់គ្រាន់។ ម្យ៉ាងទៀតលោកគ្រូ អ្នកគ្រូខ្លះមិនទាន់បានស៊ីជម្រៅលើខ្លឹមសារមេរៀនប្រចាំថ្ងៃនៅឡើយដែលជាហេតុនាំឱ្យការអនុវត្តការពិសោធមានការពិបាក។ ចំពោះវិទ្យាល័យបណ្តាញមានចម្ងាយផ្លូវឆ្ងាយពីអគារធនធានគោល ដែលជាប្រការមួយនាំឱ្យគ្រូមិនអាចធ្វើដំណើរទៅចូលរួមបាន ឬប្រជុំនៅអគារធនធាននោះបានទេ កត្តាទាំងនេះ បានបណ្តាលឱ្យការបណ្តុះបណ្តាលមុខវិជ្ជាវិទ្យាសាស្ត្រដល់សិស្សមិនបានល្អ។ចំពោះអគារធនធាននៅខេត្តបាត់ដំបងវិញ លោកគ្រូអ្នកគ្រូវិទ្យាសាស្ត្រទាមទារឱ្យមានការបណ្តុះបណ្តាលកម្រិតជំនាញសម្រាប់គ្រូវិទ្យាសាស្ត្រ ទាំងសមត្ថភាព ឯកទេស វិធីសាស្ត្របង្រៀន ការផលិតសម្ភារឧបទេស ពិសេសជំនាញពិសោធន៍ក្នុងអគារធនធានឱ្យបានញឹកញាប់ក្នុងរយៈពេល១ឆ្នាំ១ ដើម្បីពង្រឹងគុណភាព និងសមត្ថភាពគ្រូវិទ្យាសាស្ត្រ និងពន្យល់ដល់គ្រូ និងសិស្សឱ្យស្គាល់ពីអត្ថប្រយោជន៍នៃការពិសោធ សម្រាប់ប្រើប្រាស់ក្នុងសង្គម ជាពិសេសអភិវឌ្ឍប្រទេសជាតិបច្ចុប្បន្ន។

សកម្មភាពសិស្សវិទ្យាល័យ ជា ស៊ីម ត្បែងមានជ័យ សិក្សាក្នុងអគារធនធាន (២០១៣) ចំពោះអគារធនធានក្នុងខេត្តព្រះវិហារ (វិទ្យាល័យ ជា ស៊ីម ត្បែងមានជ័យ) គឺប្រឈមបញ្ហាមួយចំនួនដូចជា ករណីកង្វះខាតគ្រូវិទ្យាសាស្ត្រ សមត្ថភាពគ្រូមិនឆ្លើយតបនឹងសកម្មភាពពិសោធន៍ព្រោះភាគច្រើនជាគ្រូកម្រិតមូលដ្ឋាន។ ជាមួយគ្នានេះ ត្រូវមានអធិការកិច្ចជំនាញចុះវាយតម្លៃ និងបណ្តុះបណ្តាលឱ្យបានត្រឹមត្រូវតាមស្តង់ដារព្រមទាំងមានគ្រូបង្គោលសម្រាប់វិទ្យាល័យអគារធនធាន ក្នុងនោះគ្រូត្រូវណែនាំពីប្រភេទសម្ភារៈពិសោធន៍ របៀបប្រើប្រាស់ ព្រមទាំងការអនុវត្តជាក់ស្តែង។ ចំណែកឯសៀវភៅគ្រូវិញ ត្រូវមានរូបភាពទាក់ទងជាមួយការពិសោធ ព្រមទាំងផលិតជា VIDEO, CD, VCD ទុកសម្រាប់សិក្សាក្នុងករណីមានចម្ងល់ ហើយការប្រជុំបច្ចេកទេសទាំងក្នុងវិទ្យាល័យ និងសាលាបណ្តាញក្នុងគោលបំណងប្តូរចំណេះដឹង ហើយក៏ទាមទារឱ្យមានការកសាងអគារធនធានបន្ថែមទៀត ចំពោះវិទ្យាល័យដែលនៅដាច់ឆ្ងាយពីអគារធនធានគោល។

ដូច្នេះ គោលនយោបាយស្ដីពីសាលាធនធាន និងសកម្មភាពរបស់វាពិតជាមានសារៈសំខាន់ណាស់សម្រាប់បណ្ដុះបណ្ដាលសិស្សនៅមធ្យមសិក្សាចំណេះទូទៅដើម្បីប្រែក្លាយឱ្យទៅជាពលរដ្ឋជំនាញ អ្នកវិទ្យាសាស្ត្រវ័យក្មេង។ ពោលគឺគុណភាពអប់រំនៅមធ្យមសិក្សាចំណេះទូទៅស្របតាមកំណើនសេដ្ឋកិច្ច បច្ចេកវិទ្យាក្នុងយុគសម័យសាកលភាវូបនីយកម្ម ដែលអាចប្រកួតប្រជែងធនធានមនុស្សក្នុងសហគមន៍អាស៊ាន។ ប៉ុន្តែភាពជោគជ័យនេះអាស្រ័យលើការដោះស្រាយបញ្ហាប្រឈមមួយចំនួនបានល្អ៕

*លោក* **គួយ សុគាន**

## ក្លិនប្រហុកខ្មែរ

ឈ្ងុយប្រហើរ
ក្លិនវិលវល់
ទោះទៅរស់
ក៏ឆ្លេឆ្លា
មិនក្រអូប
ឈ្ងុយជាប់ចាន
បើចំហុយ
នេះគឺក្លិន
ក្លិនថ្ងូតថ្ងាប
ក្លិនគ្មានពីរ
ក្លិនបរិសុទ្ធ
ក្លិនហានក្លា

ដើររាយអាយ
ខ្យល់ជាប់ជាតិ
ដល់ក្រហែង
ប្រាថ្នាជួប
តែខានស្រូប
ចង្ក្រានឆ្នាំង
ក្លិនឈ្ងុយជាប់
ប្រហុកខ្មែរ
លាបជីវិត
ក្លិនសាមគ្គី
មោះមុតក្នុង
ស្លាបនាប្រា-

ភាយទៅដល់
ច្រៀតនាសា
ដើងមេឃណា
ចង់បានក្លិន ។
ក៏មិនបាន
ទាំងឆៅឆ្អិន
ក្នុងសុបិន្ត
កេរ្តិ៍ជូនតា ។
ប្រពៃណី
ជាតិខេមរា
ពង្សាវតា
សាទអង្គរ៕

**គង់ ប៊ុនឈឿន**

# ពិសោធប្រើប្រដាប់លេង និងសម្ភារឧបទេស សម្រាប់អប់រំបុត្រធីតា និងសិស្ស

មនុស្សលោកយើងមានចំណង់ច្រើនប្រការណាស់ដើម្បីជាសុភមង្គលដល់ខ្លួនផ្ទាល់ដល់គ្រួសារនិងដល់សាច់សាលោហិត។ តែចំណង់ទាំងនោះកាលបើប្រព្រឹត្តទៅក្នុងសង្គមមនុស្សគេតែងជួបប្រទះនឹងលទ្ធផលល្អក៏មាន អាក្រក់ក៏មាន។ ហេតុនេះហើយបានជាអ្នកប្រាជ្ញគ្រប់តែសត-វត្សបានខិតខំរិះរកមធ្យោបាយច្រើនណាស់សម្រាប់ដឹកនាំមនុស្សទៅរកតែសេចក្ដីល្អ។

គេបានដឹងថា មនុស្សត្រូវការសប្បាយ និងការសុខស្រួល។ បើគេតម្រូវចិត្តមនុស្សទៅតាមសភាពនេះឃើញថាការលូតលាស់ក្នុងលោកយើងនេះនឹងមិនបានប្រសើរឡើយ។ ដូច្នេះហើយបានជាអ្នកដឹកនាំទាំងឡាយតែងតែត្បាំគំនិតកុមារឱ្យរៀនធ្វើការបន្តិចម្ដងៗតាំងពីតូចទៅដល់ពេញវ័យធំល្មមធ្វើការចិញ្ចឹមជីវិតខ្លួនឯង ទើបគេប្រគល់ឱ្យធ្វើកិច្ចការតែឯកឯងជានិរន្តរ៍តទៅ។

ជាទូទៅយើងសង្កេតឃើញ ទារក-កុមារ មនុស្សកំលោះ-ក្រមុំ មនុស្សពេញវ័យត្រូវការលេងល្បែងទាំងអស់។ លេងតាំងពីតូចរហូតដល់ធំ លេងគ្មានឈប់ឈរ លេងរហូតដល់ចូលកាន់មរណភាព។ ការលេងគេចែកជាពីរបែបគឺ លេងឱ្យសប្បាយ ដើម្បីឱ្យកើនសតិបញ្ញា កែអផ្សុក ជាសុខភាពដល់រូបកាយ និងលេងល្បែងស៊ីសងជាអំពើអបាយមុខ ដែលនាំឱ្យវិនាសដល់អាត្មាវិញ។ ការលេងជំពូកក្រោយនេះ ត្រូវចៀសវាងហាមឃាត់ដាច់ខាត ហើយមិនត្រូវបញ្ចូលមកបង្រៀនដល់កូន ឬសិស្សឡើយ។

ល្បែងទាំងអស់ដែលកូនចៅយើងលេង សព្វថ្ងៃនេះអាចបង្ហាញនូវប្រវត្តិសាស្ត្រនៃអារ្យធម៌ នូវទស្សនវិជ្ជានៃជីវិត និងចិត្តសាស្ត្រមួយយ៉ាងជ្រាលជ្រៅសម្រាប់ប្រទេសនីមួយៗ។ យើងបានដឹងថា ល្បែងដែលក្មេងលេងនោះអាចប្រាប់យើងឱ្យបានស្គាល់នូវន័យមួយរបស់វា បានរុញច្រានការលូតលាស់របស់វាគ្រប់ពេលនិងមានប្រយោជន៍សំខាន់ណាស់ក្នុងជីវិតរបស់វាដែលរស់នៅក្នុងគ្រួសារក្នុងកន្លែងលេង និងក្នុងសាលារៀនដែលធ្វើឱ្យការអប់រំមានភាពសក្ដិសិទ្ធិជាមិនខាន។

ល្បែង គឺជាសុខភាពនៃបុត្រធីតាទាំងឡាយ។

**ល្បែងមានន័យយ៉ាងដូចម្ដេចចំពោះក្មេង?**

ក្មេងនិងល្បែង ជាមិត្តនឹងគ្នាតាំងពីកំណើតមក។ ក្មេងមិនអាចនៅស្ងៀមមួយនាទីឡើយ គេត្រូវការលេងគ្មានឈប់ឈរ។ គេត្រូវការប្រដាប់លេងមាននៅក្នុងដៃជានិច្ច បើគ្មានប្រដាប់លេងនេះទេ ក្មេងមានទឹកមុខក្រៀមក្រំណាស់។ មានមាតាបិតា និងអ្នកអប់រំជាច្រើនមិនទាន់ស្គាល់ប្រយោជន៍ និងការចាំបាច់នៃល្បែងឡើយ បណ្ដោយឱ្យពេលវេលាកន្លងទៅ ហើយទុកឱ្យកូនឬសិស្សប្រព្រឹត្តល្បែងដែលគ្មានន័យអ្វីបន្តិចសោះ។

យើងសង្កេតមើលសព្វថ្ងៃនេះ ក្មេងស្រីលេងបាយឡុកបាយឡនៅប៉ប៉ុកនឹងដី ក្មេងប្រុសលេងដីខ្សាច់ធ្វើជានំ ឬជារូបសត្វតាមគំនិតនឹកឃើញរបស់គេ។ ខ្លះទៀតលេងល្បែងហ៊ឹងរត់បែកញើសហូរញើសកណ្ដាលថ្ងៃ។ មាតាបិតា ឬអ្នកអប់រំខ្លះទោមនស្សនឹងក្មេងលេងបែបនេះណាស់ ព្រោះជាហេតុនាំឱ្យមិនស្អាតដល់រូបកាយវា យើងដឹងថាក្មេងតូចគេត្រូវការបែបនេះ បើចំពោះយើងជាមនុស្សធំវិញមិនត្រូវចិត្តទេ។ ត្រង់នេះហើយ អ្នកប្រាជ្ញទាំងឡាយបានខិតខំរៀបចំប្រដាប់លេងឱ្យបានស្រួលស្របទៅតាមអាយុក្មេងហើយល្បែងនោះក៏តម្រូវទៅតាមចិត្តថ្លើមរបស់គេផងដែរគឺថាក្មេងគេចូលចិត្តប្រដាប់លេងទាំងឡាយណាដែលត្រូវនឹងគំនិតរបស់គេ។បច្ចុប្បន្ននេះបណ្ដាប្រទេសមួយចំនួន ជាពិសេសនៅអឺរ៉ុបគេផលិតប្រដាប់ក្មេងលេងតាមអាយុរបស់ក្មេង។

ល្បែងរបស់ក្មេងនាំឱ្យគេសប្បាយរីករាយ។ ការសប្បាយនេះហើយធ្វើឱ្យក្មេងមានសភាពនៅមិនស្ងៀម(សកម្ម) និងមានការសម្ដែងក្នុងពេលលេង។ ការសប្បាយនេះបាននាំឱ្យក្មេងចម្រើនលូតលាស់ និងមានកម្លាំងរឹងប៉ឹងផង។ ក្មេងចូលចិត្តធ្វើត្រាប់មនុស្សធំណាស់ គេសើចរីករាយគេញាក់ចិញ្ចើម និងបញ្ចេញកាយវិការផ្សេងៗ។ ការធ្វើត្រាប់តាមនេះហើយ ជាកត្តាជំរុញឲ្យក្មេងមានការលូតលាស់កើនជារៀងរាល់ថ្ងៃគ្មានឈប់ឈរ។ ល្បែងលេង គឺដឹកនាំក្មេងឱ្យចម្រើនសតិបញ្ញាបន្តិចម្ដងៗ ឱ្យមានគំនិតល្អឡើងរៀងរាល់ថ្ងៃ និងឱ្យរាងកាយលូតលាស់យ៉ាងសមរម្យ។

ដើម្បីឱ្យយល់នូវល្បែងរបស់ក្មេង យើងគប្បីដាក់គំនិតឱ្យទៅអែបនឹងក្មេងដែលកំពុងលេងដោយធ្វើដូចជាអ្នកលេងជាមួយដែរ។ នៅពេលនោះហើយ យើងគប្បីពិនិត្យមើលក្នុងផ្លូវចិត្តរបស់គេឱ្យបានជ្រៅជ្រះ។ យើងធ្វើទៅដោយសេចក្ដីគោរព និងស្នេហាគេជាទីបំផុត ដោយនៅជិតគេយ៉ាងជិតដិត តែកុំបីធ្វើអ្វីឱ្យមានកង្វល់ដល់ការដែល គេកំពុងលេងនោះឡើយ។ ក្នុងស្ថានភាពបែបនេះយើងអាចសន្និដ្ឋានថា ការវិនិច្ឆ័យរបស់យើងមិនបានសព្វគ្រប់អន្លើទេ ព្រោះការពិនិត្យបែបនេះ ក្មេងនឹងអឹមអៀនហើយលះបង់ចោលនូវគោលគំនិតដើមរបស់គេអស់មិនខាន។ ដូច្នេះយើងត្រូវធ្វើបែបណាឱ្យបានស្រួលក្នុងការពិនិត្យនេះកុំឱ្យគេដឹងខ្លួន។ ចំពោះក្មេងល្បែងមានតម្លៃ ៣ យ៉ាងគឺ៖

**តម្លៃទីមួយ៖** ការគិតដល់ការលូតលាស់សតិបញ្ញារបស់ក្មេង។

**តម្លៃទីពីរ៖** ការស្គាល់សណ្ដាប់ធ្នាប់មិនរៀបរយរបស់ក្មេង ស្គាល់គំនិតដើម ស្គាល់សេចក្ដីត្រូវការ និងស្គាល់កម្លាំងចិត្តរបស់គេ។

**តម្លៃទីបី៖** ការផ្ដល់ឱ្យយើងទាញយកដំណើរហេតុសព្វយ៉ាងមកពីការដែលក្មេងលេងនោះ។

*(នៅមានត)*

*លោក* **ចែម ផាន**

*អធិការបឋមសិក្សា*

# គាត់តែងប្រធានចំណោទដោយផ្ដើមចេញពីប្រមាណវិធីមួយ

**វត្ថុបំណង៖ គាត់តែងចំណោទ និងបង្កើតសំណួរដោយផ្ដើមចេញពីល្បះលេខ**

I-គោលបំណងរបស់សលាកប័ត្រ

- នាំសិស្សឱ្យចេះវិភាគ ពិចារណាលើន័យនៃព័ត៌មានជាលេខ និងន័យនៃប្រមាណវិធី។
- ហ្វឹកហាត់សិស្សឱ្យស្រាវជ្រាវរកអត្ថបទចំណោទមួយដែលទាក់ទងទៅនឹងល្បះលេខ។

**ចំណោទ**

១.ចូរតាក់តែងចំណោទមួយឱ្យត្រូវនឹងប្រមាណវិធីខាងក្រោម៖

$$\frac{230 + 150}{4} = \square$$

២.ចូររកចម្លើយ។

II-ការរៀបចំរបស់គ្រូ

ចម្លងចំណោទដាក់ក្ដារខៀនមុនពេលបង្រៀនឬសរសេរលើផ្ទាំងក្រដាសធំបើមានលទ្ធភាព។

III-លំនាំនៃការបង្រៀន

**ដំណាក់ទី១៖ អំណាន និងការយល់អត្ថន័យ**

- ឱ្យសិស្សអានចំណោទដោយស្ងៀមស្ងាត់
- ទុកពេលគ្រប់គ្រាន់ឱ្យសិស្សអាន
- គ្រូសួរ៖ «តើចំណោទនេះ គេឱ្យកូនធ្វើអ្វីខ្លះ?»
- ឱ្យសិស្ស ៤ ឬ៥នាក់ពន្យល់ដោយសម្ដីគេផ្ទាល់។ មិនឱ្យអានចំណោទឡើងវិញទេ។

**ដំណាក់ទី២៖ ការស្រាវជ្រាវរបស់សិស្ស**

- ឱ្យសិស្សពិភាក្សាតាមក្រុមពីរៗនាក់ដើម្បីស្រាវជ្រាវរកវិធីតាក់តែងចំណោទលើក្រដាសព្រាង។
- គ្រូត្រូវបញ្ជាក់ប្រាប់សិស្សថា ចំណោទដែលត្រូវតាក់តែងនេះត្រូវមានន័យច្បាស់លាស់ និងមានភាពជាក់ស្ដែងផង។
- ទុកពេលគ្រប់គ្រាន់ឱ្យសិស្សធ្វើកិច្ចការ។

- ដើរពិនិត្យការងារសិស្សតាមក្រុម។ ប្រសិនបើសិស្សភាគច្រើនជួបការលំបាក គ្រូអាច ឱ្យសិស្សអានប្រធានចំណោទឡើងវិញម្ដងទៀតដោយប្រុងប្រយ័ត្ន។
- ទុកពេលឱ្យសិស្សធ្វើកិច្ចការបន្តទៅទៀត។

នៅក្នុងដំណាក់នេះ គ្រូត្រូវដើរពិនិត្យមើលកិច្ចការសិស្សតាមក្រុមហើយកត់ចំណាំក្រុមខ្លះដើម្បីត្រៀមធ្វើការបូកសរុបៈ

- ចំណោទដែលត្រូវ ហើយដែលមានស្ថានភាពប្លែកៗគ្នា។
- ចំណោទដែលមិនត្រឹមត្រូវ (ខ្វះព័ត៌មាន ឬស្ថានភាពបញ្ហាមិនត្រូវនឹងល្បះ ឬត្រូវនឹងល្បះផ្សេងទៅវិញ)។

**<u>ដំណាក់ទី៣ៈ</u>កំណែរួម**

- ឱ្យសិស្សរៀបជាក្រុមបួនៗនាក់ (២ក្រុមតូច ដែលមានពីរៗនាក់)។
- ឱ្យសិស្សក្នុងក្រុមតូចដែលមានគ្នាពីរនាក់ ប្ដូរប្រធានចំណោទដែលក្រុមខ្លួនបានតែងទៅឱ្យក្រុមតូចមួយទៀតសាកល្បងដោះស្រាយ។ ទាំងពីរក្រុមផ្ទៀងផ្ទាត់ចំណោទរបស់ពួកគេ តើត្រូវនឹងល្បះលេខហើយឬនៅ។ បើសិស្សជួបការលំបាក គ្រូត្រូវឱ្យពួកគេពិភាក្សាកែសម្រួលចំណោទនោះឡើងវិញ។

**<u>ដំណាក់ទី៤ៈ</u> ការបូកសរុបរួម**

- ឱ្យសិស្សក្នុងក្រុមដែលគ្រូបានជ្រើសរើស ឡើងអានប្រធានចំណោទដែលក្រុមគេបានតាក់តែង (ឱ្យបានច្រើនក្រុម)។

ចំពោះចំណោទនីមួយៗដែលបានស្នើឡើង គ្រូត្រូវឱ្យសិស្សទាំងអស់ផ្ទៀងផ្ទាត់ថាៈ

- តើចំណោទនីមួយៗបានគោរពតាមការណែនាំដែរឬទេ (ស្ថានភាពចំណោទដែលត្រូវនឹងល្បះលេខ)
- ស្ថានភាពចំណោទមានន័យនិងអាចអនុវត្តជាក់ស្ដែង។

***គ្រូឱ្យសិស្សទាំងអស់ចូលរួមជួយកែលម្អចំណោទ និងឱ្យផ្ដល់អំណះអំណាងបញ្ជាក់ផង។**

- គ្រូសួរៈ «ចំពោះសំណួរទី២ តើកូនរកឃើញចម្លើយប៉ុន្មាន?»

- ឱ្យសិស្សឆ្លើយឱ្យបានច្រើននាក់។ ប្រសិនបើមានចម្លើយខុសៗគ្នាត្រូវឱ្យសិស្សធ្វើអំណះអំណាងបញ្ជាក់ផង។

**កំណត់សម្គាល់*

គ្រូអាចទទួលយកគ្រប់ចម្លើយផ្សេងៗទៀតរបស់សិស្ស (ប្រធានចំណោទដែលអាចដោះ-ស្រាយបានឬដែលអាចអនុវត្តបានជាក់ស្ដែង)។

**<u>ដំណាក់ទី៥ៈ</u>** សន្និដ្ឋាន

- គ្រូបង្ហាញអត្ថបទ «គួរចងចាំ» ដល់សិស្សដោយរៀបរាប់ពន្យល់។

**គួរចងចាំ**

*ប្រធានចំណោទត្រូវបានកសាងដោយអត្ថបទ និងបម្រាប់ (ចំនួន និងឯកតារបស់វា) ដែលបញ្ចប់ដោយសំណួរ ឬសំណូមពរ។ ដើម្បីតាក់តែងចំណោទមួយឱ្យបានត្រឹមត្រូវ អ្នកត្រូវហ្វឹកហាត់រកឱ្យឃើញនូវបណ្ដាព័ត៌មានដែលទាក់ទងនឹងល្បះលេខ។*

**IV-ចម្លើយ**

១.អង្គការក្រៅរដ្ឋាភិបាលមួយបានផ្ដល់អង្ករពលកម្មស្មើៗគ្នាដល់ប្រជាជនចំនួន ៤ក្រុម។ លើកទី១ទទួលបានអង្ករទម្ងន់២៣០គក។ លើកទី២ ទទួលបាន១៥០គក។ តើក្រុមនីមួយៗទទួលអង្ករបានប៉ុន្មានគីឡូក្រាម?

២.ឪពុកខ្ញុំបានឱ្យគ្រាប់ឃ្លីខ្ញុំចំនួន២៣០គ្រាប់។ ជីតាខ្ញុំបានឱ្យឃ្លីចំនួន១៥០គ្រាប់ទៀត។ ខ្ញុំនិងបងខ្ញុំគិតគ្នាថានឹងយកទៅចែកឱ្យប្អូនៗ៤នាក់។ តើម្នាក់ៗទទួលបានគ្រាប់ឃ្លីប៉ុន្មានគ្រាប់?

*ចំពោះចំណោទទី២នេះពុំមានការពិតជាក់ស្ដែងទេព្រោះគ្រាប់ឃ្លីមានចំនួនច្រើនពេកដែលកូនក្មេងពុំអាចមាន។ ដូច្នេះប្រសិនបើមានចំណោទបែបនេះ គ្រូត្រូវដឹកនាំសិស្សឱ្យចេះប្ដូរចំណោទនេះឱ្យមានភាពជាក់ស្ដែងវិញដូចជា ៖

ឪពុកខ្ញុំជាអ្នកលក់អីវ៉ាន់ធំជាងគេក្នុងភូមិតាកុក។ គាត់បានទិញគ្រាប់ឃ្លីពណ៌ខៀវចំនួន២៣០គ្រាប់ និងពណ៌ក្រហមចំនួន១៥០គ្រាប់។ គាត់បានឱ្យបងស្រីខ្ញុំច្របល់ចូលគ្នាហើយច្រកចូលស្បោងប្លាស្ទិក ៤ស្មើៗគ្នា ដើម្បីផ្ញើទៅលក់នៅតាមផ្ទះលក់តូចៗក្នុងភូមិ។ តើស្បោងនីមួយៗមានឃ្លីប៉ុន្មានគ្រាប់?

**V-សម្រាប់ម៉ោងក្រោយ**

គ្រូអាចដាក់ចំណោទបែបដដែលនេះនៅពេលសិក្សាក្រោយៗជាមួយនឹងស្ថានភាពផ្សេងៗ ដើម្បីឱ្យសិស្សកាន់តែយល់ន័យរបស់ប្រមាណវិធីទាំងឡាយដោយគ្រាន់តែផ្លាស់ប្ដូរល្បះលេខ ដូចជា៖

ក.(120x3) + (15x2)

ខ.(75x5) – 250

គ.(168 + 8)x3

ឃ......................។ល។

ឧទាហរណ៍៖ចូរតាក់តែងចំណោទមួយឱ្យត្រូវនឹងល្បះលេខ(120x3) + (15x2)។ ចូររកចម្លើយ។

**IV-លំនាំនៃការបង្រៀន**

ត្រូវអនុវត្តតាមដំណាក់ទាំង ៤ ដូចខាងលើ។

*ដកស្រង់ដោយលោកស្រី* **ម៉ុន សារ៉ន**




# ការចុះឈ្មោះក្នុងគេហទំព័រគ្រូ
## មជ្ឈមណ្ឌលធនធានអេឡិចត្រូនិក
**www.krou.moeys.gov.kh**

មជ្ឈមណ្ឌលធនធានអេឡិចត្រូនិក ឬគេហទំព័រគ្រូ (krou.moeys.govkh) របស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានអភិវឌ្ឍឡើងក្នុងគោលបំណងផ្ដល់ជូននូវធនធានឌីជីថលដ៏សម្បូរបែប តាមបណ្ដាញអ៊ីនធឺណិត ដល់គ្រូបង្រៀន អ្នកសិក្សាស្រាវជ្រាវ សិស្សានុសិស្ស និងសាធារណជនទូទៅ។ ទន្ទឹមនឹងនេះ គេហទំព័រគ្រូក៏បានអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចបញ្ចូលរាល់ស្នាដៃរបស់ខ្លួនដែលបានស្រាវជ្រាវ ដើម្បីចែករំលែកដល់អ្នកផ្សេងទៀតតាមរយៈទំព័របណ្ដាញនេះផងដែរ។

ដើម្បីអាចធ្វើការដាក់បញ្ចូលអត្ថបទរបស់អ្នកបានជាចាំបាច់អ្នកត្រូវមានគណនីមួយនៅក្នុងគេហទំព័រគ្រូជាមុនសិន តាមរយៈការចុះឈ្មោះជាសមាជិក ដោយអនុវត្តតាមជំហានដូចខាងក្រោម៖

### ១.ការបង្កើតគណនីថ្មីក្នុងគេហទំព័រគ្រូ

ដើម្បីបង្កើតគណនីថ្មី លោកអ្នកអាចចូលទៅកាន់គេហទំព័រគ្រូតាមរយៈអាសយដ្ឋាន krou.moeys.gov.kh ដែលនឹងនាំលោកអ្នកមកដល់ទំព័រដើមនៃគេហទំព័រគ្រូ៖




*រូបភាព១៖ អាសយដ្ឋានគេហទំព័រគ្រូ*

បន្ទាប់មកសូមចុចរបាររមូលចុះក្រោម (Scroll bar) រហូតដល់ឃើញប្រអប់សមាជិកដែលស្ថិតនៅផ្នែកខាងស្ដាំនៃគេហទំព័រ។ (រូបភាព២)




*រូបភាព២៖ ប្រអប់សមាជិក*

- *ចុចលើតំណបង្កើតគណនីថ្មី*

បន្ទាប់មកនឹងនាំអ្នកមកដល់ផ្ទាំងព័ត៌មានលម្អិតអំពីគណនីដែលតម្រូវឱ្យអ្នកបំពេញព័ត៌មានចាំបាច់មួយចំនួនអំពីគណនីដែលអ្នកត្រូវបង្កើតដូចខាងក្រោម៖

- ឈ្មោះ៖ វាយឈ្មោះរបស់អ្នក (ជាអក្សរខ្មែរ ឬឡាតាំង)
- ឈ្មោះអ្នកប្រើប្រាស់៖ ជាឈ្មោះសម្រាប់ចូលប្រើប្រាស់ (ជាអក្សរឡាតាំង និងមិនដកឃ្លា
- អ៊ីមែល៖ បញ្ចូលអ៊ីមែលរបស់អ្នក
- បញ្ជាក់អ៊ីមែល៖ បញ្ចូលអ៊ីមែលរបស់អ្នកម្តងទៀត (ដូចអ៊ីមែលខាងលើ)
- លេខសម្ងាត់៖បញ្ចូលលេខសម្ងាត់សម្រាប់គណនីថ្មី (យ៉ាងតិច៨តួអក្សរ ឬលេខ)
- ត្រូវវាយពាក្យសម្ងាត់ម្តងទៀត៖ បញ្ចូលលេខសម្ងាត់ម្តងទៀត (ដូចពាក្យសម្ងាត់ខាងលើ)




*រូបភាព៣៖ ប្រអប់ព័ត៌មានលម្អិតអំពីគណនេយ្យ*

បន្ទាប់ពីបំពេញព័ត៌មានខាងលើរួចមក អ្នកត្រូវបំពេញព័ត៌មានផ្ទាល់ខ្លួន និងបញ្ចូលពាក្យបញ្ជាក់នៅលើផ្នែកព័ត៌មានផ្ទាល់ខ្លួន (រូបភាព ៤) មុននឹងបញ្ចប់ការចុះឈ្មោះដោយអនុវត្តដូចខាងក្រោម៖




*រូបភាព៤៖ ប្រអប់ព័ត៌មានផ្ទាល់ខ្លួន*

បន្ទាប់ពីបំពេញព័ត៌មានបានគ្រប់គ្រាន់និងចុចប៊ូតុងចុះឈ្មោះរួចមកអ្នកនឹងចូលមកដល់ផ្ទាំងមួយដូចខាងក្រោមដែលបញ្ជាក់ថា អ្នកបានចុះឈ្មោះជោគជ័យ។

គណនីរបស់អ្នកបានបង្កើត ហើយតំណធ្វើឱ្យសកម្មត្រូវបានផ្ញើទៅអាសយដ្ឋានអ៊ីមែលដែលអ្នកបានបញ្ចូល ។ សូមចំណាំថាមុននឹងអ្នកអាចកត់ត្រាចូលបាន អ្នកត្រូវតែធ្វើឱ្យគណនីសកម្មជាមុនសិនដោយចុចលើតំណសកម្មពេលអ្នកមកទទួលអ៊ីមែល ។

**បញ្ជាក់៖** ប្រព័ន្ធចុះឈ្មោះនេះនឹងផ្ញើអ៊ីមែលមួយទៅអាសយដ្ឋានអ៊ីមែលរបស់អ្នក។ អ្នកត្រូវចូលទៅកាន់អ៊ីមែលរបស់អ្នក និងចុចលើតំណធ្វើឱ្យសកម្មលើសារអ៊ីមែលមួយដែលផ្ញើដោយអ្នកប្រើ Krou_web ដើម្បីឱ្យគណនីដែលទើបតែចុះឈ្មោះនោះដំណើរការបាន។

## ២.ការចូលធ្វើឱ្យគណនីសកម្ម ឬបើកឲ្យដំណើរការ

ដូចបានបញ្ជាក់ខាងលើ បន្ទាប់ពីចុះឈ្មោះរួច ដើម្បីធ្វើឱ្យគណនីរបស់អ្នកអាចដំណើរការបាន អ្នកត្រូវចូលទៅអ៊ីមែលរបស់អ្នកជាមុនសិន បន្ទាប់មកសូមអនុវត្តដូចខាងក្រោម៖

- ចុចលើសារដែលផ្ញើដោយអ្នកប្រើ Krou_web(ដូចរូបខាងក្រោម)

☐ Krou_web សេចក្តីលម្អិតគណនីសម្រាប់ Kev Kaly សួស្តី Kev Kalyan ! សូមអរគុណអ្នកដែលបានចុះឈ្មោះនៅឯ Administrator Krou V

- ចុចលើតំណខាងក្រោម ដើម្បីបើកឱ្យគណនីរបស់អ្នកដំណើរការ

**Krou_web** <krou@moeys.gov.kh>
To kev_kalyan@yahoo.com

សួស្តី Kev Kalyan !

សូមអរគុណអ្នកដែលបានចុះឈ្មោះនៅឯ Administrator Krou Website ។ គណនីអ្នកបានបង្កើត ប៉ុន្តែត្រូវសកម្មវាសិនមុននឹងអ្នកអាចប្រើវាបាន ។ ដើម្បីសកម្មគណនីនេះ សូមចុចលើតំណដូចខាងក្រោម ឬចម្លងរួចបិទភ្ជាប់វាទៅក្នុងកម្មវិធីរុករករបស់អ្នក៖
http://krou.moeys.gov.kh/index.php?option=com_users&task=registration.activate&token=292840ecb0ad39847763b1ec0f0edb89

បន្ទាប់ពីសកម្មរួចអ្នកអាចកត់ត្រាចូលទៅក្នុង http://krou.moeys.gov.kh/ ដោយប្រើឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់ដូចខាងក្រោម៖

ឈ្មោះអ្នកប្រើប្រាស់៖ Kev_kalyan → *ឈ្មោះសម្រាប់ចូលប្រើប្រាស់*
ពាក្យសម្ងាត់៖ [redacted] → *លេខសម្ងាត់សម្រាប់ចូលប្រើប្រាស់*

## ៣.ការចូលប្រើគណនីរបស់អ្នក

បន្ទាប់ពីបញ្ចប់ជំហានទី២ មានន័យថា គណនីរបស់អ្នកត្រូវបានបើកឱ្យដំណើរការ និងអាចប្រើប្រាស់ដើម្បីចូលប្រើ (log in) គេហទំព័រគ្រូក្នុងការដាក់បញ្ចូលឯកសារបានហើយ។

ដើម្បីប្រើគេហទំព័រគ្រូក្នុងការដាក់បញ្ចូលឯកសារអ្នកត្រូវប្រើឈ្មោះអ្នកប្រើនិងពាក្យសម្ងាត់ដែលបានចុះឈ្មោះជាមួយគេហទំព័រនៅក្នុងប្រអប់សមាជិក (រូបភាព២)។ បន្ទាប់មកចុចប៊ូតុងចូលប្រើប្រាស់ជាការស្រេច៕

*ដោយលោក* ***អ៊ុក សម្ផស្ស*** *និង* ***តែល តារុណា***

*កែសម្រួល* ***សុក ថា*** *ការិ.បច្ចេកវិទ្យាព័ត៌មានអប់រំ*




## ចំណងបីប្រការ

*បទភុជង្គលីលា(សូត្របែបរាស់)*

១. ពាក្យចាស់បានចារទុកផ្លូវ រហូតឥឡូវ នោះត្រូវចាំចង ។
២. ទទួលយកជាច្បាប់ច្បង រកសុខម៉ត់ហ្មង ចំណងគ្រួសារ ។
៣. នោះគឺចំណងសោតណា មានបីប្រការ ថាងថាក្បាច់ក្បួន ។
៤. ចំណងទីមួយសមសួន គឺនាងនឹមនួន ខ្លឹមខ្លួនភរិយា ។
៥. ចងយើងយ៉ាងជាប់គ្រប់គ្រា ទោះក្ដៅរងា ឈឺជាម្ដេចក្ដី ។
៦. ចិត្តយើងដក់ជាប់ឥតបី ខ្លាចមានប្រុសថ្មី ស្រដីឌឺដង ។
៧. ខ្លាចមានជំងឺនោះផង ទុក្ខសោកកន្លង សៅហ្មងចំបែង ។
៨. ជួននឹកចង់លបបន្លែង ខិបខុបខែងរ៉ែង តាក់តែងបូកប៉ាន់ ។
៩. ជួននឹកឃើញនាងប្រច័ណ្ឌ ខេរខឹងសាន់វ៉ាន់ ដុកដាន់ឈ្នះចាញ់ ។
១០. ជួននឹកឃើញនាងស្រឡាញ់ ក្និកក្នក់ក្អេរក្អាញ់ ឈ្ងុយឆ្ងាញ់ស្នេហា ។
១១. ជួននឹកឃើញដូចមាតា ថ្នមថ្នាក់រក្សា កិច្ចការក្នុងផ្ទះ ។
១២. ចំណងនេះរាប់មិនឈ្នះ រឹតរួតពេញពាស លាលះមិនបាន ។
១៣. ចំណងទីពីរសមសាន្ត គឺបុត្រកល្យាណ គ្រប់ប្រាណពេកពិត ។
១៤. កូនធ្វើឱ្យយើងគន់គិត រិះរេគំនិត មូលមិត្តប្រសើរ ។
១៥. គ្រប់គ្រងអប់រំផ្លូវដើរ ឱ្យកូនគ្រាន់បើ ដំណើរល្អជា ។
១៦. មិនចង់ឃើញកូនវេទនា ទោះមានក្រគ្រា ទាមទារតស៊ូ ។
១៧. លំបាកមិនហ៊ានរអ៊ូ ក្នុងចិត្តគិតគូរ ឆាប់យូរតាមហេតុ ។
១៨. ចង់ឃើញកូនបានឆ្អល់ឆ្អែត ខ្ពង់ខ្ពស់ត្រដែត ត្រសៃតត្រសាយ ។
១៩. ចំណងនេះចងមិនណាយ តឹងពេញរាងកាយ បន្លាយលុះក្ស័យ ។
២០. ចំណងមួយទៀតធំក្រៃ ក៏តឹងអស់ដៃ ច្រៀវច្រៃគ្រប់គ្រា ។
២១. គឺភោគសម្បត្តិទ្រព្យា ឱ្យប្រឹងពុះពារ យាំងយារលកលៃ ។

២២. រិះរយឱ្យគង់ប្រពៃ ខាតបង់ទីទៃ រំពៃថៃថ្នូន ។
២៣. ម្យ៉ាងប្រឹងមិនបានដេកពួន ក្នុងចិត្តមាំមួន ខំផ្ចួនឱ្យកើន ។
២៤. ខំរកថែមឱ្យបានច្រើន ចម្រុងចម្រើន ក្រវើនមិនខ្វាត់ ។
២៥. ភិតភ័យខ្លាចទ្រព្យបង់បាត់ រសាយរសាត់ សូន្យស្ងាត់សោះសល់ ។
២៦. ចំណាងទាំងបីថ្កើងថ្កល់ ដែលមនុស្សខ្វាយខ្វល់ រចល់គ្រប់គ្នា ។
២៧. ហេតុនេះយើងត្រូវម្ចីម្នា ថែទុកឱ្យជា ឃ្លាតឃ្លាមិនបាន ។
២៨. ព្រួតប្រឹងកុំបីខកខាន រកក្ដីសុខសាន្ត គ្រប់ប្រាណទៅមុខ ៕

*លោក* **ឈា ឈៀន**

*និវត្តជន*

## ៥០% ដូចគ្នា

*មេព្រៃជនជាតិម៉ិកស៊ិកម្នាក់ ចូលហាងទិញកាំភ្លើងទៅបាញ់ទន្សាយ ប៉ះចំកាំភ្លើងខូច នៅពេលទៅដល់កន្លែងបាញ់ទន្សាយទើបដឹង។ គាត់ខំជួសជុលយ៉ាងណាក៏ប្រើការមិនកើត ក៏ត្រឡប់មកផ្ទះវិញទាំងមួម៉ៅ។ ដល់ពាក់កណ្ដាលផ្លូវ ឃើញតូបមួយដាក់ផ្លាកថា ម្ហូបទន្សាយ។ ដោយគាត់មានចំណូលសាច់ទន្សាយស្រាប់ក៏ចូលតូបនោះ ហើយបញ្ជាថា៖*

*- ស៊ុបសាច់ទន្សាយពិសេសមួយឆ្នាំង!*

*បន្តិចក្រោយមក ស៊ុបក៏មកដល់។ មេព្រៃភ្លក់ហើយស្រែកហៅចុងភៅមកសួរភ្លាម៖*

*- ស៊ុបនេះដូចជាមិនមែនសាច់ទន្សាយទេ ឆ្លើយត្រង់មកមើល តើឯងលាយសាច់អ្វីខ្លះ?*

*ចុងភៅក៏ឆ្លើយតាមត្រង់៖*

*- លាយសាច់ក្របីខ្លះទាន*

*មេព្រៃសួរគំហកខ្លាំងៗថា៖*

*- ឯងលាយរបៀបម៉េច?*

*ចុងភៅឆ្លើយ៖*

*- លាយ ៥០%ដូចគ្នា*

*មេព្រៃក្ដៅស្លឹកត្រចៀកអ៊ីង ស្រែកជំទាលដាក់ចុងភៅ*

*- ឯងពន្យល់ឲ្យច្បាស់បន្តិចបានទេ?*

*ចុងភៅតប*

*- បាទទាន គឺខ្ញុំលាយក្នុងសមាមាត្រក្របី១ចំហៀង និងទន្សាយ១ចំហៀង ស្មើភាគរយគ្នាល្អណាស់ទាន គឺឯកទេសរបស់ខ្ញុំ*

*មេព្រៃហួសចិត្តអស់វាចានឹងថា៖*

*- អញថ្ងៃនេះក្របីសុទ្ធតែម្ដង!*

**ស្រង់ពី ទស្សនាវដ្ដីគណិតវិទ្យា និងវិទ្យាសាស្ត្រ**

# កុំសេពសុរា

(បទព្រហ្មគីតិ)

| | | |
|---|---|---|
| កាហ្វេចិត្តអាចារ្យ | ស្គាល់ធម៌អាចដឹងខុសត្រូវ | |
| ស្គាល់បងប្អូនម៉ែឪ | យកផ្លូវត្រូវជាតម្រា | ។ |
| ស្រាចូលប្ដូរចិត្តភ្លាម | កម្ដៅឈាមឡើងអង្សា | |
| ស្ពឹកមុខក្លែមវោហារ | ពាក់មុខស្វាភ្លាសំដី | ។ |
| មុខរីកបានស្រវឹង | វក់លែងដឹងខ្លួនជាស្អី | |
| ចរិតខុសប្រក្រតី | ចិត្តអប្រិយ៍អាងកាប់ចាក់ | ។ |
| កាំភ្លើងការពារខ្មាំង | យកមកច្បាំងនឹងមិត្តភក្ដិ | |
| របួសដៃជើងបាក់ | ពិការខ្វាក់ស្លាប់វេទនា | ។ |
| ផ្លាស់ប្ដូរបានឬទេ? | តែកាហ្វេជំនួសស្រា | |
| រក្សាប្រាជ្ញបញ្ញា | ភ្លឺស្រស់ថ្លាស្រឡាញ់ជាតិ | ។ |
| កម្ចាត់ភាពស្រវឹង | ចំណេះដឹងកុំឱ្យឃ្លាត | |
| ខួរក្បាលដុសខាត់ទៀត | ត្រូវត្រៀមផ្ចៀតកុំទំនេរ | ។ |
| កម្ពុជាចូលអាស៊ាន | តើយើងមានអ្វីនឹងគេ? | |
| ខួរក្បាលសុទ្ធ «ត្រប៉ែ» | យើងជាខ្មែរខ្វះផលទុន | ។ |
| ប្អូនៗស្រកក្រោយ | កុំដោយពោយដូចអ្នកមុន[១] | |
| ត្រូវចេះសន្សំទុន | ត្រៀមទុកស្រេចទើបរឹងមាំ | ។ |
| គិតគូរឱ្យត្រឹមត្រូវ | ពាក្យប្រដៅត្រូវចងចាំ | |
| កុំខ្លៅដេកត្រែងត្រាំ | ពាក្យបណ្ដាំត្រូវសង្វាត | ។ |
| ស្រវឹងអ្វីចំណេញ | កម្ចាត់ចេញអ្វីដែលខាត | |
| ការងារកុំប្រមាទ | ត្រូវវៃឆ្លាតទាំងអស់គ្នា | ។ |
| បរទេសគេឆ្លាតណាស់ | យើងឥតខ្មាស់នឹកតែស្រា | |
| គេរត់យើងលូនវារ[២] | ខ្មែរគ្រប់គ្នាត្រូវរិះគិត | ។ |
| ពូជខ្មែរគ្រាន់បើដែរ | មិនដែលទេសុញគំនិត | |
| អង្គរជានិម្មិត | ពូជខ្មែរពិតជាខ្លាំងក្លា | ៕ |




លោក **រត្ន ហួត**
អតីតនាយករងវិទ្យាស្ថានជាតិអប់រំ

(១)អ្នកដឹក, (២)ព្រោះស្រវឹងរាល់ថ្ងៃ



# ពុទ្ធសាសនានៅកម្ពុជា (ត)

## ពុទ្ធសាសនាសម័យនគរភ្នំ
## ពុទ្ធសតវត្សរ៍ទី៦-១១ (ព.ស.៤៤៣-១០៩៣)
## គ្រិស្តសតវត្សរ៍ទី១-៦

បើយើងយកប្រភពលង្កាទ្វីបជាសក្ខីភាព យើងត្រូវនិយាយថា ព្រះពុទ្ធសាសនាបានចូលមកប្រទេសនគរភ្នំ (Founan) តាំងពីពុទ្ធសតវត្សរ៍ទី៣ (ព.ស.២៣៤) គឺមុនគ្រិស្តសករាជ៣០៩ឆ្នាំ ព្រោះនគរភ្នំនេះឋិតនៅក្នុងតំបន់សុវណ្ណភូមិខាងបុព្វទិស ឬអាស៊ីភាគអាគ្នេយ៍។ អ្នកនិពន្ធជាតិចិន មាននិយាយពីពង្សាវតាខ្មែរច្រើនដែរ ដូចជាថា ខ្មែរបានកសាងខ្លួនជាប្រជាជាតិមួយ មានរូបរាងកើតឡើងក្នុងពិភពលោកតាំងពីគ្រិស្តសតវត្សរ៍ទី១ ប៉ុន្តែលោកហ្វៀរ៉ង្សថា "នៅប្រទេសនគរភ្នំ មានជនជាតិឥណ្ឌាបាននាំយកវប្បធម៌ខ្លួនមកផ្សាយតាំងតែពីពុទ្ធសតវត្សរ៍ទី៣គឺតាំងពីមុនគ្រិស្តសករាជ៣០០ឆ្នាំម្ល៉េះ។ មានប្រភពចិនខ្លះនិយាយថា ប្រទេសខ្មែរ និងចិនមានការទាក់ទងគ្នាតាំងពីមុនគ្រិស្តសករាជច្រើនរយឆ្នាំ។



ព្រះពុទ្ធបដិមានៅវត្តរំលក , អង្គរបុរី តាកែវ

តាមសិលាចារឹកជាភាសាខ្មែរ នគរភ្នំ សរសេរថា “កុរុងព្នំ ឬវ្រះវ្នំ” រាជធានីឈ្មោះ “វ្យាធបុរៈ” ជាទីក្រុងតាំងនៅតំបន់បាភ្នំ។ អ្នកប្រវត្តិសាស្ត្រចិនឈ្មោះ កាំង-ថៃ (Kang-Thai) និង ជូ យិង (Zhu Ying) ជារាជទូតព្រះចៅក្រុងចិនព្រះនាម វូ (Wu) គ.ស.២២២-២៨០ បានមកប្រទេសនគរភ្នំជាដំបូងក្នុងដើមគ្រិស្តសតវត្សរ៍ទី៣។ រាជទូតទាំងនេះហៅប្រទេសនគរភ្នំថា ហ្វូណន។

ពង្សាវតារពីព្រេងនាយទាំងប៉ុន្មានបាត់បង់អស់ទៅតាមកាលវេលានៅមានសល់ខ្លះតែសិលាចារឹក ៤ កន្លែងគឺនៅវ៉ូកាញ់ ខេត្តញ៉ាត្រាំង (ប្រទេសយួន)១ នៅអ្នកតាដំបងដែក ខេត្តតាកែវ១ នៅប្រាសាទ ៥ល្វែង (កម្ពុជាក្រោម)១ នៅទន្លេបាទី ខេត្តតាកែវ១។ សិលាចារឹកទាំងនេះខ្លះនិយាយពីព្រះរាជាគោរពសាសនាព្រាហ្មណ៍ ខ្លះនិយាយពីព្រះរាជាគោរពពុទ្ធសាសនា។

ឯកសារចិននិយាយថា ព្រះរាជអាណាចក្រនគរភ្នំ តាំងនៅឆ្នេរឈូងសមុទ្រមួយធំ ខាងកើតទល់នឹងប្រទេសលិន-យី (ប្រទេសចម្ប៉ា) ខាងលិចទល់នឹងប្រទេសឥណ្ឌា និងអាណាចក្រគិនលិន(ព្រំដែនមាស ឬដែនដីមាស ឬកំពែងមាស)។ ប្រជាជនសម្បុរខ្មៅ សក់រួញ ប្រជុំភូមិមួយមានអណ្តូងមួយ រកស៊ីធ្វើស្រែចំការ មានក្រុងច្រើនសុទ្ធសឹងព័ទ្ធជុំវិញដោយកំពែង មានប្រាសាទរាជស្ថាន។ លើដីមានព្រៃព្រឹក្សា គ្រឿងទេស មានសត្វទឹក សត្វគោក ក្ងោក បក្សី ចចាត សេក ៥ពណ៌។ ក្នុងដីមានមាស ស្ពាន់ សំណ ដែក ពេជ្រ និលចិន្តា គជ់ជាដើម។ ប្រជាជនចេះត្បាញរវៃអំបោះសូត្រ ចេះធ្វើសំពៅធំៗឆ្លងសមុទ្រ ចេះសិល្បៈឆ្លាក់ក្បាច់រចនា ធ្វើចិញ្ចៀន កងកណ្ឋ[១] ខ្សែកណ្ឋ ខ្សែដៃ កងជើង មានចានប្រាក់ប្រើប្រាស់ យកមាសប្រាក់គជ់គ្រឿងក្រអូបបង់ពន្ធដារ មានក្បួនតម្រា សាស្ត្រាគម្ពីរមានមន្ទីរឯកសារ សរសេរអក្សរតាមបែបឥណ្ឌា។ ទំនៀមការកូនចៅ ឬបុណ្យខ្មោចដូចនៅប្រទេសលិនយីដែរ។ ប្រជាជនកាន់សាសនាព្រាហ្មណ៍ គោរពព្រះមហេស្វរៈក៏មាន កាន់ពុទ្ធសាសនាខាងថេរវាទក៏មាន ចេះធ្វើទេវរូបពីសំរិទ្ធិពីថ្ម បើមុខពីរមានដៃបួន បើមុខបួនមានដៃប្រាំបី ដៃមួយៗកាន់គ្រឿងឧបករណ៍ផ្សេងៗ ឬកាន់ព្រះអាទិត្យព្រះចន្ទ។ ទំនៀមកាន់ទុក្ខខ្មោចត្រូវកោរពុកមាត់ កោរសក់។ ទំនៀមកប់ខ្មោចមាន ៤ យ៉ាងគឺកប់ក្នុងដី ចោលក្នុងព្រៃស្មសានឱ្យសត្វស៊ី ទម្លាក់ចោលក្នុងទឹក ដុត។ មានពាណិជលក់ដូរគ្រឿងទេស មាសប្រាក់ សំពត់ព្រៃ។ មានពាណិជពីប្រទេសឆ្ងាយទៅមកលក់ដូរ។ ប្រទេសនគរភ្នំ និងលិនយី ទាំងពីរនេះ មានការទាក់ទងគ្នាតាមផ្លូវជើងទឹកជើងគោក ហើយជួយគ្នាទៅវិញទៅមក។ ប្រទេសនគរភ្នំទាក់ទងរហូតទៅដល់ប្រទេសឥណ្ឌា។ មានពាណិជករឥណ្ឌាម្នាក់ឈ្មោះកៀ-ស៊ាង-លី (Kia-Siang-Li) បានទៅលក់ដូរដល់ប្រទេសនគរភ្នំប្រហែលជាក្នុងពាក់កណ្តាលគ្រិស្តសតវត្សរ៍ទី២ ហើយសរសើរថាប្រទេស នគរភ្នំនេះចម្រើនរុងរឿងណាស់។

ឯកសារចិនមានដំណាលពីព្រះរាជាច្រើនអង្គនៅប្រទេសនគរភ្នំ រៀបរាប់ថា នៅនគរភ្នំមានព្រះរាជិនីជាស្តេចស្រីសោយរាជ្យជាទំនៀម គឺព្រះនាងលៀវយី មានព្រះរូបឆោមល្អល្អះដូចជាព្រះរាជកុមារ ហើយមានព្រាហ្មណ៍ម្នាក់ឈ្មោះហ៊ុន-ទៀន បានធ្នូសរមួយដែលទេពតាប្រទាន ក៏ចុះសំពៅសំដៅមកកាន់ប្រទេសនគរភ្នំ។ ព្រះនាងលីវ-យី លើកទ័ពទៅច្បាំងតទល់នឹងព្រាហ្មណ៍

១)កណ្ឋ ៖ ព្រួញ គ្រាប់កាំភ្លើង ទង់ ដើម កំណាត់ បរិច្ឆេទ វគ្គ ខ្សែ សាស្ត្រាមួយកណ្ឋ

ហ៊ុន-ទៀននោះ តែខ្លបខ្លាចចេស្តាព្រាហ្មណ៍ រួចក៏ព្រមទទួលយកជាស្វាមី។ ព្រះបាទហ៊ុន-ទៀន និងព្រះនាងលីវ-យីនេះ ជាបឋមក្សត្រនៃប្រទេសនគរភ្នំ។ ឯកសារចិនដែលនិយាយរឿងព្រះបាទហ៊ុន-ទៀននិងព្រះនាងលីវ-យីនេះ ស្របគ្នានឹងសិលាចារឹកនៅមីុសឺង(Myson) ដែលនិយាយថាព្រះបាទកៅណ្ឌិន្យបានប្រតិស្ឋានលំពែងទុកនៅភវបុរៈហើយបានព្រះនាងនាគីសោមាជាអគ្គមហេសី ហើយតាំងជារាជវង្សដើមនៃប្រទេសនេះឡើង។ ខ្មែរយើងធ្លាប់ដឹងតាមពង្សាវតារជាហូរហែមកថា ព្រះថោងនាងនាគជាបឋមក្សត្ររបស់ខ្មែរនៅនគរគោកធ្លក គឺរឿងរ៉ាវនេះឯង។ សិលាចារឹកនៅប្រាសាទបក្សីចាំក្រុងពីគ.ស.៩៤៨ ចែងទុកថា ព្រះបាទរុទ្រវរ័ន្មជាព្រះរាជាក្រោយបំផុតសម័យនគរភ្នំ ជាព្រះរាជាតវង្សមកពីព្រះបាទកៅណ្ឌិន្យ និងព្រះនាងនាគីសោមា។ ឯកសារចិនបន្ថែមទៀតថា ព្រះបាទហ៊ុន-ទៀន និងព្រះនាងលីវយីនេះ មានព្រះរាជបុត្រមួយព្រះអង្គ ហើយទ្រង់តែងតាំងឲ្យត្រួតត្រាប្រទេសសមន្តរាជ៧នគរ។ តមកមានព្រះរាជាតវង្សមួយអង្គនាមហួន-ប៉ុង-ហួង (Houen-P’an-Houang) លើកទ័ពទៅច្បាំងដណ្តើមយកសមន្តរាជទាំង៧បាន ហើយបញ្ជូនព្រះរាជបុត្រនិងព្រះរាជនត្តាព្រះអង្គឱ្យទៅសោយរាជ្យជំនួសវិញ។ ព្រះបាទហួន-ប៉ុង-ហួងនេះសោយទីវង្គតក្នុងព្រះជន្មាយុកំណត់ ៩០វស្សា (គ្រិស្តសតវត្សរ៍ទី២)។ ព្រះរាជបុត្រព្រអង្គទី២ព្រះនាមប៉ុន-ប៉ុនឡើងសោយរាជ្យ ហើយទ្រង់តែងតាំងឧត្តមសេនីយម្នាក់ឈ្មោះ ហ្វាន់-ម៉ុន ឱ្យសម្រេចព្រះរាជកិច្ចថ្វាយ។ បីឆ្នាំក្រោយមក ព្រះបាទប៉ុន-ប៉ុនទ្រង់សោយទីវង្គតទៅទៀត ទើបអ្នកនគរលើកឧត្តមសេនីយ ហ្វាន់-ម៉ុន ជាព្រះរាជាឱ្យឡើងសោយរាជ្យតមក។ ព្រះបាទហ្វាន់-ម៉ុន ឬហៅមួយទៀតថា ហ្វាន់-ចេ-ម៉ុន គឺស្រីមារៈនេះជាស្តេចក្លាហានហើយវាងវៃណាស់ ទ្រង់បានឡើងជាមហារាជាធិរាជនៃប្រទេសនគរភ្នំ។ ទ្រង់រេហ៍ពលទៅវាយយកប្រទេសជិតខាងឱ្យចុះចូលព្រះអង្គទាំងអស់។ ទ្រង់បានកសាងនាវាធំៗ ហើយឆ្លងមហាសមុទ្រទៅច្បាំងយកអាណាចក្រ ១០ មកចំណុះព្រះអង្គទៀត។ ទ្រង់មានបំណងលើកពលទៅច្បាំងយករាជអាណាចក្រ គិន-លិនទៀត តែទ្រង់ព្រះឈួន ហើយទ្រង់សោយទីវង្គតក្នុងឱកាសនោះទៅ។

*(នៅមានត)*

*ដោយលោក* **សោម ខន**

# សាលារៀនគឺជាគ្រឹះស្ថានសង្គមមួយ (តចប់)

**២.ក្លឹបសង្គម(Social club)៖** សហគមន៍ត្រួតពិនិត្យសង្គម គេគួររៀបចំឡើងនៅក្នុងសាលារៀន ដើម្បីគេស៊ើបអង្កេតលើតម្រូវការសង្គមបច្ចុប្បន្ន និងបញ្ហាដែលនៅជុំវិញខ្លួនយើង។

ឧទាហរណ៍៖ ត្រួតពិនិត្យមើលលក្ខខណ្ឌផ្លូវថ្នល់ ភាគរយអ្នកមិនចេះអក្សរ ការបង្ហូរទឹកតាមដងផ្លូវ...។ល។

**៣.សេវាកម្មសមាជិកក្នុងសង្គម(Social Service survey)៖** សេវាកម្មសមាជិកក្នុងសង្គមត្រូវគេរៀបចំឡើងដូចជា ការសម្អាតផ្លូវថ្នល់ ការរៀបចំមជ្ឈមណ្ឌលសម្រាប់សាធារណជន សាងសង់ប្រព័ន្ធបង្ហូរទឹក ការយល់ដឹងពីសកម្មភាពខ្លះៗនៃតួនាទីសមាជិកក្នុងសង្គម។

**៤.មជ្ឈមណ្ឌលអប់រំសង្គម(Adult education Centre)៖** នៅពេលរសៀល ឬពេលព្រឹកថ្នាក់រៀនអក្សរសាស្ត្រសម្រាប់ជំទង់គួរគេចាប់ផ្តើមឡើងនៅក្នុងសាលារៀន។ លោក K.G.Salyidain បានវាយតម្លៃថាសាលារៀនគួរបង្កើតឱ្យមានការជួបគ្នារវាងគ្រូបង្រៀន និងឪពុកម្តាយសិស្ស ដើម្បីពិភាក្សាគ្នាជាមិត្តភាព ដោះស្រាយបញ្ហាសង្គម សេដ្ឋកិច្ច ការអប់រំ ដែលពួកគេត្រូវប្រឈម និងការចាប់អារម្មណ៍របស់គេ។

**៥.សាលារៀនជាមជ្ឈមណ្ឌលនៃការសម្រាក(The school as a recreational centre)៖** កម្មវិធីឈប់សម្រាកដូចជាការលេងល្បែង ល្ខោន ល្បែងសាកល្បងបញ្ញា...។ល។ សម្រាប់កុមារ និងជំទង់នៅក្នុងសហគមន៍ ត្រូវបានគេរៀបចំឡើង។ ការស្តាប់វិទ្យុ ការមើលភាពយន្ត ការតាំងពិព័រណ៍ត្រូវគេបង្កើតឡើង។

**៦.ការប្រារព្ធពិធីបុណ្យជាតិ និងបុណ្យប្រពៃណី(Celebration of national days and festivals)៖** មុខងារនៃពិធិបុណ្យជាតិ និងបុណ្យប្រពៃណី គួរគេរៀបចំឡើងនៅក្នុងសាលារៀន ក្នុងតំបន់ដើម្បីអញ្ជើញអ្នកជិតខាងចូលរួមជាពិសេសសិស្សសាលាក្នុងគោលដៅឱ្យពួកគេមើលឃើញពីតម្លៃនៃពិធីបុណ្យទាំងនោះ។

**៧.បណ្ណាល័យ និងបន្ទប់អាននៅក្នុងសាលារៀន(School library and reading room)៖** ជំទង់ត្រូវបានគេលើកទឹកចិត្តឱ្យចូលបណ្ណាល័យ ដើម្បីអានឯកសារបន្ទាប់ពីពួកគេបានសិក្សានៅសាលារៀនចប់។

**៨.ជាការភ្ជាប់គ្នារវាងគ្រូបង្រៀន និងឪពុកម្តាយសិស្ស(Parent-Teacher associations)៖** ការបង្កើតឡើងនូវការភ្ជាប់គ្នារវាងឪពុកម្តាយសិស្ស និងគ្រូបង្រៀន ត្រូវបានគេលើកទឹកចិត្តឱ្យកាន់តែទូលំទូលាយឡើង។

៩.កន្លែងកម្សាន្ត(Excursions)៖ តាមទស្សនៈលោក **L.K Kindred and O.W. Stephenson**បាននិយាយថា តម្លៃនៃការកម្សាន្តសម្រាប់សិស្ស គឺពង្រីកនូវចំណេះដឹងរបស់គេតាមរយៈការកម្សាន្តដែលរៀបចំឡើងដោយសាលារៀនក្នុងទិសដៅឱ្យសិស្សបានមើលឃើញនូវទិដ្ឋភាពក្នុងសហគមន៍ដែលគេប្រដូចទៅនឹងមន្ទីរពិសោធន៍មួយ ដើម្បីស្វែងរកការពិតនូវអ្វីដែលគេបានរៀននៅក្នុងសាលា និងអ្វីដែលគេមិនបានរៀនតាមកម្មវិធីសិក្សា ពេលនេះពួកគេនឹងបានរៀនបានឃើញ។ ដំណើរកម្សាន្តនឹងនាំមកនូវតថភាពទាំងឡាយដែលគេបានរៀនក្នុងសាលារៀនរួចហើយ។

១០.ប្រសិទ្ធភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ(Vocational efficiency)៖ ឱកាសគួរត្រូវបានគេផ្តល់ឱ្យតាមរយៈសាលារៀនដើម្បីលើកកម្ពស់ប្រសិទ្ធភាពវិជ្ជាជីវៈរបស់សិស្សបន្ទាប់ពីពួកគេបានបញ្ចប់ការសិក្សា។

## ខ.តួនាទីនាយកសាលា(Role of the Principal)

តាមការវាយតម្លៃកន្លងមកនេះ នាយកសាលា និងគ្រូបង្រៀនត្រូវតែស្វែងរកនូវលទ្ធភាពគ្រប់បែបយ៉ាងក្នុងការទាក់ទងសាលារៀនជាមួយសហគមន៍។ លោក D.D Rever បាននិយាយនៅក្នុងអត្ថបទមួយដែលមានចំណងជើងថា ការបកស្រាយរបស់នាយកសាលារៀនរបស់លោក **(Principal Interprets his school)** កម្មវិធីទំនាក់ទំនងជាសាធារណៈមួយគួរតែធ្វើបន្ត ជៀសវាងការបញ្ចប់សម្រាប់តែតម្រូវការបន្ទាន់។ កម្មវិធីសិក្សានេះ គេត្រូវធ្វើឡើងពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយឆ្នាំទៅមួយឆ្នាំរាប់ទាំងរដូវក្តៅ និងរដូវត្រជាក់ផងដែរ។

លោក **Jacobson** បាននិយាយថា នាយកសាលាមធ្យមសិក្សាសព្វថ្ងៃ ប្រសិនជាលោកបានផ្តល់នូវកម្មវិធីអប់រំ ត្រូវតែបង្ហាញនូវឧត្តមភាពដែលទាក់ទងជាមួយតម្រូវការនៃការយល់ដឹងរបស់សហគមន៍។ កម្មវិធីសិក្សាត្រូវតែមានទំនាក់ទំនងជាមួយវត្ថុបំណងនៃទស្សនវិជ្ជាអប់រំសម័យទំនើប។នៅវិទ្យាល័យសព្វថ្ងៃនេះ គឺជាផ្នែកមួយដែលទ្រទ្រង់សហគមន៍ដោយផ្តោតលើសកម្មភាពរបស់វា។ បើពុំដូច្នោះទេ ការគាំទ្រសាលារៀនជាសាធារណៈមិនអាចបំពេញមុខងារ និងចូលរួមចំណែកជាសាធារណៈ ដើម្បីលើកកម្ពស់ចំណេះដឹងសិស្សបាននោះទេ។

ដូច្នេះ សាលារៀនគឺពិតជាគ្រឹះស្ថានសង្គមដែលបានប្រមូលផ្តុំនូវព័ត៌មានច្រើនបែបច្រើនយ៉ាងតាមរយៈសមាជិកម្នាក់ៗក្នុងគ្រួសារ ដែលមានភារកិច្ចផ្សេងៗគ្នាទៅតាមមុខងារទីទៃពីគ្នា៕

*លោក* **គួយ សូគាន**

*សាស្ត្រាចារ្យវិទ្យាស្ថានជាតិអប់រំ*



## សុត្តន្តប្រីជាឥន្ទ (១៨៥៩-១៩២៤)

ឧកញ៉ាសុត្តន្តប្រីជាឥន្ទ កំណើតកើតនៅស្រុកទន្លេធំ គឺភូមិរកាកោង ខេត្តមុខកំពូល មាតាឈ្មោះយាយមុំ បិតាឈ្មោះបញ្ចង់កែ ឧកញ៉ាកើតថ្ងៃច័ន្ទ ខែអាសាធ ឆ្នាំរកា ពុទ្ធសករាជកន្លងទៅបាន២៤០៣វស្សា គឺថ្ងៃ២២ ស៊ូយេត(១) ឆ្នាំ១៨៥៩។ កាលអាយុ១០ឆ្នាំ នៅវត្តសិក្សាអក្សរខ្មែរ អាយុ១៥ឆ្នាំចេញរៀនប្រែព្រះបរិយត្ត បួសជាសាមណេរនៅវត្តព្រែកពោធិ៍ បួសបាន១វស្សា សឹកចាកភេទជាសាមណេរ រួចទៅរៀននឹងលោកព្រះអាចារ្យ ពេជ ស្រុកព្រះត្រពាំង អាយុ១៨ឆ្នាំទៅរៀននឹងលោកគ្រូព្រះពុទ្ធឃោសាចារ្យ ប្រាក់ វត្តឧណ្ណាលោម ក្រុងភ្នំពេញ អាយុ១៩ឆ្នាំ ទៅរៀននឹងលោកគ្រូព្រះអាចារ្យ សុខ វត្តកែវ ស្រុកបាត់ដំបង អាយុ២០ឆ្នាំបានបួសជាភិក្ខុនៅវត្តកែវ ១វស្សា ទើបលាព្រះឧបជ្ឈាយាចារ្យទៅរៀននៅស្រុកបាងកក ក្រុងស្យាម រៀនបាន៧វស្សា ក៏វិលមកស្រុកខ្មែរវិញ ក្នុងចំណោមលោកព្រះយ៉ាថាថន (ញ៉ុញ) នៅវត្តកណ្ដាល ស្រុកបាត់ដំបង រួមបាន១០វស្សា លាសិក្ខាបទសឹកមកមានបុត្រភរិយានៅភូមិផ្សាធំ លោកកថាថន (ឈុំ) ចិញ្ចឹមជាទីហ្លួងវិចិត្រវោហារបានតែងបានប្រែបាលីជាសម្រាយមានឈ្មោះ ៤៤ឈ្មោះ ជាសៀវភៅខ្លះ ចារស្លឹករឹតខ្លះ លុះអាយុបាន៥៥ឆ្នាំរាជការក្រុងភ្នំពេញឱ្យមកយកតាំងទីជាឧកញ៉ាសុត្តន្តប្រីជា ប្រោសឱ្យជួយតែងសព្វវចនាធិប្បាយខ្មែរនៅទីសាលាបាលី ក្នុងរវាងអាយុ៥៥ឆ្នាំដល់អាយុ៦៥ឆ្នាំ បានលារាជការវិលមកនៅស្រុកបាត់ដំបងវិញ លុះនៅថ្ងៃ១០ កើត ខែអស្សុជ ឆ្នាំជូត ឆស័ក មានរោគក្អកបណ្ដាកូនចៅរាល់គ្នាប្រតិបត្តិប្រកបថ្នាំរកគ្រូរក្សាពុំចេះធូរឡើយ លុះដល់ថ្ងៃអាទិត្យ ១២កើត ខែកត្តិក ឆ្នាំជូតឆស័ក ក៏ទទួលអនិច្ចកម្មនៅវេលាម៉ោង ៨ព្រឹក គឺថ្ងៃ៨ណូវ៉ែម(២) ឆ្នាំ១៩២៤៕

*លោក* **យស់ អ៊ាន**

*ដកស្រង់ចេញពីសៀវភៅគតិលោកភាគទី១*

*១.ស៊ូយេត : ខែកក្កដា (២)ណូវ៉ែម : ខែវិច្ឆិកា (ពាក្យបារាំង)*

# ប្រវត្តិ "បឹងត្របែក"

បឹងត្របែក ស្ថិតនៅក្នុងសង្កាត់លេខ៥ ក្រុងភ្នំពេញ បច្ចុប្បន្នជាសង្កាត់បឹងត្របែក ក្នុងខ័ណ្ឌចំការមនរាជធានីភ្នំពេញ។បើយោងតាមសព្វខាងលើ គេមិនពិបាកយល់ទេ គឺពិតជាបឹងដែលមានដើមត្របែកដុះច្រើនហើយ។ តែត្រង់ថាខុស ឬត្រូវទៅតាមប្រវត្តិពិតឬយ៉ាងណានោះ លុះណាតែបានអានប្រជុំរឿងព្រេងខ្មែរភាគ៦ទំព័រ១៣៩-១៤៤ដែលបានដកស្រង់ពីក្នុងសៀវភៅព្រះរាជពង្សសាវតាច្បាប់សរសេរដៃតម្កល់នៅពុទ្ធសាសនបណ្ឌិតដែលមានសេចក្តីដូចខាងក្រោមនេះសិនះ

ព្រះបាទជ័យជេដ្ឋា (ព្រះអង្គសូរ) ព.ស.២២១៩ គង់នៅឧត្តុង្គឮជ័យ បានសាងវាំង១ទៀតនៅទួលឪជ្រឹង ស្រុកសំរោងទងសព្វថ្ងៃ ព្រះអង្គរើព្រះរាជវាំងពីឧត្តុង្គឮជ័យមកគង់នៅព្រះរាជវាំងទួលឪជ្រឹង ទុកព្រះមាតា គឺសម្តេចព្រះទាវ ឱ្យគង់នៅឯឧត្តុង្គឮជ័យ។ ឯសម្តេចព្រះបទុមរាជាមហាឧបរាជ ទ្រង់ជ្រាបព័ត៌មាននេះហើយ ក៏មានព្រះទ័យត្រេកអរជាពន់ពេក ហើយប្រឹក្សាជាមួយអុងយួន រួចលើកទ័ពខ្មែរ-យួនទៅលុកវាំងឧត្តុង្គឮជ័យ ហើយចាប់យកសម្តេចព្រះទាវជាព្រះវររាជមាតានៃព្រះជ័យជេដ្ឋា និងនាងអំ ជាសាវឡិក នាំយកទៅនៅបន្ទាយជ្រោយចង្វា។ ព្រះជ័យជេដ្ឋាដែលគង់នៅវាំងទួលឪជ្រឹង កាលបើទ្រង់ជ្រាបការណ៍នេះហើយ ទ្រង់ព្រះកន្សែងសោយសោកអាឡោះអាល័យពីការនិរាសព្រាត់ព្រះវរមាតា។ ព្រះអង្គរើព្រះរាជដំណាក់ពី ព្រះរាជវាំងទួលឪជ្រឹងទៅគង់ឧត្តុង្គឮជ័យវិញ។ ព្រះអង្គទ្រង់បានប្រឹក្សាជាមួយសេនាបតី នាម៉ឺនសព្វមុខមន្ត្រីឱ្យប្រមូលទ័ពទៅច្បាំងជាមួយទ័ពខ្មែរ-យួន ដែលនៅជ្រោយចង្វា ដើម្បីដណ្តើមយកព្រះវររាជមាតាមកវិញ។ មន្ត្រីក៏ប្រមូលទ័ពបានគ្រប់ចំនួនហើយ ព្រះអង្គទ្រង់ព្រះចិន្តាថា លើកទ័ពទៅវាយទ័ពយួន ដែលមានព្រះវររាជមាតានៅជាមួយផងមិនស្រួលទេ។ គិតដូច្នេះ ព្រះអង្គទ្រង់កែព្រះរាជមធ្យោបាយ។ ព្រះអង្គទ្រង់ប្រឹក្សាជាមួយពញាមន្ត្រីសង្គ្រាមសួស្តី ដើម្បីទៅយកព្រះវររាជមាតា។ ចៅពញាមន្ត្រីសង្គ្រាមសួស្តីថ្វាយព្រះរាជយោបល់ថា មានតែប្អូនទូលព្រះបង្គំ ឈ្មោះពញាភក្តី សង្គ្រាមហុកទេដែលមានថ្វីដៃ អាចទៅយកព្រះវររាជមាតាព្រះអង្គបាន។ ចៅពញាភក្តីសង្គ្រាមហុក ទទួលព្រះរាជបញ្ជាហើយ ក៏សន្យានឹងព្រះជ័យជេដ្ឋាថា តែ ៧ ថ្ងៃនឹងធ្វើការនេះឱ្យបានសម្រេច ហើយសូមព្រះអង្គឱ្យទ័ពទៅចាំទទួល។ ចៅពញាសង្គ្រាមហុក សុំយកទាសាជំនិតម្នាក់ឈ្មោះគោ និងសុនខមួយឈ្មោះអាស្រគំទៅជាមួយ។ ចៅពញាភក្តីសង្គ្រាមហុក ធ្វើដំណើរទៅដល់ភ្នំពេញហើយទៅសំណាក់ក្នុងវត្តស្រកាលេញ រួចដើរស៊ើបយកការណ៍ រហូតដល់បានព័ត៌មានថា ទ័ពយួនទុកសម្តេចព្រះទាវក្នុងទូកនៅឯជ្រោយចង្វា។ នៅវេលាយប់ស្ងាត់ មេឃងងឹតរកកល់ចង់ភ្លៀងផងចៅពញាភក្តីសង្គ្រាមយកទៀនធូបភ្ញីផ្កាខ្លះលបចូលទៅក្នុងព្រះវិហារវត្តស្រកាលេញហើយតាំងអធិដ្ឋានថា: ខ្ញុំព្រះអង្គនេះមានចិត្តកតញ្ញូនឹងព្រះបាទជាអម្ចាស់ ស៊ូលះបង់ជីវិតមិនគិតស្លាប់ទទួលមកអញ្ជើញសម្តេចព្រះទាវជាព្រះវររាជមាតាពី កណ្តាប់ដៃនៃសត្រូវបើសម្តេចព្រះជ័យជេដ្ឋាជា

អម្ចាស់ខ្ញុំ ស្ដេចបានសោយរាជ្យសម្បត្តិក្នុងក្រុងកម្ពុជាធិបតីនេះ សូមកុំឱ្យទ័ពយួនឃើញស្គាល់ខ្ញុំអម្ចាស់ឡើយ ដោយសេចក្ដីកតញ្ញូរបស់ខ្ញុំ សូមកុំឱ្យមានអន្តរាយអ្វីសូមទេវតាជួយទំនុកបម្រុង សូមឱ្យខ្ញុំទៅអញ្ជើញសម្ដេចព្រះទាវ ជាព្រះវររាជមាតាពីក្នុងចំណោមកងទ័ពសង្គ្រាមបានដោយងាយ។ លុះចប់ការតាំងអធិដ្ឋានហើយ ចៅពញាភក្ដីសង្គ្រាមហុក នាំនាយគោចេញពីព្រះវិហារ ហើយផ្ដាំឱ្យអាស្រគំចាំនៅមុខព្រះវិហារនេះ។ អ្នកផ្សងសំណាងទាំងពីរនាក់ផ្លាស់សំពត់យកចងទ្រូង ហើយយកកាំបិតស្នៀតសៀតនឹងចង្កេះ ដើររកឫស្សីហែលឆ្លងទៅជ្រោយចង្វា។ ចៅពញាភក្ដីសង្គ្រាមឆ្លងដល់ត្រើយហើយ ពួនតាមមាត់ទន្លេតម្រង់ទៅរកទូកយួន។ លួនបណ្ដើរសែកមន្តគាថាសណ្ដំទ័ពយួនបណ្ដើរ ចៅពញាភក្ដីសង្គ្រាមហុកបានទៅដល់ទូកដែលសម្ដេចព្រះទាវផ្ទំ។លោកបានឃើញសម្ដេចព្រះទាវហើយ ក៏ចូលទៅដាស់ព្រះអង្គ ហើយថ្វាយចិញ្ចៀនព្រះទម្រង់ដែលព្រះជ័យជេដ្ឋាទ្រង់បានផ្ញើឱ្យយកទៅថ្វាយសម្ដេចព្រះមាតាជាបន្ទាល់។ សម្ដេចព្រះទាវ ទតឃើញសេនារបស់ព្រះអង្គទ្រង់មានសេចក្ដីរំភើបជាទីបំផុត។ ចៅពញាភក្ដីសង្គ្រាមហុកតឿនព្រះអង្គឱ្យចេញពីទូកយួនជាប្រញាប់។ តែព្រះអង្គមានព្រះរាជសវនីយ៍ទៅកាន់ចៅពញាសង្គ្រាមថា ឱ្យទៅយកនាងអាំជាភីលៀងមកជាមួយផង ព្រោះធ្លាប់កម្សត់ជាមួយព្រះអង្គ។ ចៅពញាភក្ដីសង្គ្រាមហុកនាំសម្ដេចព្រះទាវ និងនាងអាំចេញពីទូកបានហើយមេឃងងឹតឈឹងរកមើលទិសតំបន់អ្វីមិនឃើញ ក៏បញ្ជាឱ្យនាយគោផ្ទៀងចាំស្ដាប់អាស្រគំលូ។ ផ្ទៀងសំឡេងឆ្កែលូជាក់ច្បាស់ហើយ ចៅពញាសង្គ្រាមហុកនាំគ្នាហែលឆ្លងមកត្រើយភ្នំពេញវិញ។ លុះដល់ត្រើយហើយ សម្ដេចព្រះទាវយាងទៅសម្រាកព្រះកាយបន្តិច ក្នុងវត្តស្រកាលេញ ហើយបន្តព្រះរាជដំណើរទៅទៀត ចៅពញាសង្គ្រាមហុក បញ្ជិះសម្ដេចព្រះទាវ ហើយឱ្យនាយគោ នាងអាំ អាស្រគាំដើរទៅមុខតម្រង់ទៅឧត្តុង្គឫជ័យ។ តែពេលនោះមេឃងងឹតពេក ចៅពញាសង្គ្រាមមើលផ្លូវពុំច្បាស់ចេញពីវត្តស្រកាលេញទៅដោយព្រាវ ទៅដល់បឹងត្របែកសព្វថ្ងៃនេះ ឃើញផ្លូវបែក នាយគោងាកមកសួរចៅហ្វាយនាយថា តើត្រូវដើរទៅតាមផ្លូវណា?។ ចៅពញាសង្គ្រាមហុក ក៏បញ្ជាឱ្យនាយគោបែកទៅស្ដាំ។ កន្លែងដែលមានផ្លូវបែកនេះ មានសភាពទំនាបជាបឹងទើបហៅថា "បឹងត្រង់បែក"។ ពាក្យថា "បឹងត្រង់បែក"នេះ អ្នកស្រុកនិយាយរហ័សក៏ឮតែបឹងត្របែកៗទៅវិញ។ សំដីនេះក៏ចេះតែក្លាយទៅៗរហូតដល់បាត់ន័យ ដើមរបស់ពាក្យដូច្នេះ។ លុះភ្លឺឡើងទៅដល់ស្ទឹងព្រែកត្នោត ទើបចៅពញាសង្គ្រាមដឹងថាវង្វេងផ្លូវ។ ហើយនាំគ្នាបែរមុខទៅរកទិសទៅកាន់ឧត្តុង្គឫជ័យវិញ។ ទីនេះក៏ជាប់ឈ្មោះថា បឹងត្របែក រហូតមក៕

*ដកស្រង់ដោយលោក* **យស់ អ៊ាខ**

# ក្រុង.ស្រុក.ខណ្ឌ-ឃុំ-សង្កាត់នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១២(ត)

| ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ | ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ | ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ | ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ |
|---|---|---|---|---|---|---|---|
| **១៦** | **ខេត្តរតនគិរី** | | ២.ប៉ូយ | | ១.ចារឈូក | | ១១.សង្វើយ |
| ១ | ស្រុកអណ្ដូងមាស | | ៣.ឯកភាព | | ២.ដូនពេង | | ១២.ស្ពានត្នោត |
| | មាន ៣ ឃុំ៖ | | ៤.កាឡៃ | | ៣.គោកដូង | ៥ | ស្រុកក្រឡាញ់មាន |
| | ១.ម៉ាលិក | | ៥.អូរជុំ | | ៤.គោល | | ១០ឃុំ៖ |
| | ២.ញ៉ាង | | ៦.សាមគ្គី | | ៥.នគរភាស | | ១.ចន្លាសដៃ |
| | ៣.តាឡាវ | | ៧.ល្អក់ | | ៦.ស្រែខ្វាវ | | ២.កំពង់ថ្កូវ |
| ២ | ក្រុងបានលុង មាន៤ | ៧ | ស្រុកអូរយ៉ាដាវមាន | | ៧.តាសោម | | ៣.ក្រឡាញ់ |
| | សង្កាត់៖ | | ៧ឃុំ៖ | ២ | ស្រុកអង្គរធំមាន | | ៤.ក្រូចគរ |
| ៣ | ស្រុកបរកែវមាន ៦ | | ១.បរខាំ | | ៤ឃុំ៖ | | ៥.រោងគោ |
| | ឃុំ៖ | | ២.លំជ័រ | | ១.ជប់តាត្រាវ | | ៦.សំបួរ |
| | ១.កក់ | | ៣.ប៉ក់ញ៉ែ | | ២.លាងដៃ | | ៧.សែនសុខ |
| | ២.កិះចុង | | ៤.ប៉ាតេ | | ៣.ពាក់ស្នែង | | ៨.ស្នួល |
| | ៣.ឡាមីញ | | ៥.សេសាន | | ៤.ស្វាយចេក | | ៩.ស្រណាល |
| | ៤.លុងឃុង | | ៦.សោមធំ | ៣ | ស្រុកបន្ទាយស្រីមាន | | ១០.តាអាន |
| | ៥.សើុង | | ៧.យ៉ាទុង | | ៦ឃុំ៖ | ៦ | ស្រុកពួកមាន |
| | ៦.ទីងចាក់ | ៨ | ស្រុកតាវែងមាន២ | | ១.ខ្នារសណ្ដាយ | | ១៤ឃុំ៖ |
| ៤ | ស្រុកកូនមុំមាន៦ឃុំ៖ | | ឃុំ៖ | | ២.ឃុនរាម | | ១.សសរស្ដម្ភ |
| | ១.សិរីមង្គល | | ១.តាវែងលើ | | ៣.ព្រះដាក់ | | ២.ដូនកែវ |
| | ២.ស្រែអង្គ្រង | | ២.តាវែងក្រោម | | ៤.រំចេក | | ៣.ក្ដីរុន |
| | ៣.តាអង | ៩ | ស្រុកវើនសៃមាន | | ៥.រុនតាឯក | | ៤.កែវពណ៌ |
| | ៤.តឺន | | ៩ឃុំ៖ | | ៦.ត្បែង | | ៥.ខ្នាត |
| | ៥.ត្រពាំងច្រេស | | ១.ប៉ុង | ៤ | ស្រុកជីក្រែងមាន | | ៦.ល្វា |
| | ៦.ត្រពាំងក្រហម | | ២.ហាត់ប៉ក់ | | ១២ឃុំ៖ | | ៧.មុខប៉ែន |
| ៥ | ស្រុកលំផាត់មាន | | ៣.កាចូន | | ១.អន្លង់សំណរ | | ៨.ពោធិទ្រាយ |
| | ៦ឃុំ៖ | | ៤.កោះប៉ង់ | | ២.ជីក្រែង | | ៩.ពួក |
| | ១.ជ័យឧត្ដម | | ៥.កោះពាក្យ | | ៣.កំពង់ក្ដី | | ១០.ព្រៃជ្រូក |
| | ២.កាឡែង | | ៦.កុកឡាក់ | | ៤.ខ្វាវ | | ១១.រើល |
| | ៣.ល្បាំង១ | | ៧.ប៉ាកាឡាន់ | | ៥.គោកធ្លកក្រោម | | ១២.សំរោងយា |
| | ៤.ល្បាំង២ | | ៨.ភ្នំកុក | | ៦.គោកធ្លកលើ | | ១៣.ត្រីញ័រ |
| | ៥.បាតាង | | ៩.វើនសៃ | | ៧.ល្វែងឫស្សី | | ១៤.យាង |
| | ៦.សេដា | **១៧** | **ខេត្តសៀមរាប** | | ៨.ពង្រក្រោម | ៧ | ប្រាសាទបាគងមាន |
| ៦ | ស្រុកអូរជុំមាន៧ឃុំ៖ | ១ | ស្រុកអង្គរជុំមាន | | ៩.ពង្រលើ | | ៨ឃុំ៖ |
| | ១.ចាអ៊ុង | | ៧ឃុំ៖ | | ១០.ឫស្សីលក | | ១.បាគង |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.បល្ល័ង្គ | ១១ | **ស្រុកស្វាយលើមាន** | | ១២.ទឹកថ្លា | | ៣.កោះស្រឡាយ |
| | ៣.កំពង់ភ្លុក | | **៥ឃុំ៖** | | ១៣.ទួលទទឹង | | ៤.អូរម្រះ |
| | ៤.កន្ទ្រាំង | | ១.បឹងមាលា | | ១៤.វាលរេញ | | ៥.អូរឬស្សីកណ្ដាល |
| | ៥.កណ្ដែក | | ២.កន្ទួត | ៣ | **ស្រុកស្ទឹងហាវមាន** | | ៦.សៀមបូក |
| | ៦.មានជ័យ | | ៣.ខ្នងភ្នំ | | **៤ឃុំ៖** | | ៧.ស្រែក្រសាំង |
| | ៧.រលួស | | ៤.ស្វាយលើ | | ១.កំពេញ | ២ | **ស្រុកសៀមប៉ាងមាន** |
| | ៨.ត្រពាំងធំ | | ៥.តាសៀម | | ២.អូរត្រេះ | | **៥ឃុំ៖** |
| ៨ | **ក្រុងសៀមរាបមាន** | ១២ | **ស្រុកវ៉ារិនមាន៥ឃុំ៖** | | ៣.ទំនប់រលក | | ១.ព្រែកមាស |
| | **១៣សង្កាត់** | | ១.ប្រាសាទ | | ៤.កែវផុស | | ២.សេកុង |
| ៩ | **ស្រុកសូត្រនិគមមាន** | | ២.ល្វាក្រាំង | ៤ | **ស្រុកកំពង់សីលា** | | ៣.សន្តិភាព |
| | **១០ឃុំ៖** | | ៣.ស្រែណូយ | | **មាន៤ឃុំ៖** | | ៤.ស្រែសំបូរ |
| | ១.ចាន់ស | | ៤.ស្វាយស | | ១.ចំការហ្លួង | | ៥.ថ្មកែវ |
| | ២.ដំដែក | | ៥.វ៉ារិន | | ២.កំពង់សីលា | ៣ | **ក្រុងស្ទឹងត្រែងមាន៤** |
| | ៣.ដានរុន | **១៨** | **ខេត្តព្រះសីហនុ** | | ៣.អូរបាក់រទេះ | | **សង្កាត់** |
| | ៤.កំពង់ឃ្លាំង | ១ | **ក្រុងព្រះសីហនុមាន** | | ៤.ស្ទឹងឆាយ | ៤ | **ស្រុកថាឡាបរិវ៉ាត់** |
| | ៥.កៀនសង្កែ | | **៥សង្កាត់** | **១៩** | **ខេត្តស្ទឹងត្រែង** | | **មាន១១ឃុំ៖** |
| | ៦.ខ្ចាស់ | ២ | **ស្រុកព្រៃនប់មាន** | ១ | **ស្រុកសេសានមាន** | | ១.អន្លង់ភេ |
| | ៧.ខ្នារពោធន៍ | | **១៤ឃុំ៖** | | **៧ឃុំ៖** | | ២.ចំការលើ |
| | ៨.ពពេល | | ១.អណ្ដូងថ្ម | | ១.កំភុន | | ៣.កាំងចាម |
| | ៩.សំរោង | | ២.បឹងតាព្រហ្ម | | ២.ក្បាលរមាស | | ៤.កោះស្នែង |
| | ១០.តាយ៉ែក | | ៣.បិតត្រាំង | | ៣.ភ្លុក | | ៥.អន្លង់ជ្រៃ |
| ១០ | **ស្រុកស្រីស្នំមាន** | | ៤.ជើងគោ | | ៤.សាមឃួយ | | ៦.អូររ៉ៃ |
| | **៦ឃុំ៖** | | ៥.អូរជ្រៅ | | ៥.ស្ដៅ | | ៧.អូរស្វាយ |
| | ១.ជ្រោយនាងនួន | | ៦.អូរឧកញ៉ាហេង | | ៦.ស្រែគរ | | ៨.ព្រះរំកិល |
| | ២.ក្លាំងហាយ | | ៧.ព្រៃនប់ | | ៧.តាឡាត | | ៩.សំអាង |
| | ៣.ត្រាំសសរ | | ៨.រាម | ២ | **ស្រុកសៀមបូកមាន** | | ១០.ស្រែឬស្សី |
| | ៤.មោង | | ៩.សាមគ្គី | | **៧ឃុំ៖** | | ១១.ថាឡាបរិវ៉ាត់ |
| | ៥.ប្រីយ៍ | | ១០.សំរុង | | ១.កោះព្រះ | | |
| | ៦.ស្ពែងស្ពាន | | ១១.ទឹកល្អក់ | | ២.កោះសំពាយ | | |

(នៅមានត)

ដោយលោកស្រី **គុយ ផល្លា**

ពុក និងម៉ែ កែតប៉ុណ្ណោះ ចេះតែចាស់
ប្រាកដណាស់ ច្បាស់ជាព្រាត់ ឃាត់មិនបាន
កូនត្រូវខំ នាំ វិជ្ជា មកដាក់ប្រាណ
ទើបកូនបាន ទីពំនឹង ពឹងអាស្រ័យ។

**អនាមិក**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការកណ្តាល
លេខ: ០១ /១៥គ.ក

## សេចក្តីជូនដំណឹងមរណៈភាពប្រចាំខែ ធ្នូ ឆ្នាំ២០១៤
## តាងនាមសមាគមបុគ្គលិកសិក្សាខ្មែរទាំងមូលគណៈកម្មាធិការកណ្តាលនៃ ស.ប.ស.ខ.
## សូមសម្តែងក្តីសោកស្តាយជាទីបំផុតចំពោះការបាត់បង់ជីវិតនៃមិត្តយើង និង

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបម្រើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | សពទី |
|---|---|---|---|---|---|---|---|---|---|
| | | | | | ក.មរណៈភាពសមាជិក | | | | |
| 1 | កង ហ៊ីន | ៦៧ | ប | គ្រូ | និវត្ត.បឋមសុវណ្ណគីរីស្មីស្រុកឈូក ខេត្តកំពត | ១០-១០-១៤ | ជរាពាត | ៣៧០៨កព | ១០០១១ |
| 2 | ប៉ាង តី | ២៤ | ស | បឋម | បឋមវត្តលំពូ ស្រុកកំពង់ត្រាច ខេត្តកំពត | ១១-១០-១៤ | ជម្ងឺបេះដូង | ៧៥៣៩កព | ១០០១២ |
| 3 | យ៉ែម វឌ្ឍនា | ៣០ | ប | ម.បក | អនុវិទ្យាល័យកោះរ៉ាំង ស្រុកបន្ទាយមាស កំពត | ០៩-១០-១៤ | ចងកសម្លាប់ខ្លួន | ៦៥៥៣កព | ១០០១៣ |
| 4 | ម៉ម យឿន | ៦៨ | ប | គ្រូ | និវត្តជន.កោះតាស៊ុយ ស្រុកព្រែកប្រសព្វ ក្រចេះ | ១៨-១០-១៤ | ជរាពាត | ០៣៣៤ក្រច | ១០០១៤ |
| 5 | ខេ ធីតា | ៤៧ | ស | បឋម | បឋមឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ | ១៨-១០-១៤ | ជរាពាត | ១៦៥៥ក្រច | ១០០១៥ |
| 6 | ចាន់ ថុន | ៥៥ | ប | បឋម | បឋមអណ្តូងពោធិ៍ ស្រុករមាសហែក ស្វាយរៀង | ១៥-០៩-១៤ | គ្រោះថ្នាក់ចរាចរ | ១០១១ស្វរ | ១០០១៦ |
| 7 | ងួន សាឌឿន | ៦៤ | ប | គ្រូ | និវត្តជនស្រុកស្វាយទាប ខេត្តស្វាយរៀង | ០៦-១០-១៤ | គាំងបេះដូង | ២០៤៦ស្វរ | ១០០១៧ |
| 8 | នួន ភី | ៦៥ | ប | គ្រូ | និវត្តជនស្រុករមាសហែក ខេត្តស្វាយរៀង | ១២-១០-១៤ | លើសឈាម | ៩៦៥ស្វរ | ១០០១៨ |
| ៩ | គង់ ដូរ៉ាភីគុល | ៧០ | ប | គ្រូ | និវត្តជនម.អ.យ.ក ខេត្តកំពង់ធំ | ០៧-០៦-១៤ | ជរាពាធ | ៤១៥៥កធ | ១០០១៩ |
| ១០ | លាម សារុន | ៦៩ | ប | គ្រូ | និវត្តជនម.អ.យ.ក ខេត្តកំពង់ធំ | ០៦-០៧-១៤ | ជរាពាធ | ៤០៩៧កធ | ១០០២០ |
| ១១ | កែវ និន | ៦៨ | ប | គ្រូ | និវត្តជនការិអយក ស្រុកស្ទោង ខេត្តកំពង់ធំ | ០៦-០៧-១៤ | ជរាពាធ | ២២៤២កធ | ១០០២១ |
| ១២ | ញ៉េប ឈន | ៦១ | ប | គ្រូ | និវត្តជនការិអយក ស្រុកប្រាសាទ ខេត្តកំពង់ធំ | ០៣-០៥-១៤ | ជរាពាធ | ២៣៩១កធ | ១០០២២ |
| ១៣ | ចាន់ ខេន | ៤៨ | ប | បឋម | បឋមបារៀង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ | ០៥-០៥-១៤ | ធ្លាក់ពីលើផ្ទះ | ២៥៨០កធ | ១០០២៣ |
| ១៤ | ទុក ម៉ង់ | ៦៨ | ប | គ្រូ | និវត្តជនបឋមខ្សាច់ ស្រុកល្វាឯម ខេត្តកណ្តាល | ០៥-១០-១៤ | ជរាពាធ | ២៦០៥កណ | ១០០២៤ |
| ១៥ | ចាន់ សែម | ៨២ | ប | គ្រូ | និវត្តជនស្រុកល្វាឯម ខេត្តកណ្តាល | ០៨-១០-១៤ | ជរាពាធ | ២៨៥៧កណ | ១០០២៥ |
| ១៦ | កែវ មាស | ៦៧ | ប | គ្រូ | និវត្តជនស្រុកអង្គស្នួល ខេត្តកណ្តាល | ១២-១០-១៤ | ជរាពាធ | ៦៤៧១កណ | ១០០២៦ |
| ១៧ | ផាង ផាកហួត | ៦៨ | ប | គ្រូ | និវត្តជនស្រុកអង្គស្នួល ខេត្តកណ្តាល | ១៥-០៩-១៤ | ជរាពាធ | ៥២៨១កណ | ១០០២៧ |
| ១៨ | អ៊ុក សាវុន | ៦៥ | ប | គ្រូ | និវត្តជនស្រុកពញាព ខេត្តកណ្តាល | ១០-១០-១៤ | ជរាពាធ | ១៨៧៩កណ | ១០០២៨ |
| ១៩ | កឹម សុធី | ៦២ | ប | គ្រូ | និវត្តជន ស្រុកអង្គស្នួល ខេត្តកណ្តាល | ១៤-១០-១៤ | ជរាពាធ | ៥២៤៤កណ | ១០០២៩ |
| ២០ | ជា ចាន់ដារ៉ា | ២៤ | ស | បឋម | បឋមតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប | ១០-០៩-១៤ | មហារីក.ឈាម | ៨៧៦០ សរ | ១០០៣០ |
| ២១ | ម៉ាក សុធារី | ៥៨ | ស | បឋម | បឋមហ៊ុននាង ទួលទំពូងទី២ ចំការមន ភ្នំពេញ | ២៧-០៩-១៤ | ជរាពាធ | ៤៣៦៥ភព | ១០០៣១ |
| ២២ | អៀវ ស៊ីន | ៧០ | ប | គ្រូ | និវត្តជនមអយក រាជធានីភ្នំពេញ | ០៣-១០-១៤ | ជរាពាធ | ០១៥ ភព | ១០០៣២ |
| ២៣ | ហេង គីមតិច | ៦០ | ប | គ្រូ | និវត្តជនវិទ្យាល័យវត្តភ្នំ រាជធានីភ្នំពេញ | ១៨-០៩-១៤ | ជរាពាធ | ៥៥៨៦ ភព | ១០០៣៣ |
| ២៤ | ស៊ាន វណ្ណា | ៤៤ | ប | គ្រូ | វិទ្យាល័យឫស្សីកែវ រាជធានីភ្នំពេញ | ១១-១០-១៤ | ទឹកនោមប្រៃ | ៩៧៤៩ ភព | ១០០៣៤ |
| ២៥ | ឱម សុខុន | ៦៣ | ស | គ្រូ | និវត្តជនបឋមប្រទះឡាង ដង្កោ ភ្នំពេញ | ១២-១០-១៤ | គាំងបេះដូង | ៥៦៨ ភព | ១០០៣៥ |
| ២៦ | ជា ថារិទ្ធ | ៦១ | ស | គ្រូ | និវត្តជនវិទ្យាល័យច្បារអំពៅ ភ្នំពេញ | ២១-១០-១៤ | គាំងបេះដូង | ១៩២៨ ភព | ១០០៣៦ |
| ២៧ | នឹម ម៉ារិន | ៣៩ | ស | បឋម | បឋមចៅពញាហុក ចំការមន ភ្នំពេញ | ០១-១១-១៤ | ជរាពាធ | ៣៩៥០ ភព | ១០០៣៧ |
| ២៨ | ឡាំ វ៉ន | ៦៦ | ប | គ្រូ | និវត្តជនការិអយក ស្រុកព្រះនេត្តព្រះ បន្ទាយ.ជ័យ | ១២-១០-១៤ | លើសឈាម | ១៩០៣បជ | ១០០៣៨ |
| ២៩ | ធឹង សំរិទ្ធ | ៧២ | ប | គ្រូ | និវត្តជនបឋមទំពសៀម ស.ស្វាយចេក បន្ទាយ.ជ | ០៦-១១-១៤ | គ្រោះថ្នាក់ចរាចរ | ១៩០៣ បជ | ១០០៣៩ |
| ៣០ | ពៅ ម៉ៅ | ៦២ | ប | គ្រូ | និវត្តជនបឋម អញ្ចាញ ស្រុកអូជ្រៅ បន្ទាយ.ជ | ០៧-១១-១៤ | ជរាពាធ | ២១២៣ បជ | ១០០៤០ |
| ៣១ | មោក ស៊ីម | ៨០ | ប | គ្រូ | និវត្តជន មអយក ខេត្តស្វាយរៀង | ០១-១១-១៤ | គាំងបេះដូង | ៣៦០៥ ស្វរ | ១០០៤១ |
| ៣២ | សុខ សារុន | ៧៥ | ប | គ្រូ | និវត្តជនបឋមក្បាលកោះ ស.ស្រីសន្ធរ កំពង់ចាម | ០៧-១០-១៤ | ជរាពាធ | ៧៣០១កច | ១០០៤២ |
| ៣៣ | អ៊ុង សាដ្ឋ | ៧៦ | ប | គ្រូ | និវត្តជនបឋមប្រិមប្រិយ៍ ព្រៃឈរ កំពង់ចាម | ១៣-១០-១៤ | ជរាពាធ | ២៧៣០ កច | ១០០៤៣ |
| ៣៤ | វ៉ុង ធឹម | ៨៧ | ប | គ្រូ | និវត្តជនបឋមមហាលាភ កោះសូទិន កំពង់ចាម | ២០-១០-១៤ | ជរាពាធ | ១៩១៥ កច | ១០០៤៤ |
| ៣៥ | នូ អ៊ាម | ៦៩ | ប | គ្រូ | និវត្តជនបឋមស្ពឺ(ក) ចំការលើ កំពង់ចាម | ០៨-១០-១៤ | ជរាពាធ | ៥៦៩៤កច | ១០០៤៥ |
| ៣៦ | ជិន ស៊ីផាន | ៦៨ | ស | ម/ត | និវត្តជនមត្តេយ្យស្រុក ចំការលើ កំពង់ចាម | ១៧-១០-១៤ | ជរាពាធ | ៦០៤៨កច | ១០០៤៦ |
| ៣៧ | គង់ ស៊ីថា | ៦៣ | ស | គ្រូ | និវត្តជនបឋមប្រជាកុមារ សួងក្រុងសួង ត្បូងឃ្មុំ | ០៦-១១-១៤ | ជរាពាធ | ៩៥៩៦កច | ១០០៤៧ |
| ៣៨ | អន យឿន | ៥៩ | ប | បឋម | បឋមបនហស ខ្សាក ពញាក្រែក ត្បូងឃ្មុំ | ០៧-១១-១៤ | ខ្យល់គរ | ៦៩២៤កច | ១០០៤៨ |
| ៣៩ | ឃ្លោក សារិន | ៦៦ | ប | គ្រូ | និវត្តជនបឋមពោធិរតនារាម ព្រះស្តេច ព្រៃវែង | ០៤-១០-១៤ | ជរាពាធ | ១១២២ពវ | ១០០៤៩ |
| ៤០ | នាង សារិន | ៧៤ | ប | គ្រូ | និវត្តជនព្រែកក្រឡាញ់ ស្រុកពារាំង ខេត្តព្រៃវែង | ១៧-១០-១៤ | ជរាពាធ | ៦៣៥៩ពវ | ១០០៥០ |
| ៤១ | អ៊ុក សារឿន | ៦៦ | ប | គ្រូ | និវត្តជនបឋមភូមិធំថ្មី កំពង់ត្របែក ព្រៃវែង | ០៤-១០-១៤ | លើសឈាម | ១៤៩២ពវ | ១០០៥១ |
| ៤២ | ហួង វណ្ណី | ៥៩ | ស | បឋម | បឋមបន្ទាយទឹក ស្រុកពារាំង ខេត្តព្រៃវែង | ១៨-១០-១៤ | ជរាពាធ | ៦១១២ពវ | ១០០៥២ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៤៣ | ហួត សារ៉ាត់ | ៧៩ | ប | គ្រូ | និវត្តជនបឋមព្រែកខ្លោង ពោធិរៀង ព្រៃវែង | ១០-១០-១៤ | ជរាពាធ | ១២៧៣៣ពវ | ១០០៥៣ |
| ៤៤ | ប៊ុន សេង | ៧៨ | ប | គ្រូ | និវត្តជនវិទ្យាល័យព្រះអង្គខ្វង ខេត្តព្រៃវែង | ១០-១០-១៤ | ជរាពាធ | ០២៩៣ពវ | ១០០៥៤ |
| ៤៥ | ហៃ រុង | ៣៩ | ប | ម.ដ្ឋា | បឋមបាបោង ស្រុកពោមរក៏ ខេត្តព្រៃវែង | ០៨-១០-១៤ | ជម្ងឺបេះដូង | ៧១៨៦ពវ | ១០០៥៥ |
| ៤៦ | ឡុង ចំរើន | ៤៤ | ប | ម.ដ្ឋា | វិទ្យាល័យហស កំពង់លាវ ខេត្តព្រៃវែង | ២៩-០៩-១៤ | ជរាពាធ | ២២១៣ពវ | ១០០៥៦ |
| ៤៧ | តាត់ ទូច | ៤៨ | ស | បឋម | បឋមអង្គសិង្ហ ស្រុកបាទី ខេត្តតាកែវ | ១៦-០៧-១៤ | គ្រោះថ្នាក់ចរាចរ | ១៣៤៧តក | ១០០៥៧ |
| ៤៨ | ហាក់ លឹម | ៦៧ | ប | គ្រូ | និវត្តជនស្រុកគីរីវង់ ខេត្តតាកែវ | ០៩-០៨-១៤ | ជរាពាធ | ៤១០៦តក | ១០០៥៨ |
| ៤៩ | អ៊ុំ សុន | ៧៣ | ប | គ្រូ | និវត្តជនស្រុកព្រៃកប្បាស ខេត្តតាកែវ | ១៨-០៨-១៤ | ជរាពាធ | ៥១១៤តក | ១០០៥៩ |
| ៥០ | ង៉ែត សារិន | ៦៨ | ប | គ្រូ | និវត្តជនស្រុកត្រាំកក់ ខេត្តតាកែវ | ០៣-០៧-១៤ | ជរាពាធ | ៥៥៩០តក | ១០០៦០ |
| ៥១ | អ៊ុន ឆេន | ៦៣ | ប | គ្រូ | និវត្តជនបឋមព្រៃអាន ស្រុកសំរោង ខេត្តតាកែវ | ០៩-០៨-១៤ | ជរាពាធ | ២៩៧០តក | ១០០៦១ |
| ៥២ | ភិន យ៉ុន | ៥៣ | ប | បឋម | បឋមប្រាសាទស្រះកែវ ស្រុកបាទី ខេត្តតាកែវ | ០២-០៨-១៤ | ខ្យល់គរ | ១៤០២តក | ១០០៦២ |
| ៥៣ | ពៅ សារិន | ៥៧ | ប | បឋម | បឋមអង្គមេត្រី ក្រុងដូនកែវ ខេត្តតាកែវ | ២៧-០៨-១៤ | ជរាពាធ | ៣៦៣៥តក | ១០០៦៣ |
| ៥៤ | យឹម រឿន | ៤២ | ប | បឋម | បឋមក្រាំងស្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ | ០៤-០៩-១៤ | ជរាពាធ | ៤៨២៣តក | ១០០៦៤ |
| ៥៥ | ផាត់ ដា | ៣២ | ប | បឋម | អនុវិទ្យាល័យអង្គប្រាសាទ ស្រុកគីរីវង់ តាកែវ | ១១-០៩-១៤ | គ្រោះថ្នាក់ចរាចរ | ៨៣១០តក | ១០០៦៥ |
| ៥៦ | ជួន ប្រមូល | ៤៩ | ប | មបភ | វិទ្យាល័យសម្តេចហស ស្រុកទ្រាំង តាកែវ | ០៤-០៩-១៤ | មហារីកឈាម | ២៣៩០តក | ១០០៦៦ |
| **ខ.មរណៈភាពគូស្រករ** | | | | | | | | | |
| ០១ | យ៉ែម វឌ្ឍនា | ៣០ | ប | មបភ | ប្តីអ្នកគ្រូ វ៉ាន់ ស្រីមុំ បឋមកោះរ៉ាង បន្ទាយមាស | ០៩-១០-១៤ | ចងកសម្លាប់ខ្លួន | ៦១១៥កព | ៥៨៨៤ |
| ០២ | ប៉ាង គី | ២៤ | ស | បឋម | ប្រពន្ធលោកគ្រូ អឹង និន បឋមវត្តលំពូ កំពង់ត្រាច | ១១-១០-១៤ | ជម្ងឺបេះដូង | ៧១៣០កព | ៥៨៨៥ |
| ០៣ | កែវ ធី | ៤៩ | ប | កសិក | ប្តីអ្នកគ្រូ យឹម ស្រីពៅ បឋមវត្តស្វាយ ស្វាយរៀង | ២៩-១០-១៤ | ជម្ងឺរាំរ៉ៃ | ១៦១២ស្វរ | ៥៨៨៦ |
| ០៤ | ឌឿ ថាវ | ៦១ | ប | កសិក | ប្តីអ.គ្រូ អ៊ុំ ស៊ីថាន និវត្តជនតាំងក្រសាំង កំពង់ធំ | ២៦-០៥-១៤ | ជរាពាធ | ២៧២៦កធ | ៥៨៨៧ |
| ០៥ | នុត សាហឿន | ៦៣ | ស | មេផ្ទះ | ប្រ.ពលោកគ្រូ ណុប ឈឿន វិ.ទេពប្រណម្យ កណ | ១៨-០៩-១៤ | ជរាពាធ | ៣៨០៤កណ | ៥៨៨៨ |
| ០៦ | សំ គី | ៧៥ | ប | លក់ដូរ | ប្តីអ.គ្រូ សោ គន្ធា ក្រពើហា ក្រុងតាខ្មៅ កណ្តាល | ២៥-០៩-១៤ | ជរាពាធ | ២២៣២កណ | ៥៨៨៩ |
| ០៧ | តូច ភន | ៦៨ | ប | កសិក | ប្តីអ.គ្រូ ឌី សាវុធ និវត្តជនកណ្តាលស្ទឹង កណ្តាល | ១២-១០-១៤ | ជរាពាធ | ៤៣៧៧កណ | ៥៨៩០ |
| ០៨ | មាស វ៉ាន់ | ៦៤ | ស | មេផ្ទះ | ប្រ.ពលោកគ្រូ ចាប ឈឿន ស្អាង កណ្តាល | ០៤-១០-១៤ | ជរាពាធ | ៥៦៥០កណ | ៥៨៩១ |
| ០៩ | លាវ លឿន | ៦៨ | ស | កសិក | ប្រ.ពលោកគ្រូ ម៉ៅ លួន និវត្តជនសូត្រនិគម ស.រ | ០៩-១០-១៤ | លើសឈាម | ១២០៤សរ | ៥៨៩២ |
| ១០ | តាន់ រឿម | ៧០ | ស | កសិក | ប្រ.ពលោកគ្រូ គីម ហេង និវត្តជនប្រាសាទបាគង | ០៦-០៨-១៤ | ជរាពាធ | ១៦៨៦សរ | ៥៨៩៣ |
| ១១ | ប៊ី ម៉ុតស៊ិន | ៧៤ | ស | មេផ្ទះ | ប្រ.ពលោកគ្រូ ប៉ូ សារិន និវត្តជនការិអយក ភព | ២៦-១០-១៤ | ជរាពាធ | ២៤៥៥ភព | ៥៨៩៤ |
| ១២ | ប៊ុន ស៊ី | ៦៣ | ស | មេផ្ទះ | ប្រ.ពលោកគ្រូ អ៊ុក សាវឿន និវត្តជនកុលាប១ ភព | ២៦-០៨-១៤ | ជរាពាធ | ៣១៦៨ភព | ៥៨៩៥ |
| ១៣ | អ៊ុំ សុផល | ៦០ | ប | កម្មករ | ប្តីអ.គ្រូ សរ ស៊ីវន្ថា បឋមស្ទឹងមានជ័យ ភ្នំពេញ | ០៧-០៩-១៤ | ជរាពាធ | ១១៥៣ភព | ៥៨៩៦ |
| ១៤ | អ៊ុក សារ៉ាត | ៥៨ | ប | កម្មករ | ប្តីអ.គ្រូ ជុំផល្លា បឋមច្បារអំពៅ១ ភ្នំពេញ | ២៩-០៩-១៤ | ជរាពាធ | ៧៦៥ភព | ៥៨៩៧ |
| ១៥ | សាន វណ្ណា | ៤៤ | ប | មទភ | ប្តីអ.គ្រូ សុខ គន្ធា បឋមឫស្សីកែវ ភ្នំពេញ | ១១-១០-១៤ | ទឹកនោមប្រៃ | ៨៥៦៣ភព | ៥៨៩៨ |
| ១៦ | មុំ សុភឿត | ៥៨ | ស | មេផ្ទះ | ប្រ.ពលោកគ្រូនួន លៀស បឋមស្រះចែង ប.ជ | ២៩-០៩-១៤ | ជរាពាធ | ២៦០៣បជ | ៥៨៩៩ |
| ១៧ | តាក់ ឆន | ៤៣ | ប | កសិក | ប្តីអ.គ្រូ ហ៊ុយ សារ៉ន បឋមបន្ទាយនាង ប.ជ | ២២-១០-១៤ | ខ្យល់គរ | ១២៥៤បជ | ៥៩០០ |
| ១៨ | ផៃ លាងហួរ | ៥២ | ប | យោធ | ប្តីអ.គ្រូ អ៊ូសុម៉ានី ការិអយក កងមាស កំពង់ចាម | ០៥-១០-១៤ | គាំងបេះដូង | ៨៥២៤កច | ៥៩០១ |
| ១៩ | កើត សុមាល | ៤៤ | ប | នគរប | ប្តីអ.គ្រូ ឡាវ នាង បឋមព្រៃទទឹង ព្រៃឈរ កំ.ចាម | ១២-១០-១៤ | ជរាពាធ | ៣៤៧៥កច | ៥៩០២ |
| ២០ | ឈិន រិន | ៦០ | ស | កសិក | ប្រព.លោក ទេព សំអន បឋមត្រពាំងរាំង តាកែវ | ០៨-១១-១៤ | លើសឈាម | ៣១៥៤កច | ៥៩០៣ |
| ២១ | ដៀប ផន | ៦៨ | ស | មេផ្ទះ | ប្រ.ពលោកគ្រូ ប៉ែន និន និវត្តជនគីរីវង់ តាកែវ | ៣០-០៧-១៤ | ជរាពាធ | ៤២៥២តក | ៥៩០៤ |
| ២២ | ញាញ់ សារឹម | ៥២ | ស | មេផ្ទះ | ប្រ.ពលោកគ្រូ ឌុក សំភី និវត្តជនត្រាំកក់ តាកែវ | ១៤-០៨-១៤ | ជរាពាធ | ២២៩៤តក | ៥៩០៥ |
| ២៣ | សាំង សុខា | ៥២ | ស | មេផ្ទះ | ប្រ.ពលោក ម៉ី គិន និវត្តជនគីរីវង់ តាកែវ | ០៩-០៩-១៤ | ជរាពាធ | ៤២៩៦តក | ៥៩០៦ |

មេត្តាប្រមូលភាគទានឧបត្ថម្ភប្រចាំខែធ្នូ ឆ្នាំ២០១៤ ឱ្យទាន់ពេលវេលាដើម្បីដោះស្រាយជូនគ្រួសារសព។

**ចំណាំ:** ត្រូវបង់ប្រាក់ឧបត្ថម្ភសពសមាជិក ៥៦ ន × ៤០៛ = ២២៤០៛

សពគូស្រករ ២៣ ន × ២០៛ = ៤៦០៛

ភាគទានប្រចាំខែ = ២០០៛

ភាគទានសាងសង់ផ្ទះគ្រូបង្រៀន = ៣០០៛

**សរុប** = ៣.២០០៛

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០១៤

ជ.គណៈកម្មាធិការកណ្តាល

**អគ្គលេខាធិការរង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការកណ្តាល
លេខ: ០១ /១៥គ.ក

## សេចក្តីជូនដំណឹងមរណៈភាពប្រចាំខែ មករា ឆ្នាំ២០១៥
## តាងនាមសមាគមបុគ្គលិកសិក្សាខ្មែរទាំងមូលគណៈកម្មាធិការកណ្តាលនៃ ស.ប.ស.ខ.
## សូមសម្តែងក្តីសោកស្តាយជាទីបំផុតចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ
## ហើយសូមចូលរួមរំលែកទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបម្រើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | សពទី |
|---|---|---|---|---|---|---|---|---|---|
| ក.មរណៈភាពសមាជិក | | | | | | | | | |
| 1 | សេង ម៉េង | ៧៤ | ប | គ្រូ | និវត្តជន.បឋមត្រពាំងជ្រៃ ស្រុកកោះធំ ខេត្តកណ្តាល | ១៨-១០-១៤ | ជរាពាធ | ៧៤០ កណ | ១០០៦៧ |
| 2 | នៅ សុខកាន | ៤៤ | ប | ម.ប.ភ | អនុវិទ្យាល័យព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល | ១៩-១០-១៤ | មហារីកបំពង់ក | ១៣៧កណ | ១០០៦៨ |
| 3 | ពេញ បាន | ៦៨ | ប | គ្រូ | និវត្តជន.បឋមឃ្លាំងមឿង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល | ២៩-១០-១៤ | ជម្ងឺហឺត | ៣៤០៤កណ | ១០០៦៩ |
| 4 | តាន់ ឡាយ | ៦៧ | ប | គ្រូ | និវត្តជន បឋមព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល | ០១-១១-១៤ | លើសឈាម | ៣៤៤៤កណ | ១០០៧០ |
| 5 | ឃ្លោក សារិទ្ធ | ៥៨ | ប | ម.ប.ភ | អនុវិ.ស្វាយអំពារ ស្រុកមុខកំពូល ខេត្តកណ្តាល | ២២-១០-១៤ | គ្រោះថ្នាក់ចរាចរ | ៨០៧៣កណ | ១០០៧១ |
| 6 | ប៉ោ ចាន់រ័ត្ន | ៦៥ | ប | គ្រូ | និវត្តជន. ការិ.អយក ស្រុកដងទង់ ខេត្តកំពត | ១៦-១១-១៤ | ជរាពាធ | ២៥៦១កព | ១០០៧២ |
| 7 | មិន ណៃម | ៥៧ | ស | បឋម | បឋម.ឧត្តមសិរីរ័តន៍ ស្រុកឈូក ខេត្តកំពត | ២៧-១០-១៤ | មហារីកក | ៣៥៣៤កព | ១០០៧៣ |
| 8 | សួន សារឿន | ៦៣ | ប | គ្រូ | អនុវិ.អង្គមេត្រី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | ១៨-១០-១៤ | ជរាពាធ | ២០៩៧កស្ព | ១០០៧៤ |
| 9 | ឃួន ឌឿន | ៧៧ | ប | គ្រូ | និវត្តជន ម.អ.យ.ក ខេត្តកំពង់ស្ពឺ | ១១-១១-១៤ | ជរាពាធ | ០២៣៨កស្ព | ១០០៧៥ |
| 10 | ហ៊ិន សារឿន | ៧១ | ស | គ្រូ | និវត្តជន ការិ អ.យ.ក ស្រុកសណ្តាន់ ខេត្តកំពង់ធំ | ២៨-០៥-១៤ | ទឹកនោមផ្អែម | ២៦៤១កធ | ១០០៧៦ |
| 11 | ស៊ី សេងគី | ៦៨ | ប | គ្រូ | និវត្តជន ការិ អ.យ.ក ស្រុកស្ទោង ខេត្តកំពង់ធំ | ២៤-០៦-១៤ | ជរាពាធ | ២១៩៩កធ | ១០០៧៧ |
| 12 | ប៉ាង រ៉ន | ៦៧ | ប | គ្រូ | និវត្តជន ការិ អ.យ.ក ស្រុកសណ្តាន់ ខេត្តកំពង់ធំ | ២០-០៦-១៤ | ជរាពាធ | ២៧៣១កធ | ១០០៧៨ |
| 13 | វ៉ាញ វ៉ាច័ន្ទ | ៦៧ | ស | គ្រូ | និវត្តជន ស្រុកសំបូរ ខេត្តក្រចេះ | ១៦-១១-១៤ | ជរាពាធ | ០១១៨ក្រច | ១០០៧៩ |
| 14 | សូ យឹម | ៧២ | ប | គ្រូ | និវត្តជន ស្រុកឆ្លូង ខេត្តក្រចេះ | ២២-១១-១៤ | ជរាពាធ | ១៤៣១ក្រច | ១០០៨០ |
| 15 | អ៊ិត យាន | ៦៨ | ប | គ្រូ | និវត្តជន ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង | ១៧-០៧-១៤ | ដាច់សរសៃឈាម | ០១១១៩កឆ | ១០០៨១ |
| 16 | ទេព នឿន | ៧០ | ប | គ្រូ | និវត្តជន ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង | ១៩-០៧-១៤ | ទឹកនោមផ្អែម | ០១០៥៨កឆ | ១០០៨២ |
| 17 | ស៊ិន ច័ន្ទរុណ | ៥៧ | ប | បឋម | ការិ អ.យ.ក ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង | ០៩-០៨-១៤ | មហារីកថ្លើម | ០២២២០កឆ | ១០០៨៣ |
| 18 | ហែម ម៉ន | ៦៨ | ប | គ្រូ | និវត្តជន ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង | ២១-០៨-១៤ | គ្រោះថ្នាក់ចរាចរ | ០២២៦៦កឆ | ១០០៨៤ |
| 19 | ជូ សុវត្ថិ | ៦១ | ស | គ្រូ | និវត្តជន ស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំង | ២២-០៨-១៤ | ទឹកនោមផ្អែម | ០២៣៩៦កឆ | ១០០៨៥ |
| 20 | យូ សុខលី | ៤៣ | ប | ម.ប.ភ | វិទ្យាល័យព្រះបាទសុរាម្រិត ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង | ២៦-០៨-១៤ | ជម្ងឺពុកឆ្អឹង | ០១៥៧៩កឆ | ១០០៨៦ |
| 21 | ស៊ឹម សារឿន | ៤៣ | ប | បឋម | បឋម ធ្លកវៀន ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង | ១៨-១១-១៤ | ជម្ងឺរបេង | ០៧៤៥កឆ | ១០០៨៧ |
| 22 | កង ហ៊ី | ៤៤ | ប | បឋម | បឋម ព្រៃគ្រីជើង ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង | ២៨-១១-១៤ | លើសឈាម | ០៣៣៥កឆ | ១០០៨៨ |
| 23 | អ៊ិត ណាត | ៥៥ | ប | បឋម | បឋម ថ្មរៀង ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង | ២៣-១០-១៤ | ទឹកនោមផ្អែម | ០២៩០កឆ | ១០០៨៩ |
| 24 | សេង គឹមតិច | ៧៤ | ប | គ្រូ | និវត្តជន អនុវិទ្យាល័យចាក់អង្រែ រាជធានីភ្នំពេញ | ០៩-១១-១៤ | ជរាពាធ | ២០៦៦ភព | ១០០៩០ |
| 25 | គង់ ឆៃវ៉ន | ៦៨ | ប | គ្រូ | និវត្តជន បឋម ឫស្សីកែវ រាជធានីភ្នំពេញ | ០៩-១១-១៤ | ជរាពាធ | ៣៦៥៧ភព | ១០០៩១ |
| 26 | ជឹន សំអុល | ៣៧ | ប | ម.ប.ភ | អនុវិទ្យាល័យព្រែកព្នៅ រាជធានីភ្នំពេញ | ១០-១១-១៤ | ជម្ងឺថ្លើម | ១១៥០៥ភព | ១០០៩២ |
| 27 | អ៊ឹង រស្មី | ៤៧ | ប | ម.ប.ភ | វិទ្យាល័យសន្ធរម៉ុក រាជធានីភ្នំពេញ | ២៥-១១-១៤ | ដុះសាច់ខួរក្បាល | ៥៩៣៣ភព | ១០០៩៣ |
| 28 | ឌី ជីនសារុន | ៧៧ | ប | គ្រូ | និវត្តជន បឋមក្បាលកោះ ស្រុកកោះធំ ខេត្តកណ្តាល | ១០-១១-១៤ | ជរាពាធ | ៥១៥កណ | ១០០៩៤ |
| 29 | ណុប សារឿន | ៥៩ | ប | បឋម | បឋម អង្គសិរី ស្រុកពញាឮ ខេត្តកណ្តាល | ២៧-១០-១៤ | ជរាពាធ | ១៧៦៥កណ | ១០០៩៥ |
| 30 | ចាន់ សុខុម | ៧៤ | ប | គ្រូ | និវត្តជន បឋមមង្គលបុរី ស្រុកអង្គស្នួល ខេត្តកណ្តាល | ១៦-១១-១៤ | ជរាពាធ | ៤៨៦៣កណ | ១០០៩៦ |
| 31 | ញ៉ែម សុភា | ៥៨ | ស | បឋម | បឋម ហ.ស ឧន្តីបារមី៧មករា ស្រុកស្អាង ខេត្តកណ្តាល | ២៤-១១-១៤ | ជរាពាធ | ៦១៩៦កណ | ១០០៩៧ |
| 32 | ឡេង លឿន | ៣៩ | ប | ម.ប.ភ | អនុវិទ្យាល័យព្រះសីហនុវរ្ម័នស្រុកស្អាង ខេត្តកណ្តាល | ០៤-១២-១៤ | ជរាពាធ | ៨០៥០កណ | ១០០៩៨ |
| 33 | ឈឹម សារឿន | ៦៦ | ប | គ្រូ | និវត្តជន បឋមវត្តជ្រោយ ស្រុកកោះធំ ខេត្តកណ្តាល | ០១-១២-១៤ | ជរាពាធ | ៧៦៦កណ | ១០០៩៩ |
| 34 | ពុធ សុត្ថា | ៧០ | ប | គ្រូ | និវត្តជន បឋម ពេជ រតន៍ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង | ១៥-១០-១៤ | ជរាពាធ | ១៨៤៥៣៧វ | ១០១០០ |
| 35 | ប៊ូ យ៉ង់ | ៤៥ | ប | ម.ប.ភ | អនុវិទ្យាល័យប្រធាតុ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង | ១៩-១១-១៤ | ជរាពាធ | ១៦៦៥៣៧វ | ១០១០១ |
| 36 | ងួន ពោន | ៧៤ | ប | គ្រូ | និវត្តជន ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង | ១៥-១០-១៤ | ជរាពាធ | ៣៩៥៨៣៧វ | ១០១០២ |
| 37 | អ៊ិន សុខ | ៦០ | ប | គ្រូ | និវត្តជន វិទ្យាល័យកំចាយមារ ខេត្តព្រៃវែង | ០៥-១១-១៤ | គ្រោះថ្នាក់ចរាចរ | ២៨១០៣៧វ | ១០១០៣ |
| 38 | ឃឹម ស៊ីង | ៦២ | ប | គ្រូ | និវត្តជន វិទ្យាល័យច័ន្ទគ្រីស្នា ស្រុកមេសាង ខេត្តព្រៃវែង | ០១-១០-១៤ | ជរាពាធ | ៥៤៨៦៣៧វ | ១០១០៤ |
| 39 | ទូច ឡុង | ៦១ | ប | គ្រូ | និវត្តជន បឋមត្រពាំងឈ្លូស ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ | ៣០-១១-១៤ | ដាច់សរសៃ<br>ឈាមខួរក្បាល | ១៨០តឃ | ១០១០៥ |
| 40 | ឡេង ចុល្លី | ៥៤ | ប | បឋម | បឋម ទូលក្តី ក្រុងសួង ខេត្តត្បូងឃ្មុំ | ១២-១២-១៤ | ជរាពាធ | ១៥២៦តឃ | ១០១០៦ |
| 41 | សុខ សុវណ្ណ | ៤៩ | ប | បឋម | បឋម ជ្រៃបិទមាស ក្រុងសួង ខេត្តត្បូងឃ្មុំ | ១២-១២-១៤ | ជរាពាធ | ១៥៤០តឃ | ១០១០៧ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 42 | ម៉ម ម៉ុន | ៦១ | ប | គ្រូ | និវត្តជន វិទ្យាល័យស្រីសន្ធរ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម | ០៣-១១-១៤ | ជរាពាធ | ៧១១២កច | ១០១០៨ |
| 43 | ម៉ៅ អែរអួន | ៦២ | ស | គ្រូ | និវត្តជនបឋមកណ្ដាលកោះជើងស្រុកកោះសូទិន ខេត្តកំពង់ចាម | ២៩-១០-១៤ | ជរាពាធ | ៤៧៤០កច | ១០១០៩ |
| 44 | ហែម សាត | ៧៣ | ប | គ្រូ | និវត្តជន បឋមជយោ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម | ១៧-១១-១៤ | ជរាពាធ | ៥៨៤៤កច | ១០១១០ |
| 45 | កាន់ សុធីរ | ៣០ | ប | ម.ទ.ភ | វិទ្យាល័យ ហ.ស គរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម | ២១-១១-១៤ | រលាកពោះវៀន | ១២៧៥៥កច | ១០១១១ |
| 46 | ខៃ លឹមឈាង | ៧២ | ប | គ្រូ | និវត្តជន បឋមប្រិមប្រីយ៍ ស្រុកព្រៃឈរ ខេត្តកំពង់ចាម | ២៨-១១-១៤ | ទឹកនោមប្រៃ | ២៩៩៦កច | ១០១១២ |
| 47 | ឈឹម ឆាំ | ៦៥ | ប | គ្រូ | និវត្តជន ការិ អ.យ.ក ស្រុកស្វាយទាប ខេត្តស្វាយរៀង | ២០-១១-១៤ | ខ្យល់គរ | ២៣៧១ស្វ | ១០១១៣ |
| 48 | សៅ ស៊ីណា | ៤១ | ស | បឋម | ការិ អ.យ.ក ស្រុករំដួល ខេត្តស្វាយរៀង | ២៨-១១-១៤ | ទឹកនោមប្រៃ | ២៩៨០ស្វ | ១០១១៤ |
| 49 | ប៊ី សុខុន | ៦៨ | ប | គ្រូ | និវត្តជន ការគ្រប់គ្រងគណៈកម្មាធិការកណ្ដាល | ១៧-១១-១៤ | ជរាពាធ | ៣៣៩៣គក | ១០១១៥ |
| 50 | ស៊ុន ណាគ្រី | ៦៦ | ប | គ្រូ | និវត្តជន ការគ្រប់គ្រងគណៈកម្មាធិការកណ្ដាល | ០៩-១២-១៤ | មហារីកថ្លើម | ៣៥៧៣គក | ១០១១៦ |
| 51 | វ៉ា សារិន | ៧៧ | ប | គ្រូ | និវត្តជន ការគ្រប់គ្រងគណៈកម្មាធិការកណ្ដាល | ១១-១២-១៤ | ជរាពាធ | ១០៣២បប | ១០១១៧ |
| 52 | សួម សាន | ៦៩ | ប | គ្រូ | និវត្តជន ស្រុកសង្កែ ខេត្តបាត់ដំបង | ០៨-០៦-១៤ | មហារីក | ២១៩៨បប | ១០១១៨ |
| 53 | ជិង សុផាន់ | ៧៥ | ប | គ្រូ | និវត្តជន ស្រុកបវេល ខេត្តបាត់ដំបង | ២១-០៩-១៤ | ជរាពាធ | ៣២០៧បប | ១០១១៩ |
| 54 | ទឹមទន់ លីជាតា | ៤២ | ប | បឋម | បឋមវត្តកំផែង ក្រុងបាត់ដំបង ខេត្តបាត់ដំបង | ១៩-១០-១៤ | ចងក | ៤២៤៧បប | ១០១២០ |
| 55 | សុខ សុធី | ៥៦ | ស | គ្រូ | បឋមអណ្ដូងចេញ ក្រុងបាត់ដំបង ខេត្តបាត់ដំបង | ២២-១០-១៤ | ជរាពាធ | ១១១៧បប | ១០១២១ |
| 56 | អ៊ូច អ៊ិន | ៦៨ | ប | គ្រូ | និវត្តជន ស្រុកមោងឫស្សី ខេត្តបាត់ដំបង | ០១-១១-១៤ | ជរាពាធ | ៤៩៩៦បប | ១០១២២ |
| 57 | ចេង ភឿន | ៤១ | ប | ម.ទ.ភ | វិទ្យាល័យថ្មគោល ស្រុកថ្មគោល ខេត្តបាត់ដំបង | ១៩-១១-១៤ | ទឹកចូលសួត | ១៤១២បប | ១០១២៣ |
| 58 | ម៉ៅ យ៉ន | ៥៨ | ប | បឋម | បឋម វឌ្ឍវិជ្ជា ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង | ០១-១២-១៤ | គ្រួសតម្រងនោម | ៦៩២៥បប | ១០១២៤ |
| 59 | វ៉ាន់ ចាន់ថន | ២៤ | ស | ម.ទ.ភ | វិទ្យាល័យបវេល ស្រុកបវេល ខេត្តបាត់ដំបង | ០៣-១២-១៤ | គ្រោះថ្នាក់ចរាចរ | ១១៧៥៣បប | ១០១២៥ |
| 60 | ស៊ិន សំ | ៨៥ | ប | គ្រូ | និវត្តជន ក្រុងបាត់ដំបង ខេត្តបាត់ដំបង | ២៣-១១-១៤ | ជរាពាធ | ២៨៣០បប | ១០១២៦ |
| 61 | ញ៉ឹម ម៉ែន | ៧២ | ប | គ្រូ | និវត្តជន ម.អ.យ.ក ខេត្តបាត់ដំបង | ១៧-១២-១៤ | ជរាពាធ | ៣៧៥បប | ១០១២៧ |

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបម្រើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | សពទី |
|---|---|---|---|---|---|---|---|---|---|
| | | | | | ខ.មរណៈភាពគូស្រករ | | | | |
| 1 | យូរ គីម | ៦៤ | ស | មេផ្ទះ | ប្រពន្ធលោកគ្រូម៉ីសុខប.ទួលសាលាស្រុកអង្គស្នួលខេត្តកណ្ដាល | ២៧-១០-១៤ | ជរាពាធ | ៤៨០៤កណ | ៥៩០៧ |
